

# សាក្សីប្រវត្តិសាស្ត្រ

## សៀវភៅកំណត់ហេតុរបស់ព្រះមហាក្សត្រី
## នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ


បកប្រែពីភាសាបារាំងមកជាភាសាអង់គ្លេស
និងសេចក្តីផ្តើម

**ឯកអគ្គរាជទូតបណ្ឌិត ហ្វូលីយ៉ូ អេ.ហែលម្រេស**

អារម្ភកថា និងអវសានកថា

**ឆាំង យុ**


ព្រះរាជដំណើរសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ទៅកាន់តំបន់រំដោះរណសិរ្សរួបរួមជាតិកម្ពុជា ឆ្នាំ១៩៧៣



ផ្លូវលំហូជីមិញ តាមបណ្តោយជួរភ្នំឆ្ពោះចុះទៅកាន់ព្រំដែនកម្ពុជា។
រូបថតជាស្នាព្រះហស្តសម្តេច ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ



**មជ្ឈមណ្ឌលឯកសារកម្ពុជា / បណ្ណាល័យសម្តេចម៉ែ**
ភូមិគ្រឹះលេខ ១១ ផ្លូវ ២៥៦ សង្កាត់បតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ១២២០០ ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទ៖ +(៨៥៥) ១២ ៩០ ៥៥ ៩៥
សារអេឡិចត្រូនិច៖ dccam@online.com.kh
គេហទំព័រ៖ www.dccam.org

**សាក្សីប្រវត្តិសាស្ត្រ៖ សៀវភៅកំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ**
**ព្រះរាជដំណើររបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ទៅកាន់តំបន់រំដោះរណសិរ្សរួបរួមជាតិកម្ពុជា ឆ្នាំ១៩៧៣**

១. ប្រទេសកម្ពុជា - ច្បាប់ - សិទ្ធិមនុស្ស
២. ប្រទេសកម្ពុជា - នយោបាយ និងរដ្ឋាភិបាល - ចន្លោះឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៩
៣. ប្រទេសកម្ពុជា - ប្រវត្តិសាស្ត្រ - ចន្លោះឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៩

គម្រោងស្រាវជ្រាវភាសាចិនទទួលបានហិរញ្ញប្បទានយ៉ាងសប្បុរសពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID)

ឯកសារបកប្រែជាភាសាខ្មែរទី២២ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា
រក្សាសិទ្ធិឆ្នាំ២០២៣ ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា

រក្សាសិទ្ធិគ្រប់យ៉ាង។ មិនមានផ្នែកណាមួយនៃសៀវភៅនេះត្រូវបាន បោះពុម្ពឡើងវិញ ឬប្រើប្រាស់ ក្នុងទម្រង់ ឬក្នុងមធ្យោបាយណាមួយឡើយរួមមានដូចជា ការថតចម្លង ការកត់ត្រាទុក ឬការថតទុកនៅក្នុងប្រព័ន្ធ ផ្ទុកព័ត៌មានផ្សេងៗទៀតដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នកបោះពុម្ពបានឡើយ។

ការអះអាង៖ ការបោះពុម្ពផ្សាយនេះ ទទួលបានជំនួយហិរញ្ញប្បទានមួយផ្នែកពី (គម្រោងចងក្រងឯកសារនិងលទ្ធិប្រជាធិបតេយ្យ) ក្រសួងការបរទេសសហរដ្ឋអាមេរិក។ មតិយោបល់ ការរកឃើញ និងសេចក្តីសន្និដ្ឋានដែលមាននៅក្នុងឯកសារនេះគឺជារបស់អ្នកនិពន្ធ ហើយមិនឆ្លុះបញ្ចាំងអំពីមតិយោបល់របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក និងទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិឡើយ។ ទស្សនៈដែលបានបង្ហាញនៅក្នុងសៀវភៅនេះគឺជាទស្សនៈរបស់អ្នកនិពន្ធតែប៉ុណ្ណោះ។

ប្រភពរូបថត៖ រក្សាសិទ្ធិដោយសមុច្ច័យរបស់ឯកអគ្គរាជទូតបណ្ឌិត ហ្សូលីយ៉ូ អេ.ហែលឌ្រេស,
បណ្ណាល័យសម្តេចម៉ែ, វិទ្យាស្ថានស្លឹករឹត/មជ្ឈមណ្ឌលឯកសារកម្ពុជា។

9 789924 552017 >

បោះពុម្ពនៅប្រទេសកម្ពុជា ឆ្នាំ២០២៣

# សាក្សីប្រវត្តិសាស្ត្រ

## សៀវភៅកំណត់ហេតុរបស់ព្រះមហាក្សត្រី
## នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ

ព្រះរាជដំណើរសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ទៅកាន់
តំបន់រំដោះរណសិរ្សរួបរួមជាតិកម្ពុជា ឆ្នាំ១៩៧៣

បកប្រែពីភាសាអង់គ្លេសមកជាភាសាខ្មែរ

# សូវិចិត្រ មេត្តា

ត្រួតពិនិត្យ និង សម្រួល

# ជាំខ យុ និង សុភ័ក្ត្រ តាណា

បណ្ណាល័យសម្តេចម៉ែ
នៃមជ្ឈមណ្ឌលឯកសារកម្ពុជា
ឆ្នាំ២០២៣

# មាតិកា


| | |
|---|---|
| ទំព័រលេខ I-IV | ផែនទីបង្ហាញអំពីព្រះរាជដំណើររបស់ព្រះវររាជមាតាជាតិខ្មែរ៖ លី កុកឆាយ |
| ទំព័រលេខ ១ | អារម្ភកថា៖ ឆាំង យុ |
| ទំព័រលេខ ៣ | សេចក្តីថ្លែងអំណរគុណ៖ ឯកអគ្គរាជទូតបណ្ឌិត ហ្វលីយ៉ូ អេ.ហៃលខ្មែរ |
| ទំព័រលេខ ៤ | ប្រវត្តិរូបសង្ខេបរបស់បុគ្គលសំខាន់ៗ |
| ទំព័រលេខ ៨ | សេចក្តីផ្តើម៖ ឯកអគ្គរាជទូតបណ្ឌិត ហ្វលីយ៉ូ អេ.ហៃលខ្មែរ |
| ទំព័រលេខ ១៦ | ផ្នែកទី១ - ការយាងចេញដំណើរ |
| ទំព័រលេខ ៣៤ | ផ្នែកទី២ - ការយាងមកដល់ប្រទេសកម្ពុជា |
| ទំព័រលេខ ៦២ | ផ្នែកទី៣ - ការយាងជួបជាមួយប្រជានុរាស្ត្រកម្ពុជា |
| ទំព័រលេខ ៧៤ | ផ្នែកទី៤ - ការយាងត្រឡប់ទៅកាន់ប្រទេសចិន |
| ទំព័រលេខ ១០៣ | អវសានកថា៖ ឆាំង យុ |


Zhangjiakou
Baotou
Datong
Beijing
Tianjin
Dandong
Dalian
Baoding
Shijiazhuang
Taiyuan
Yantai
Jinan
Zibo
Qingdao
Yellow Sea
Handan
Xining
Lanzhou
Zhengzhou
Xi'an
CHINA
Zhumadian
Taizhou
Nanjing
Hefei
Shanghai
Xiangfan
Hangzhou
Yichang
Wuhan
Chengdu
Chongqing
Nanchang
Wenzhou
Changsha
Lijiang
Guiyang
Fuzhou
Taipei
Quanzhou
Kunming
Taiwan
Liuzhou
Shantou
MYANMAR (BURMA)
Guangzhou
Kaohsiung
Nanning
Hong Kong
Mandalay
Hanoi
Zhanjiang
Nay Pyi Taw
Gulf of Tonkin
LAOS
Vientiane
Yangon
Da Nang
THAILAND
VIETNAM
Bangkok
CAMBODIA
Phnom Penh
Ho Chi Minh City
Andaman Sea
Gulf of Thailand
Sulu Sea
N
Esri, HERE, Garmin, FAO, NOAA, USGS, Esri, USGS
0 150 300 600 km
Map by Ly Kok-Chhay | Documentation Center of Cambodia


Ratchathani
Pakxe
Nakhon Ratchasima
Attapu
VIETNA
Huai Thapthan-Huai Samran Wildlife Preserve Area
Thap Lan National Park
Pleiku City
Siem Reap
Battambang
Tônlé Sab
Mekong
CAMBODIA
Phuong Thang Loi
Phnom Penh
Bien Hoa
Phan Thiet City
Ho Chi Minh City
Sihanoukville
Mekong
Mekong
N
0 40 80 160 km
Can Tho
NOSTRA, Esri, HERE, Garmin, FAO, NOAA, USGS, Esri, CGIAR, USGS
Map by Ly Kok-Chhay | Documentation Center of Cambodia


Saravan
Ban Phon
Ubon Ratchathani
Pakxe
Nakhon Ratchasima
Attapu
VIETNAM
Huai Thapthan-Huai Samran Wildlife Preserve Area
Khao Yai National Park
Thap Lan National Park
Pleiku City
Quy Nhon City
Siem Reap
Battambang
Tonlé Sab
Mekong
CAMBODIA
Phuong Thang Loi
Nha Trang City
Phnom Penh
Phan Thiet City
Bien Hoa
Ho Chi Minh City
Sihanoukville
N
0 50 100 200 km
Mekong
Can Tho
NOSTRA, Esri, HERE, Garmin, FAO, NOAA, USGS, Esri, USGS
Map by Ly Kok-Chhay | Documentation Center of Cambodia


INDOCHINA AREA
International boundary
Province boundary
National capital
Railroad
Road
Trail
Route number
Canal
Spot elevation (in feet)
GULF OF THAILAND
CAMBODIA
SOUTH CHINA SEA
BATTAMBANG
PURSAT
KOMPONG THOM
KRATIE
MONDOLKIRI
STUNG TRENG
PREAH VIHEAR
SIEM REAP
KOMPONG CHAM
PREY VENG
KAMPOT
KOH KONG
KOMPONG SPEU
TAKEO
PLEIKU
DARLAC
PHUOC LONG
BINH THUAN
NINH THUAN
PHUOC TUY
KIEN GIANG
KIEN HOA
VINH BINH
AN XUYEN
SAIGON
BANGKOK
THAILAND

# អារម្ភកថា

សៀវភៅកំណត់ហេតុមួយច្បាប់នេះ គឺជាព្រះរាជសំណេរដើម និងមិនបានកែសម្រួល ឆ្លុះបញ្ចាំងអំពីព្រះរាជតម្រិះ ព្រះរាជយោបល់ និងព្រះរាជទស្សនៈរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរក្នុងសេរីភាព និងសេចក្តីថ្លៃថ្នូរ ក្នុងអំឡុងពេលដែលព្រះអង្គអមព្រះរាជដំណើរ សម្តេច ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ព្រះវររាជបិតាជាតិខ្មែរ យាងដំណើរតាមយន្តហោះចេញពីទីក្រុងប៉េកាំងទៅកាន់ ទីក្រុងហាណូយ រួចយាងបន្តព្រះរាជដំណើរពីទីក្រុងហាណូយដោយរថយន្ត តាមបណ្តោយផ្លូវលំហូជីមិញទៅកាន់ខេត្តសៀមរាប ប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៧៣។ ព្រះរាជដំណើររបស់ ព្រះអង្គទាំងពីរបានចំណាយអស់រយៈពេលមួយខែ ប៉ុន្តែសៀវភៅកំណត់ហេតុនេះបានបង្ហាញ យ៉ាងច្រើនអំពីសេចក្តីថ្លៃថ្នូរ និងភាពទន់ភ្លន់របស់ព្រះមហាក្សត្រី ទោះបីព្រះអង្គស្ថិតនៅក្នុងស្ថានភាពវឹកវរដែលគ្របដណ្តប់ពេញប្រទេសកម្ពុជា និងតំបន់អាស៊ីអាគ្នេយ៍នាពេលនោះក្តី។

ព្រះមហាក្សត្រី គឺជាសាក្សីផ្ទាល់ចំពោះប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា នារយៈកាលជាង ៧ ទសវត្សរ៍កន្លងមក ហើយព្រះអង្គ គឺជាឥស្សរជនប្រវត្តិសាស្ត្រដ៏លេចធ្លោមួយអង្គក្នុងអំឡុងពេលនោះ។ ព្រះរាជសំណេរនៅក្នុងសៀវភៅកំណត់ហេតុរបស់ទ្រង់ ផ្តល់នូវព្រះរាជតម្រិះសង្ខេបអំពីជំពូកដ៏សំខាន់នៃប្រវត្តិសាស្ត្រប្រទេសកម្ពុជា។ ព្រះរាជសំណេររបស់ទ្រង់ត្បិតតែយ៉ាងសង្ខេប ប៉ុន្តែប្រកបដោយអត្ថន័យខ្លឹមសារមុតស្រួច ព្រមទាំងបង្ហាញថា សោភ័ណភាព និង សេចក្តីថ្លៃថ្នូរនៅតែអាចបន្តមាន បើទោះបីជាស្ថិតនៅក្នុងស្ថានភាពនៃភ្នក់ភ្លើងសង្គ្រាមយ៉ាងណាក្តី។ ព្រះមហាក្សត្រី បានព្រះលិខិតរៀបរាប់សរសើរយ៉ាងលម្អិតអំពីបុគ្គលដែលបានជួយ និងអ្នកហែហមព្រះអង្គ។ ព្រះអង្គព្រមទាំងបានព្រះរាជពិពណ៌នាដោយឥតលម្អៀងយ៉ាងលម្អិតអំពីការបំផ្លិចបំផ្លាញដែលកើតមាននៅក្នុងប្រទេសកម្ពុជារួម ជាមួយនឹងទិដ្ឋភាពនៃសម្រស់ធម្មជាតិដ៏ត្រកាលដែលទ្រង់បានឃើញក្នុងអំឡុងព្រះរាជដំណើររបស់ទ្រង់។

ទោះបីជាព្រះមហាក្សត្រីបានទ្រង់ព្រះលិខិតរៀបរាប់ត្រួសៗអំពីភាពងងឹត និងការបំផ្លិចបំផ្លាញដោយសង្គ្រាមយ៉ាងណាក៏ដោយ តថភាពទាំងនេះគឺមិនមែនជាសមាសធាតុសំខាន់បំផុតនៃសៀវភៅកំណត់ហេតុរបស់ទ្រង់ឡើយ។ ព្រះរាជសំណេរពិពណ៌នា របស់ព្រះមហាក្សត្រីអំពីព្រះរាជដំណើររបស់ទ្រង់ទាំងពីរព្រះអង្គ គឺជាកត្តាជំរុញទឹកចិត្ត និងផ្តល់ជាព័ត៌មានសព្វគ្រប់ជ្រុងជ្រោយ សម្រាប់អ្នកដឹកនាំនយោបាយ និងប្រជានុរាស្ត្រកម្ពុជាទូទៅ ដែលនេះបានសបញ្ជាក់ថា ស្មារតីមនុស្សជាតិ នៅតែអាចបញ្ចេញពន្លឺនៅក្នុងកាលៈទេសៈដ៏គ្រោះថ្នាក់ ឬដ៏សង្វេគជាទីបំផុតយ៉ាងណាក្តី។

ព្រះមហាក្សត្រីទ្រង់បានកត់ត្រាអំពីភាពលំបាក និងគ្រោះថ្នាក់មួយចំនួនក្នុងព្រះរាជដំណើររបស់ទ្រង់ ក៏ប៉ុន្តែព្រះរាជសំណេរប្រចាំថ្ងៃរបស់ព្រះអង្គស្ទើរតែទាំងស្រុងផ្តល់នូវតុល្យភាពឥតលម្អៀងដោយរួមបញ្ចូលទាំងសក្ខីកម្មអំពីភាពអស្ចារ្យ ជ័យជម្នះ ឬសម្រស់ស្រស់ត្រកាលនៃទេសភាពតំបន់។ ព្រះរាជតម្រិះរបស់ទ្រង់ត្រូវបានបង់ក្រងឡើងតាំងពីជាងពាក់កណ្តាលសតវត្សរ៍មុន ប៉ុន្តែព្រះរាជសំណេរនេះ ស្ថិតនៅជាចីរកាលពីព្រោះកំណត់ហេតុនេះបានបង្ហាញប្រជានុរាស្ត្រកម្ពុជា នៅតែអាចមើលឃើញពីភាពស្រស់ស្អាត និងសេចក្តីសង្ឃឹម នៅគ្រប់កាលៈទេសៈទាំងអស់។

ព្រះរាជតួនាទីរបស់ព្រះមហាក្សត្រីនៅក្នុងប្រទេសកម្ពុជាគឺពិតជាមានសារៈសំខាន់យ៉ាងមហិមាណាស់។ ព្រះរាជតួនាទីរបស់ទ្រង់ គឺជាឧទាហរណ៍មួយនៃការប្រឈមមុខទៅនឹងសោកនាដកម្ម និងការតតាំងជាមួយនឹងព្រឹត្តិការណ៍ដ៏អាក្រក់ តាមរយៈភាពទន់ភ្លន់ ភាពថ្លៃថ្នូរ និងភាពសន្តោសប្រណីចំពោះប្រជានុរាស្ត្រកម្ពុជា មិនឋាមាន ឬក្រ និងតាមរយៈភាពបរិសុទ្ធ សេចក្តីស្មោះត្រង់ និងការប្តេជ្ញាដែលមិនរួញរាចំពោះប្រទេសជាតិរបស់ទ្រង់។ អតីតកាលរបស់ប្រទេសកម្ពុជានឹងនៅតែជិតដាមទៅដោយភាពច្របូកច្របល់ សោកនាដកម្ម និង ភាពភ័យរន្ធត់ ប៉ុន្តែព្រះមហាក្សត្រី គឺជាតំណាងឱ្យភាពទន់ភ្លន់ និងភាពរឹងមាំនៃព្រលឹងជាតិខ្មែរ ដែលអ្នកដឹកនាំកម្ពុជាអាចយកជាគំរូ និងដែលប្រទេសកម្ពុជាអាចសម្រេចបានក្នុងនាមជាប្រជាជាតិមួយ។

**ឆាំង យុ**

**នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា**



# សេចក្តីថ្លែងអំណរគុណ

ឯកសារនេះ គឺជាឯកសារបកប្រែនៃឯកសារប្រវត្តិសាស្ត្រដ៏ពិសេសប្លែកពីគេ ដែលជាស្នាព្រះហស្តរបស់សម្តេចព្រះមហាក្សត្រ នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ នៅក្នុងព្រះរាជដំណើររបស់ទ្រង់មកកាន់ប្រទេសកម្ពុជានៅចន្លោះខែមីនា ដល់ខែមេសា ឆ្នាំ១៩៧៣។ ដូចដែលអ្នកដឹកនាំប្រទេសវៀតណាមម្នាក់បានលើកឡើងកាលពីពេលថ្មីៗនេះថា “ព្រះមហាក្សត្រ គឺជាបុគ្គលតែមួយអង្គគត់ ដែលគង់នៅមានព្រះជន្មពីសម័យកាលជាប្រវត្តិសាស្ត្រនោះ។” ហេតុនេះ ខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្សរីករាយក្រៃលែង ដែលអាចនាំមកជូននូវការបកប្រែជាភាសាអង់គ្លេសនៃសៀវភៅកំណត់ហេតុរបស់ព្រះមហាក្សត្រ ដែលពិពណ៌នាយ៉ាងលម្អិតអំពីបទពិសោធន៍ និងការសង្កេតឃើញ របស់ព្រះអង្គក្នុងអំឡុងព្រះរាជដំណើរតាមបណ្តោយផ្លូវលំហូជីមិញ។

ខ្ញុំសូមថ្លែងអំណរព្រះគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះសម្តេចព្រះមហាក្សត្រ នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដែលរាជានុញ្ញាតឱ្យខ្ញុំបកប្រែសៀវភៅកំណត់ហេតុរបស់ទ្រង់ពីភាសាបារាំងទៅជាភាសាអង់គ្លេស និងរាជានុញ្ញាតឱ្យវិទ្យាស្ថានស្លឹករឹតនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបោះពុម្ពផ្សាយសំណៅឯកសារបកប្រែនេះ។

ខ្ញុំក៏សូមអរគុណយ៉ាងជ្រាលជ្រៅចំពោះសាស្ត្រាចារ្យ ចន ឌី. ឆបឈីអារី នៃសាកលវិទ្យាល័យមីឈីហ្កែនដែលបានអានផ្ទៀងផ្ទាត់លើសេចក្តីព្រាងនៃការបកប្រែ និងកែសម្រួលធ្វើឱ្យសំណៅជាភាសាអង់គ្លេសនេះកាន់តែមានភាពល្អប្រសើរឡើង។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណក្រៃលែងចំពោះលោក ឆាំង យុ ក៏ដូចជាបុគ្គលិកវិទ្យាស្ថានស្លឹករឹតនៃមជ្ឈមណ្ឌលឯកសារកម្ពុជាទាំងអស់ ដែលបានឧបត្ថម្ភដល់ការបកប្រែ និងការបោះពុម្ពផ្សាយសៀវភៅកំណត់ហេតុរបស់ព្រះមហាក្សត្រី។

**ឯកអគ្គរាជទូតបណ្ឌិត ហ្វូលីយ៉ូ អេ.ហៃលគ្រេស**

# ប្រវត្តិរូបសង្ខេបរបស់
## បុគ្គលសំខាន់ៗ

### ហូ នឹម* (ឆ្នាំ១៩៣០ - ឆ្នាំ១៩៧៧)

ហូ នឹម កើតនៅក្នុងគ្រួសារកសិករក្រីក្រដែលគ្មានដីជាកម្មសិទ្ធិឡើយ។ ហូ នឹម ទទួលបានការសិក្សាអប់រំនៅក្នុងខេត្តកំពង់ចាម និងទីក្រុងភ្នំពេញ។ ហូ នឹម ត្រូវជ្រើសតាំងជាសភាតំណាងរាស្ត្រនៅក្នុងឆ្នាំ១៩៦១ និងត្រូវជ្រើសតាំងជាថ្មីម្តងទៀតនៅក្នុងឆ្នាំ១៩៦៦។ នាឆ្នាំ១៩៦៧ ហូ នឹម បានរត់ភៀសខ្លួនទៅក្នុងព្រៃ។ បន្ទាប់មកនៅក្នុងឆ្នាំ ១៩៧៥ ហូ នឹម ត្រូវបានតែងតាំងជារដ្ឋមន្ត្រីក្រសួងព័ត៌មាននៃរបបកម្ពុជាប្រជាធិបតេយ្យ។ ហូ នឹម ត្រូវបានសម្លាប់នៅក្នុងខែមេសា ឆ្នាំ១៩៧៧។

### ហ៊ូ យន់ (១៩៣០ - ១៩៧៥)

ហ៊ូ យន់ កើតនៅក្នុងខេត្តកំពង់ចាម។ ហ៊ូ យន់ បានសិក្សារៀនសូត្រនៅក្នុងប្រទេសបារាំង និងបានចូលរួមជាមួយនិស្សិតម៉ាក្សនិយមនៅទីនោះ។ ហ៊ូ យន់ បានបម្រើការងារក្នុងតួនាទីជារដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្មនៅក្នុងឆ្នាំ១៩៥៨ ជាមន្ត្រីជាន់ខ្ពស់មួយរូបនៅក្រសួងផែនការនៅឆ្នាំ១៩៥៩ បម្រើការងារនៅក្រសួងសុខាភិបាលពីឆ្នាំ១៩៥៩ ដល់ឆ្នាំ១៩៦០ ហើយបានធ្វើការងារនៅក្នុងក្រសួងហិរញ្ញវត្ថុនៅឆ្នាំ១៩៦២ និងបំពេញមុខងារនៅក្នុងក្រសួងផែនការនៅអំឡុងឆ្នាំ១៩៦២ ដល់ឆ្នាំ១៩៦៣។ ហ៊ូ យន់ ត្រូវបានជ្រើសតាំងជាសភាតំណាងរាស្ត្រនៅឆ្នាំ១៩៦៦ និងបន្ទាប់មកភៀសខ្លួនទៅក្នុងព្រៃនៅឆ្នាំ១៩៦៧។ ក្នុងឆ្នាំ១៩៧១ ហ៊ូ យន់ ត្រូវបានតែងតាំងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ហ៊ូ យន់ ត្រូវបានសម្លាប់នៅខែសីហា ឆ្នាំ ១៩៧៥។

### អៀង សារី (ឆ្នាំ១៩៣០ - ឆ្នាំ២០១៣)

អៀង សារី កើតក្នុងគ្រួសារខ្មែរកាត់ចិនមួយ នៅក្នុងខេត្តត្រាវិញ ប្រទេសវៀតណាមខាងត្បូង។ អៀង សារី គឺជាសមាជិកនៃក្រុមម៉ាក្សនិយមនៅប្រទេសបារាំងក្នុងឆ្នាំ១៩៥០ និង ជាគ្រូបង្រៀនប្រវត្តិវិទ្យា និងភូមិវិទ្យានៅទីក្រុងភ្នំពេញ។ អៀង សារី ត្រូវជ្រើសតាំងជាគណៈកម្មាធិការមជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជានៅឆ្នាំ១៩៦៣ និងបានរត់ភៀសខ្លួនទៅក្នុងព្រៃក្នុងឆ្នាំដដែល។ អៀង សារី កាន់មុខតំណែងផ្លូវការជាបេសកជនពិសេសរបស់ ប៉ុល ពត ដោយចាប់ផ្តើមតួនាទីដំបូង នៅក្នុងទីក្រុងហាណូយ និងបន្ទាប់មកនៅទីក្រុងប៉េកាំង។ អៀង សារី គឺជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ។

### ខៀវ សំផន (ឆ្នាំ១៩៣១ - )

ខៀវ សំផន ទទួលបានការសិក្សានៅប្រទេសបារាំងក្នុងឆ្នាំ១៩៥០។ ខៀវ សំផន ត្រូវបានជ្រើសតាំងជាសភាតំណាងរាស្ត្រនៅឆ្នាំ១៩៦២ និងត្រូវជ្រើសតាំងជាថ្មីម្តងទៀតនៅឆ្នាំ១៩៦៦។ ក្នុងឆ្នាំ១៩៦៧ ខៀវ សំផន បានគេចខ្លួនចូលទៅក្នុងព្រៃ។ ខៀវ សំផន ត្រូវបានតែងតាំងជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ ព្រមទាំងជាអគ្គមេបញ្ជាការកងទ័ពរំដោះជាតិក្នុងឆ្នាំ១៩៧៣។ ខៀវ សំផន ទទួលបានការតែងតាំងជាប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យនៅឆ្នាំ១៩៧៦។

*កំណត់សម្គាល់៖ នេះគឺជា ការប្រកបឈ្មោះ ហូ នឹម យោងតាម រូបភាពព័ត៌មានផ្សាយចេញពីក្រសួងឃោសនាការជាតិ លេខ៣៧ ចេញផ្សាយ ថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩៦០ (ប្រភព៖ បណ្ណសារដ្ឋានជាតិកម្ពុជា)

## ខៀវ ប៉ុណ្ណារី (ភរិយារបស់ សាឡុត ស ហៅ ប៉ុល ពត) (១៩២០ - ២០០៣)

ខៀវ ប៉ុណ្ណារី មានស្រុកកំណើតនៅខេត្តបាត់ដំបង និងមានឪពុកធ្វើជាចៅក្រម។ ខៀវ ប៉ុណ្ណារី រៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិក្នុងទីក្រុងភ្នំពេញ ហើយបន្ទាប់មកបានបន្តការសិក្សានៅប្រទេសបារាំង។ ខៀវ ប៉ុណ្ណារី គឺជាស្ត្រីខ្មែរដំបូងបង្អស់ ដែលទទួលបានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិពីប្រទេសបារាំង។ នៅក្នុងឆ្នាំ ១៩៥១ ខៀវ ប៉ុណ្ណារី បានវិលត្រឡប់មកកាន់ប្រទេសកម្ពុជាវិញ ហើយបានចាប់ផ្ដើមសរសេរទស្សនាវដ្ដីសម្រាប់ស្ត្រីដែលមានឈ្មោះថា “នារី”។ ខៀវ ប៉ុណ្ណារី បានរៀបការជាមួយ សាឡុត ស (ហៅ ប៉ុល ពត) នៅក្នុងឆ្នាំ ១៩៥៦។ នាឆ្នាំ ១៩៦១ ខៀវ ប៉ុណ្ណារី បានបង្កើតសហភាពស្ត្រីកម្ពុជា (គឺជារណសិរ្សកុម្មុយនីស្តទ្រង់ទ្រាយធំមួយ) ប៉ុន្តែមិនបានប្រកាសអំពីវត្តមានរបស់ខ្លួនទេ។ ខៀវ ប៉ុណ្ណារី បានភៀសខ្លួនចូលទៅក្នុងព្រៃនាឆ្នាំ១៩៦៥ បាត់វត្តមានរហូតដល់ឆ្នាំ១៩៧៣។

## កុយ ធួន (១៩៣៣ - ១៩៧៧)

មានព័ត៌មានតិចតួចណាស់អំពី កុយ ធួន។ នៅឆ្នាំ១៩៥៩ កុយ ធួន គឺជាអ្នកយកព័ត៌មានឱ្យកាសែតឡុបស៊ែរវ៉ាក់ទ័រនៅទីក្រុងភ្នំពេញ។ បន្ទាប់ពីភៀសខ្លួនទៅក្នុងព្រៃកាលពីឆ្នាំ១៩៦៤ កុយ ធួន បានក្លាយជាលេខាបក្សប្រចាំភូមិភាគឧត្តរដែលមានមូលដ្ឋាននៅតំបន់៣២ (ខេត្តកំពង់ធំ)។ នៅឆ្នាំ១៩៧៣ កុយ ធួន ត្រូវតែងតាំងជាអ្នកគ្រប់គ្រងតំបន់ ៣០៤ ដែលមានមូលដ្ឋាននៅខេត្តសៀមរាប។ កុយ ធួន ទទួលបន្ទុកជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនៅឆ្នាំ១៩៧៦ ហើយត្រូវបានសម្លាប់នៅខែមករា ឆ្នាំ១៩៧៧។

## លន់ នល់ (ឆ្នាំ១៩១៣ - ឆ្នាំ១៩៨៥)

លន់ នល់ គឺជារដ្ឋមន្ត្រីការពារជាតិ និងជាអគ្គសេនាធិការ (ពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៦៦) ជាមេបញ្ជាការកងយោធពលខេមរភូមិន្ទក្នុងឆ្នាំ១៩៦០ ព្រមទាំងកាន់តួនាទីជានាយករដ្ឋមន្ត្រីជាច្រើនលើកពោលគឺនៅក្នុងឆ្នាំ១៩៦៣ ពីឆ្នាំ១៩៦៦ ដល់ឆ្នាំ១៩៦៧ និងពីឆ្នាំ១៩៦៩ដល់ឆ្នាំ១៩៧៣ បន្ទាប់មក លន់ នល់ បានក្លាយជាប្រធានាធិបតីនៃសាធារណរដ្ឋខ្មែរចាប់ពីឆ្នាំ១៩៧២ដល់ឆ្នាំ១៩៧៥ និងជាមេដឹកនាំរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។

## សម្ដេចព្រះ នរោត្តម សីហនុ ព្រះវររាជបិតាជាតិខ្មែរ (ឆ្នាំ១៩២២ - ឆ្នាំ២០១២)

សម្ដេចព្រះ នរោត្តម សីហនុ ទ្រង់សោយរាជ្យជាព្រះមហាក្សត្រកម្ពុជានៅក្នុងឆ្នាំ១៩៤១ ហើយទ្រង់បានដាក់រាជ្យនៅឆ្នាំ១៩៥៥។ សម្ដេចព្រះ នរោត្តម សីហនុ ជាប់ឆ្នោតជាប្រមុខរដ្ឋនៅឆ្នាំ ១៩៦០ និងត្រូវបានធ្វើរដ្ឋប្រហារទម្លាក់ពីតំណែងនៅឆ្នាំ១៩៧០។ នៅក្នុងឆ្នាំ១៩៧០ សម្ដេចព្រះ នរោត្តម សីហនុ បានបង្កើតរណសិរ្សរួបរួមជាតិកម្ពុជាមួយនៅទីក្រុងប៉េកាំង។ សម្ដេចគឺជាព្រះប្រមុខរដ្ឋនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាដែលត្រូវបង្កើតឡើងនៅទីក្រុងប៉េកាំងនាខែឧសភា ឆ្នាំ១៩៧០។ នៅក្នុងខែមីនា ឆ្នាំ១៩៧៦ សម្ដេចបានលាលែងពីតំណែងជាប្រមុខរដ្ឋ។ បន្ទាប់មក នៅខែមិថុនា ឆ្នាំ១៩៨២ ដល់ខែកក្កដា ឆ្នាំ១៩៩០ សម្ដេច គឺជាប្រធានាធិបតីនៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ និងជាប្រធានឧត្តមក្រុមប្រឹក្សាជាតិនៃកម្ពុជាពីខែមិថុនា ឆ្នាំ១៩៩១ ដល់ខែកញ្ញា ឆ្នាំ១៩៩៣។ សម្ដេចព្រះ នរោត្តម សីហនុ បានឡើងសោយរាជ្យជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាឡើងវិញ នៅខែកញ្ញា ឆ្នាំ១៩៩៣។

## ព្រះអង្គម្ចាស់ នរោត្តម ភូរីស្សរ៉ា (ឆ្នាំ១៩១៩ - ឆ្នាំ១៩៧៦)

ព្រះអង្គម្ចាស់ នរោត្តម ភូរីស្សរ៉ា បានប្រសូតនៅទីក្រុងភ្នំពេញ។ ទ្រង់បានទទួលការសិក្សានៅ ទីក្រុងភ្នំពេញ និងបញ្ចប់ការសិក្សា ពីមហាវិទ្យាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញនៅឆ្នាំ១៩៥៨។ ព្រះអង្គម្ចាស់ នរោត្តម ភូរីស្សរ៉ា ទ្រង់បំពេញមុខតំណែងបន្តបន្ទាប់នៅក្នុងជួររដ្ឋាភិបាលកម្ពុជា ក្នុងឋានៈជារដ្ឋលេខាធិការ និងជារដ្ឋមន្ត្រីព្រមទាំងរដ្ឋមន្ត្រីការបរទេស។ ព្រះអង្គម្ចាស់ នរោត្តម ភូរីស្សរ៉ា បានចូលរួមជាមួយរណសិរ្សរួបរួមជាតិកម្ពុជាក្នុងឆ្នាំ១៩៧២ និងត្រូវបានជ្រើសតាំងជាប្រធានគណៈកម្មាធិការរណសិរ្សរួបរួមជាតិកម្ពុជាប្រចាំទីក្រុងភ្នំពេញ ហើយបន្ទាប់មក ទ្រង់គឺជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌នៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ នៅពេលចុងក្រោយបង្អស់ដែលគេដឹងថា ព្រះអង្គម្ចាស់ នរោត្តម ភូរីស្សរ៉ា នៅមានព្រះជន្ម គឺនៅក្នុងឆ្នាំ១៩៧៦។

## ប៉ែន នុត (ឆ្នាំ១៩០៦ - ឆ្នាំ១៩៨៥)

ប៉ែន នុត គឺជាទីប្រឹក្សាជំនិតរបស់សម្តេចព្រះនរោត្តម សីហនុ។ ប៉ែន នុត កាន់តំណែងជា នាយករដ្ឋមន្ត្រីកម្ពុជា ជាច្រើនដងនៅចន្លោះឆ្នាំ១៩៤៨ និងឆ្នាំ១៩៦៩។ ក្រោយមកទៀត ប៉ែន នុត គឺជានាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។

## សាឡុត ស (ហៅ ប៉ុល ពត) (ឆ្នាំ១៩២៨ - ឆ្នាំ១៩៩៨)

សាឡុត ស បានកើតនៅក្នុងខេត្តកំពង់ធំ។ សាឡុត ស ទទួលបានការអប់រំនៅទីក្រុងភ្នំពេញ និងប្រទេសបារាំង ហើយបានចូលរួមជាមួយក្រុមម៉ាក្សនិយមនៅទីក្រុងប៉ារីសកាលពីឆ្នាំ១៩៥០។ សាឡុត ស បានវិលត្រឡប់មកប្រទេសកម្ពុជាវិញនៅឆ្នាំ១៩៥៣ និងបានភៀសខ្លួនទៅក្នុងព្រៃនៅឆ្នាំ១៩៦៣។ សាឡុត ស ត្រូវបានតែងតាំងជាលេខាបក្សកុម្មុយនីស្តភូមិភាគឦសាននៅឆ្នាំ ១៩៦៨ និងក្រោយមកបានធ្វើដំណើរដោយសម្ងាត់ទៅកាន់ទីក្រុងប៉េកាំងក្នុងឆ្នាំ១៩៧០។ សាឡុត ស គឺជានាយករដ្ឋមន្ត្រីនៃរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងឆ្នាំ១៩៧៦។ នៅក្នុងខែកញ្ញា ឆ្នាំ១៩៧៩ សាឡុត ស បានចុះចេញពីតំណែងជានាយករដ្ឋមន្ត្រីមួយរយៈខ្លី ហើយបន្ទាប់មកបន្តកាន់តំណែងជានាយករដ្ឋមន្ត្រីចាប់ពីខែតុលា ឆ្នាំ១៩៧៩ រហូតដល់ខែមិថុនា ឆ្នាំ១៩៨២។ សាឡុត ស បន្តកាន់តំណែងជាអគ្គលេខាធិការ គណបក្សកុម្មុយនីស្តកម្ពុជា រហូតដល់ទទួលមរណភាពនៅឆ្នាំ១៩៩៨ (សង្ស័យថាត្រូវបានបំពុលសម្លាប់)។

## សុន សេន (ឆ្នាំ១៩៣០ - ឆ្នាំ១៩៩៧)

សុន សេន កើតនៅខេត្តត្រាវិញ ក្នុងប្រទេសវៀតណាមខាងត្បូង។ សុន សេន បានទទួលការអប់រំនៅសាលាគរុកោសល្យក្នុងទីក្រុងភ្នំពេញនៅឆ្នាំ១៩៤៦។ សុន សេន បានទៅរៀនបន្តនៅប្រទេសបារាំងក្នុងឆ្នាំ១៩៥០ និងបន្ទាប់មកវិលត្រឡប់កាន់តំណែងជានាយកផ្នែកសិក្សានៃ សាលាគរុកោសល្យនៅឆ្នាំ១៩៥៦វិញ។ សុន សេន បានទស្សនកិច្ចប្រទេស ឆេកូស្លូវ៉ាគីនៅឆ្នាំ ១៩៥៩ និងបានចូលរួមជាមួយបក្សកុម្មុយនីស្តនៅឆ្នាំ១៩៦០។ សុន សេន បានភៀសខ្លួនទៅក្នុងព្រៃនៅឆ្នាំ១៩៦៤ ហើយបន្ទាប់មក ត្រូវបានតែងតាំងជាមេបញ្ជាការនៃកងទ័ពរំដោះជាតិ។ សុន សេន ត្រូវបានតែងតាំងជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ក្រសួងការពារជាតិនៃរបបកម្ពុជាប្រជាធិបតេយ្យនៅឆ្នាំ១៩៧៦។ សុន សេន ត្រូវបានធ្វើឃាតតាមបញ្ជារបស់ ប៉ុល ពត នៅខែមិថុនា ឆ្នាំ១៩៩៧។

## ព្រះអង្គម្ចាស់ សុផានុវង្ស (ឆ្នាំ១៩០៩-ឆ្នាំ១៩៩៥)

ព្រះអង្គម្ចាស់ សុផានុវង្ស គឺជាព្រះអនុជដែលមានមាតាទីទៃរបស់អតីតនាយករដ្ឋមន្ត្រីប្រទេសឡាវគឺព្រះអង្គម្ចាស់ ស៊ូវណ្ណា ភូម៉ា។ ទោះបីជាព្រះអង្គគឺជាសមាជិកនៃគ្រួសាររាជវង្សឡាវក៏ដោយ ទ្រង់គឺជាជនស្នេហាជាតិដ៏សកម្ម និងបានប្រយុទ្ធជាមួយបារាំងក្នុងនាមជាសមាជិកគាំទ្របក្សកុម្មុយនីស្តប៉ះថេតឡាវ។ ព្រះអង្គបានចូលរួមជាមួយរដ្ឋាភិបាលរួបរួមជាតិឡាវបន្ទាប់ពីប្រទេសទទួលបានឯករាជ្យ ប៉ុន្តែទ្រង់ត្រូវបានចាប់ព្រះកាយបន្ទាប់ពីក្រុមស្តាំនិយមបានឡើងកាន់អំណាចនៅឆ្នាំ១៩៥៩។ ព្រះអង្គ ម្ចាស់ សុផានុវង្ស គឺជាប្រតិភូប៉ះថេតឡាវនៅក្នុងសន្និសីទទីក្រុងហ្សឺណែវស្តីពីឡាវ (ឆ្នាំ១៩៦១-ឆ្នាំ១៩៦២) ហើយបានក្លាយជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងផែនការសេដ្ឋកិច្ចនៃរដ្ឋាភិបាលរួបរួមដែលបានបង្កើតឡើងនាពេលនោះ។ ព្រះអង្គម្ចាស់ សុផានុវង្ស បានចូលរួមក្នុងចលនាតស៊ូក្នុងព្រៃនៅឆ្នាំ១៩៦៣ បន្ទាប់ពីរដ្ឋាភិបាលរួបរួមបានទទួលបរាជ័យ។ ព្រះអង្គម្ចាស់ សុផានុវង្ស បានក្លាយជាទីប្រឹក្សាជាន់ខ្ពស់នៃរដ្ឋាភិបាលរួបរួមឡាវថ្មីមួយទៀតដែលបង្កើតឡើងនៅឆ្នាំ១៩៧៤។ នៅឆ្នាំ១៩៧៥ ព្រះអង្គម្ចាស់ សុផានុវង្ស ត្រូវតែងតាំងជាប្រធានាធិបតីនៃសាធារណរដ្ឋ ប្រជាធិបតេយ្យប្រជាមានិតឡាវដែលទើបបង្កើតថ្មី។ ក្រោយមកទ្រង់ បានលាលែងពីតំណែងនិងចូលនិវត្តន៍នៅឆ្នាំ ១៩៨៦ ហើយបានសោយទិវង្គតនៅឆ្នាំ ១៩៩៥។

## វ៉ូ ង្វៀនយ៉ាប (ឆ្នាំ១៩១១ - ឆ្នាំ២០១៣)

វ៉ូ ង្វៀនយ៉ាប គឺជាឧត្តមសេនីយ៍វៀតណាមម្នាក់កើតនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩១១។ វ៉ូ ង្វៀនយ៉ាប មិនបានទទួលការអប់រំផ្លូវការទេ ប៉ុន្តែបានទទួលការបណ្តុះបណ្តាលផ្នែកយោធា រហូតក្លាយជាឧត្តមសេនីយ៍ឈានមុខដែលដឹកនាំកងទ័ពវៀតណាមខាងជើង។ វ៉ូ ង្វៀនយ៉ាប បានរៀបចំផែនការ និងដឹកនាំប្រតិបត្តិការយោធាប្រឆាំងនឹងបារាំងដែលធ្វើឱ្យកងទ័ពបារាំងបរាជ័យនៅឯសមរភូមិដៀនបៀនហ្វូក្នុងឆ្នាំ១៩៥៤។ ក្នុងអំឡុងឆ្នាំ១៩៦០ វ៉ូ ង្វៀនយ៉ាប បានគ្រប់គ្រងលើប្រតិបត្តិការទ័ពព្រៃដើម្បីប្រយុទ្ធប្រឆាំងជាមួយវៀតណាមខាងត្បូង និងកងកម្លាំងអាមេរិកដែលបោះទីតាំងនៅប្រទេសវៀតណាមខាងត្បូង។ វ៉ូ ង្វៀនយ៉ាប បានរៀបចំប្រតិបត្តិការវាយលុក តេត (តេត គឺជាឈ្មោះនៃពិធីបុណ្យចូលឆ្នាំរបស់ជនជាតិវៀតណាម) នៅឆ្នាំ១៩៦៨ និងការវាយលុកចុងក្រោយប្រឆាំងនឹងរដ្ឋាភិបាលសៃហ្គននៅចុងខែមេសា ឆ្នាំ ១៩៧៥។

## ជូ អេនឡាយ (ឆ្នាំ១៨៩៨ - ឆ្នាំ១៩៧៦)

ជូ អេនឡាយ គឺជារដ្ឋបុរសចិន ដែលបានទទួលការអប់រំនៅក្នុងប្រទេសបារាំង និងបន្ទាប់មកចូលរួមជាមួយបក្សកុម្មុយនីស្តចិននៅឆ្នាំ១៩២១។ ជូ អេនឡាយ បានក្លាយជានាយករដ្ឋមន្ត្រីទីមួយរបស់សាធារណរដ្ឋប្រជាមានិតចិនពីឆ្នាំ១៩៤៩ ដល់ឆ្នាំ១៩៧៦។ ជូ អេនឡាយ គឺជាបុគ្គលប្រកបដោយប្រាជ្ញាម្នាក់ ដែលយល់ច្បាស់អំពីព្រះរាជសកម្មភាពរបស់សម្តេចព្រះ នរោត្តម សីហនុ ហើយយល់យ៉ាងច្បាស់ថាប្រទេសកម្ពុជាមិនអាចប្រែក្លាយទៅជាប្រទេសដែលប្រកាន់យកលទ្ធិកុម្មុយនីស្តភ្លាមៗក្នុងរយៈពេលដ៏ខ្លីមួយបាននោះទេ។

# សេចក្ដីផ្ដើម

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ឧត្តមសេនីយ៍ លន់ នល់ បានធ្វើរដ្ឋប្រហារផ្ដួលរំលំសម្ដេចព្រះ នរោត្តម សីហនុ ចេញពីតំណែងជាប្រមុខរដ្ឋកម្ពុជា។ ព្រឹត្តិការណ៍នេះ បានផ្លាស់ប្ដូរប្រទេសកម្ពុជាជារៀងរហូត ដែលការផ្លាស់ប្ដូរនេះគឺបានរុញច្រានប្រទេសឱ្យឈានទៅក្នុងស្ថានភាពកាន់តែលំបាកទៅៗ។ ប្រទេសដែលធ្លាប់តែមានសន្តិភាព សម្បូរសប្បាយសមរម្យ និងមានសុភមង្គល ត្រូវរុំព័ទ្ធជុំជិតទៅដោយភ្នក់ភ្លើងសង្គ្រាមដែលបានជះឥទ្ធិពលដល់ប្រទេសវៀតណាម និងសាយភាយឥទ្ធិពលទៅលើប្រទេសឡាវ។

នាពេលនោះ សម្ដេច នរោត្តម សីហនុ កំពុងចាប់ផ្ដើមព្រះរាជដំណើរទស្សនកិច្ចរបស់ទ្រង់ទៅកាន់សាធារណរដ្ឋប្រជាមានិតចិន ព្រះអង្គបានសម្រេចព្រះទ័យតបតប្រឆាំងនឹងសកម្មភាពរបស់ លន់ នល់ ហើយបានរាជាបង្កើតរណសិរ្សរួបរួមជាតិកម្ពុជានៅទីក្រុងប៉េកាំង នាថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ ដើម្បីរៀបចំការតស៊ូប្រឆាំង លន់ នល់ និងសហរដ្ឋអាមេរិកដែលជាអ្នកគាំទ្ររបប លន់ នល់។

រណសិរ្សរួបរួមជាតិកម្ពុជាទទួលស្វាគមន៍ប្រជានុរាស្ត្រកម្ពុជាទាំងអស់ដែលជំទាស់ទៅនឹងការធ្វើរដ្ឋប្រហាររបស់ លន់ នល់ ដោយមិនប្រកាន់អំពីពណ៌សម្បុរនយោបាយនោះឡើយ។ ក្រុមមួយនៅក្នុងចំណោមក្រុមដំបូងដែលបានទទួលស្គាល់ និងគាំទ្ររណសិរ្សរួបរួមជាតិកម្ពុជា គឺជាចលនាកុម្មុយនីស្ត (ខ្មែរក្រហម) មួយក្រុមតូច ដែលសម្ដេចព្រះ នរោត្តម សីហនុ បានគ្រប់គ្រងយ៉ាងតឹងរ៉ឹងក្រោមគោលនយោបាយរបស់ព្រះអង្គក្នុងទសវត្សរ៍ទី៥០ និង ៦០។[១]

សម្ដេច នរោត្តម សីហនុ ទ្រង់អាចសម្រេចកិច្ចការនេះបាន គឺដោយសារតែព្រះអង្គបានទទួលស្គាល់សាធារណរដ្ឋប្រជាមានិតចិន ព្រមទាំងរក្សាទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយបណ្ដាមេដឹកនាំចិន ជាពិសេសជាមួយមិត្តជិតដិតផ្ទាល់ព្រះកាយរបស់ទ្រង់ គឺនាយករដ្ឋមន្ត្រី ជូ អេនឡាយ ថ្វីត្បិតតែប្រទេសទាំងពីរមានបញ្ហារកាំរកូសខ្លះក្នុងអំឡុងពេលបដិវត្តវប្បធម៌នៅប្រទេសចិននាពាក់កណ្ដាលទសវត្សរ៍ឆ្នាំ១៩៦០ក៏ដោយ។ សម្ដេច នរោត្តម សីហនុ ព្រះអង្គយល់ថាចំណងមិត្តភាពជាមួយប្រទេសចិន គឺជាការធានាចំពោះសន្តិសុខប្រជាជាតិដ៏តូចមួយរបស់ព្រះអង្គ ដែលស្ថិតនៅកៀបចំកណ្ដាលប្រទេសជិតខាងដែលមានអំណាចខ្លាំងជាងខ្លួនគឺ ប្រទេសវៀតណាម និងប្រទេសថៃ។

ការគាំទ្ររបស់ប្រទេសចិនចំពោះសម្ដេច នរោត្តម សីហនុ ដែលបានចាប់ផ្ដើមឡើងតាំងពីទសវត្សរ៍ឆ្នាំ១៩៥០ មក បានកៀរគរទៅជាការវិនិយោគប្រកបដោយកិត្យានុភាពដ៏លេចធ្លោគួរឱ្យកត់សម្គាល់មួយ។ នេះបានបង្ហាញយ៉ាងជាក់ច្បាស់អំពីចំណាប់អារម្មណ៍ខុសស្រឡះពីគ្នារវាងប្រទេសវៀតណាម និងប្រទេសចិន មកលើប្រទេសកម្ពុជា ដោយមើលឃើញអំពីការមិនទុកចិត្តរបស់ប្រទេសកម្ពុជាជាយូរណាស់មកហើយចំពោះភាគីវៀតណាមទាំងអស់ ពោលគឺទាំងវៀតណាមខាងជើង និងខាងត្បូង។

---

១.ដកស្រង់ចេញពីសៀវភៅដែលជាព្រះរាជនិពន្ធរបស់សម្ដេច នរោត្តម សីហនុ មានចំណងជើងជាភាសាអង់គ្លេសថា The Cup to the Dregs បោះពុម្ពឯករាជ្យ ក្នុងឆ្នាំ១៩៨៥-១៩៨៧, ផ្នែកទី១, ជំពូកទី៦, ទំព័រ ១៦-៦២។

បន្ទាប់ពីរដ្ឋប្រហារនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ សម្តេច នរោត្តម សីហនុ បានបន្តគង់នៅ ក្នុងទីក្រុងប៉េកាំង ហើយប្រទេសចិនដែលជាម្ចាស់ផ្ទះបានទទួលស្វាគមន៍ និងបាត់ទុកព្រះអង្គ ជាភ្ញៀវកិត្តិយសដែលមានឋានៈខ្ពង់ខ្ពស់បំផុត។ ប្រទេសចិន បានពង្រីកការគាំទ្រ និងទទួលស្គាល់ផ្នែកការទូតចំពោះរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ថាជារដ្ឋាភិបាលស្របច្បាប់តែមួយគត់របស់ប្រទេសកម្ពុជា។[២]

ប្រទេសចិនបានដឹងយ៉ាងច្បាស់អំពីភាពលំបាក ក៏ដូចជា ការបំអកចំពោះការទទួលស្វាគមន៍សែស្រឡាយរាជវង្សនៅក្នុងរដ្ឋធានីនៃប្រទេសប្រកាន់របបសង្គមនិយមនេះ ក៏ប៉ុន្តែចិននៅតែបន្តបង្ហាញការគោរពតាមរយៈការផ្សព្វផ្សាយអំពីសេចក្តីថ្លែងការណ៍ និងព្រះរាជសាររបស់សម្តេច នរោត្តម សីហនុ ដល់ប្រជានុរាស្ត្រកម្ពុជា ដោយមិនបន្ថែមការអត្ថាធិប្បាយ ឬបង្ហាញអំពីការគាំទ្រជ្រុលពេកទៅលើរដ្ឋាភិបាលរួបរួមជាតិកម្ពុជានោះទេ។

នាយករដ្ឋមន្ត្រី ជូ អេនឡាយ បានពន្យល់អំពីគោលជំហររបស់ប្រទេសចិនទៅកាន់លោក បណ្ឌិត ហង់រី ឃីសស៊ីងជឺរ ទីប្រឹក្សាសន្តិសុខជាតិសហរដ្ឋអាមេរិកនៅក្នុងអំឡុងទស្សនកិច្ចរបស់លោកមកកាន់ប្រទេសចិនថា៖ “ដូចដែលលោកបានដឹង ហើយសម្តេច នរោត្តម សីហនុ ក៏បានដឹងដែរថា ប្រទេសចិនមិនមានបំណងប្រែក្លាយសម្តេច នរោត្តម សីហនុ ឱ្យទៅជានរណាម្នាក់ដែលត្រូវតែស្តាប់បង្គាប់ ប្រទេសចិននោះទេ។ ប្រសិនបើយើងធ្វើបែបនោះ គឺហាក់បីដូចជាបង្ហាញថា ប្រទេសចិន ធ្វើអន្តរាគមមកលើប្រទេសកម្ពុជា។ ទស្សនៈភាគច្រើនដែលសម្តេច នរោត្តម សីហនុ បានថ្លែងនៅក្នុងសារព័ត៌មានប្រជាជនរបស់ប្រទេសចិន គឺមិនមែនជាទស្សនៈរបស់ប្រទេសចិននោះទេ ពោលគឺយើងផ្តល់សេរីភាពពេញលេញជូនសម្តេច នរោត្ត សីហនុ ក្នុងការបញ្ចេញទស្សនៈឯករាជ្យ”។[៣]

ឥរិយាបថរបស់ប្រទេសចិនអាចត្រូវបានគេបកស្រាយថា គឺជាការគាំទ្របែបមិនក្តៅមិនត្រជាក់ដល់សម្តេច នរោត្តម សីហនុ ប៉ុន្តែជាក់ស្តែងអាកប្បកិរិយានេះបង្ហាញឱ្យឃើញអំពីគោលគំនិតប្រកបដោយ ហេតុផលរបស់ ជូ អេនឡាយ ព្រមទាំងបញ្ជាក់យ៉ាងច្បាស់ថារដ្ឋាភិបាលចិនមិនបានដាក់សម្ពាធទៅលើសម្តេច នរោត្តម សីហនុ ឱ្យដើរតាមលំអានគោលនយោបាយជាក់លាក់ណាមួយរបស់ប្រទេសចិនឡើយ។

ប៉ុន្តែ មេដឹកនាំចិនដែលជាមិត្តពិតប្រាកដរបស់សម្តេច នរោត្តម សីហនុ រូបនេះក៏អាចប៉ាន់ស្មានដឹងមុនអំពីការខកចិត្តរបស់សម្តេច ហើយក៏ប្រាប់អំពីសេចក្តីព្រួយបារម្ភរបស់ព្រះអង្គចំពោះភាពជ្រុលនិយមរបស់ខ្មែរក្រហមដែរ។ ជូ អេន ឡាយ បានប្រាប់ទៅកាន់ហង់រី ឃីសស៊ីងជឺរ ថាមិនអាចទៅរួចនោះទេ ដែលធ្វើឱ្យប្រទេសកម្ពុជាប្រែក្លាយទៅប្រកាន់យកលទ្ធិកុម្មុយនីស្តទាំងស្រុងនៅពេលនេះ។ ហើយប្រសិនបើការណ៍នេះត្រូវបានប៉ុនប៉ងមែន នោះបញ្ហាកាន់តែធ្ងន់ធ្ងរនឹងកើតមានឡើង”។[៤]

ដោយសារតែ ជូ អេនឡាយ មិនទទួលបានចម្លើយជាវិជ្ជមានអ្វីសោះពី ហង់រី ឃីសស៊ីងជឺរ នាយករដ្ឋមន្ត្រីចិនរូបនេះ បានអំពាវនាវម្តងហើយម្តងទៀត ទៅកាន់ប្រេសិតបរទេសនានាប្រចាំទីក្រុងប៉េកាំងអំពីជំហរអព្យាក្រឹតប្រទេសកម្ពុជា។ ស្ទីវិន ហ្វីតស៍ជីរ៉ល ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំនៅប្រទេសចិននាពេលនោះ បានរាយការណ៍ទៅ

២. ការបង្កើតរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាត្រូវបានប្រកាសនៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៧០។ ប្រទេសចិន វៀតណាម កូរ៉េខាងជើង និងប្រទេសមួយចំនួនទៀតបានធ្វើការទទួលស្គាល់ភ្លាមៗថាជារដ្ឋាភិបាលស្របច្បាប់របស់ប្រទេសកម្ពុជា។

៣-៤. កំណត់ហេតុអំពីកិច្ចសន្ទនារវាងនាយករដ្ឋមន្ត្រី ជូ អេនឡាយ និងបណ្ឌិត ហង់រី ឃីសស៊ីងជឺរ, នៅសាលមហាស្រពប្រជាជន ក្នុងទីក្រុងប៉េកាំង, នាថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ១៩៧៣ពីម៉ោង ២ និង ៤៣ នាទីរសៀលដល់ម៉ោង ៧ និង ១៥ នាទីល្ងាច។ បណ្ណសាររបស់ប្រធាននាយកដ្ឋានផែនការគោល, ឆ្នាំ ១៩៦៩-១៩៧៧ ប្រអប់លេខ ៣៧១, កិច្ចសន្ទនា របស់លេខាធិការនៅទីក្រុងប៉េកាំង។ ខែកុម្ភៈ ឆ្នាំ១៩៧៣ នាយកដ្ឋានតម្កល់និងគ្រប់គ្រងបណ្ណសារជាតិ។

ទីក្រុងកង់បេរ៉ាថា លោកត្រូវបាននាយករដ្ឋមន្ត្រី ជូ អេនឡាយ អញ្ជើញឱ្យទៅប្រជុំនៅយប់ថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៧៣។ នៅក្នុងកិច្ចប្រជុំនោះ ជូ អេនឡាយ បានអំពាវនាវជាថ្មីម្តងទៀតឱ្យប្រទេសកម្ពុជារក្សាអព្យាក្រឹតភាពរបស់ខ្លួន ហើយប្រទេសមហាអំណាចបរទេសដទៃទៀតគួរគោរពតាមគោលការណ៍របស់ប្រទេសកម្ពុជា។ "ប្រទេសកម្ពុជាអាចប្រកាន់យកអព្យាក្រឹតភាព ហើយប្រសិនបើសម្តេច នរោត្តម សីហនុ ធ្វើមាតុភូមិនិវត្តន៍ទៅប្រទេសកម្ពុជាវិញ ទោះបីជាយ៉ាងណាក្តី ក៏នៅតែមិនអាចប្រែក្លាយទៅជាប្រទេសកុម្មុយនីស្តទាំងស្រុងបានដែរ"។[៥]

សេចក្តីអំពាវនាវនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ របស់សម្តេច នរោត្តម សីហនុ គឺមិនមែនថ្លែងទៅកាន់ក្រុមកុម្មុយនីស្តកម្ពុជានោះទេ ប៉ុន្តែថ្លែងចំពោះប្រជានុរាស្ត្រកម្ពុជាដែលគាំទ្រសម្តេចប្រឆាំងនឹង លន់ នល់។ សម្តេចមិនដែលអំពាវនាវទៅកាន់ក្រុមកុម្មុយនីស្តកម្ពុជាទាំងនៅមុនពេល និងក្រោយពេលបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា ហើយព្រះអង្គក៏មិនដែលទាក់ទងជាមួយក្រុមកុម្មុយនីស្តកម្ពុជាប្រចាំទីក្រុងប៉េកាំង ឬទីក្រុងហាណូយដែរ។

នៅឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ នៅក្នុងសុន្ទរកថាដែលបានផ្សាយតាមវិទ្យុភ្នំពេញ មេដឹកនាំខ្មែរក្រហម ប៉ុល ពត បានបញ្ជាក់ថាខ្លួននៅទីក្រុងប៉េកាំងនាថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ដែលជាថ្ងៃធ្វើរដ្ឋប្រហាររបស់ លន់ នល់ ទម្លាក់សម្តេច នរោត្តម សីហនុ ចេញពីតំណែង។ ប៉ុល ពត បាននិយាយថាខ្លួន បាន "ប្រឹក្សាយោបល់ជាមួយមេដឹកនាំចិនឱ្យណែនាំសម្តេច នរោត្តម សីហនុ ឱ្យប្រកាន់យកឥរិយាបថតឹងរ៉ឹងប្រឆាំងនឹងក្រុម លន់ នល់ ដោយធ្វើការប្រយុទ្ធរហូតដល់ទីបញ្ចប់ ដើម្បីប្រឆាំងនឹងអាយ៉ងរបស់ចក្រពត្តិនិយមអាមេរិក"។[៦]

នៅក្នុងសៀវភៅកំណត់ហេតុដែលមានចំណងជើងជាភាសាអង់គ្លេសថា "The Cup to the Dregs" សម្តេច នរោត្តម សីហនុ បានព្រះលិខិតថាសម្តេចមិនដែលឃើញស្រមោល ប៉ុល ពត នៅទីក្រុងប៉េកាំងនោះទេ។ សម្តេចសង្ស័យថា ប៉ុល ពត បានកុហកអំពីវត្តមានរបស់ខ្លួន ហើយសម្តេច បានបញ្ជាក់ទៀតថាថ្នាក់ដឹកនាំចិនមិនដែលបានឆ្លៀតឱកាសក្នុងការប្រឹក្សាយោបល់ជាមួយសម្តេច ដើម្បីបង្កើតជាយុទ្ធសាស្ត្រណាមួយសម្រាប់ប្រទេសចិននោះទេ។

សម្តេច នរោត្តម សីហនុ បានបន្ថែមទៀតថានៅមួយថ្ងៃមុនការបង្កើតជារាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា នាយករដ្ឋមន្ត្រី ជូ អេនឡាយ បានផ្តល់យោបល់ដល់បរិវាររបស់សម្តេចនៅទីក្រុងប៉េកាំងថា គួរតែកុំដាក់ឈ្មោះរដ្ឋាភិបាលថ្មីជា" រដ្ឋាភិបាលបដិវត្តន៍" ឬ" ប្រជាមានិត" ដូចដែលប្រជាជនកម្ពុជាខ្លះនៅប៉េកាំងគាំទ្រឱ្យដាក់។[៧]

នាយករដ្ឋមន្ត្រីចិនរូបនេះ យល់ឃើញថាមាគ៌ាដ៏ល្អបំផុតសម្រាប់ក្រុមអ្នកតស៊ូកម្ពុជា គឺការតស៊ូក្រោមក្របខ័ណ្ឌនៃភាពស្របច្បាប់ និងនិរន្តរភាព៖ ភាពស្របច្បាប់របស់សម្តេច នរោត្តម សីហនុ ក្នុងនាមជាប្រមុខរដ្ឋ និងការបន្តរាជានិយម ដែលជនក្បត់នៅភ្នំពេញបានធ្វើរដ្ឋប្រហារទម្លាក់ដោយមិនស្របច្បាប់។ គោលគំនិតរបស់ ជូ អេនឡាយ គឺថាប្រសិនបើរដ្ឋាភិបាលតស៊ូថ្មីមិនកំណត់អំពីទំនោររបស់ខ្លួនទៅរករាជានិយមនោះទេ គឺប្រៀបបាននឹងផ្តល់សិទ្ធិស្របច្បាប់ដល់រដ្ឋប្រហារ លន់ នល់ ហើយនឹងមានការបាត់បង់គោលការណ៍រដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជា។

ជូ អេនឡាយ បានស្នើសុំឱ្យរដ្ឋាភិបាលតស៊ូរក្សារដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្តល់ភាពស្របច្បាប់ និងភាពសមស្របតាមរដ្ឋធម្មនុញ្ញដល់រដ្ឋាភិបាលបង្កើតថ្មីនេះ។ ការប្រកាន់ខ្ជាប់នូវរដ្ឋធម្មនុញ្ញ និងប្រជាប្រិយភាពនៃការគាំទ្រយ៉ាងក្លៀវក្លារបស់សម្តេច នរោត្តម សីហនុ ពីសំណាក់ប្រជាជន គឺជាកម្លាំងចលករដ៏ខ្លាំងក្លា ដែលអាចប្រើប្រាស់ដើម្បីតស៊ូប្រឆាំងនឹង លន់ នល់។

៥. ស្ថានទូតអូស្ត្រាលីប្រចាំទីក្រុងប៉េកាំងផ្ញើទៅកាន់នាយកដ្ឋានការបរទេសនៅទីក្រុងកង់បេរ៉ា, ទូរលេខ ៣៣៦, នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៣ លេខរៀង អា១៨៣៨, និមិត្តសញ្ញាត្រួតពិនិត្យលេខ ៦៩៦/១/៥/៤, បណ្ណសារជាតិអូស្ត្រាលី, ទីក្រុងកង់បេរ៉ា។

៦. សុន្ទរកថារបស់ ប៉ុល ពត ដែលផ្សាយដោយវិទ្យុភ្នំពេញនៅខែកញ្ញា ឆ្នាំ១៩៧៧។

៧. សៀវភៅកំណត់ហេតុរបស់សម្តេច នរោត្តម សីហនុ មានចំណងជើងជាភាសាអង់គ្លេសថា "The Cup to the Dregs", ផ្នែកទី១, ជំពូកទី ៦, ទំព័រ ១៦-១៧។

មេដឹកនាំខ្មែរក្រហម មានទំនាក់ទំនងជាលក្ខណៈឯកជនជាមួយប្រទេសចិនដោយផ្ទាល់ ហើយបានចំណាយពេលជាច្រើនឆ្នាំ ដើម្បីធ្វើការតស៊ូនៅក្នុងព្រៃក្នុងប្រទេស។ មេដឹកនាំខ្មែរក្រហមបានសម្លឹងឃើញឱកាសដ៏វិសេសវិសាលពីរដ្ឋប្រហាររបស់ លន់ នល់ និងគោលនយោបាយរបស់សហរដ្ឋអាមេរិកនៅក្នុងប្រទេសកម្ពុជា ដែលបានបើកផ្លូវឱ្យខ្លួនអាចក្រសោបយកអំណាច ហើយបានប្រមូលផ្តុំគ្នាភ្លាមៗ ចូលរួមនៅក្នុងរណសិរ្ស ដែលសម្តេច នរោត្តម សីហនុ បានបង្កើតឡើងនៅក្នុងទីក្រុងប៉េកាំង។

ជាងនេះទៅទៀត មេដឹកនាំខ្មែរក្រហមបានប្រើប្រាស់ព្រះឆាយាលក្ខណ៍ជាទីសក្ការរបស់សម្តេច នរោត្តម សីហនុ ដើម្បីទាក់ទាញប្រជាជន កសិករ និងមន្ត្រីរដ្ឋាភិបាលឱ្យចូលរួមក្នុងបុព្វហេតុរបស់ខ្លួន។ សិស្សានុសិស្ស មន្ត្រី យោធា និងមន្ត្រីរាជការជាច្រើន បានលាលែងពីការងារ និងចាកចេញពីក្រុមគ្រួសាររបស់ខ្លួន ដើម្បីចូលរួមនៅក្នុង "តំបន់រំដោះ" នៃប្រទេសកម្ពុជាដែលបង្កើតឡើងដោយខ្មែរក្រហម ដោយជឿជាក់ថា ខ្លួនកំពុងប្រយុទ្ធដើម្បីទាមទារតំណែងជាព្រះប្រមុខរដ្ឋកម្ពុជាថ្វាយ សម្តេច នរោត្តម សីហនុ។

អ្នកជំនាញបរទេសសិក្សាស្រាវជ្រាវអំពីកម្ពុជាមួយចំនួន ដែលមានទស្សនៈប្រឆាំងនឹងសម្តេច នរោត្តម សីហនុ ជាយូរយារមកហើយនោះ បានអះអាងថា សម្តេច នរោត្តម សីហនុ បានប្រមូលផ្តុំចលនាខ្មែរក្រហមភ្លាមៗបន្ទាប់ពីរដ្ឋប្រហាររបស់ លន់ នល់។ តាមពិតទៅ នេះគឺជាទស្សនៈផ្ទុយស្រឡះពីការពិត។ ការអះអាងខាងលើនេះមានភាពប្រាសចាកពីការពិតដែលចលនាខ្មែរក្រហម មិនដែលធ្វើការគាំទ្រទៅលើការគ្រប់គ្រងរបស់ សម្តេច នរោត្តម សីហនុ នៅក្នុងប្រទេសកម្ពុជាម្តងណាឡើយ ហើយព្រមទាំងបានរៀបចំនូវសកម្មភាពបះបោរយ៉ាងសកម្មប្រឆាំងនឹងការគ្រប់គ្រងរបស់ សម្តេច នរោត្តម សីហនុ។

ចាប់តាំងពីពេលដែលព្រះអង្គសម្រេចព្រះទ័យប្រឆាំងនឹងរដ្ឋប្រហារ លន់ នល់ មក សម្តេច នរោត្តម សីហនុ យល់ឃើញថា ដើម្បីឱ្យរណសិរ្សតស៊ូរបស់សម្តេច ទទួលបានការជឿជាក់ និងការគាំទ្រទាំងក្នុងស្រុក និងជាអន្តរជាតិ សម្តេច និងរដ្ឋមន្ត្រីរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ត្រូវតែមានវត្តមាននៅលើទឹកដីកម្ពុជាជាជាងការរៀបចំឱ្យមានទីស្នាក់ការកណ្តាលនៃចលនាតស៊ូនេះនៅឯរដ្ឋធានីប្រទេសចិនដែលជាមិត្តមហាអំណាច។

មួយឆ្នាំបន្ទាប់ពីការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា មេដឹកនាំខ្មែរក្រហមបានដឹកនាំចលនាតស៊ូប្រឆាំង លន់ នល់ នៅក្នុងប្រទេសកម្ពុជា។ មេដឹកនាំខ្មែរក្រហមបានបន្តជំទាស់យ៉ាងខ្លាំងក្លា ប៉ុន្តែប្រកបដោយការគួរសមចំពោះព្រះរាជបំណងរបស់ សម្តេច នរោត្តម សីហនុ ស្តីពីការផ្ទេរទីស្នាក់ការកណ្តាលនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាពីទីក្រុងប៉េកាំងទៅកាន់ប្រទេសកម្ពុជា។[៨]

ជាដំបូង នៅក្នុងព្រះរាជកំណត់ហេតុរបស់ព្រះអង្គ សម្តេច នរោត្តម សីហនុ បានពន្យល់ថាតាមទស្សនៈរបស់ទ្រង់ មេដឹកនាំខ្មែរក្រហម ជំទាស់ចំពោះទៅនឹងការយាងត្រឡប់របស់សម្តេចមកកាន់ទឹកដីកម្ពុជាវិញដោយសារមូលហេតុមួយចំនួន។ ទីមួយគឺ ខ្មែរក្រហមត្រូវការកិត្តិនាម និងព្រះរាជសារជាញឹកញាប់របស់ ព្រះអង្គទៅកាន់ប្រជានុរាស្ត្រកម្ពុជាផ្សាយចេញពីទីក្រុងប៉េកាំង ដើម្បីទាក់ទាញព្រះសង្ឃ សិស្ស-និស្សិត កសិករ និងក្រុមដទៃទៀតឱ្យចូលរួមគាំទ្រចលនារបស់ខ្លួន (ដែលនៅមិនទាន់បង្ហាញអត្តសញ្ញាណថាជាបក្សកុម្មុយនីស្តកម្ពុជានៅឡើយ)។

ទីពីរគឺ មេដឹកនាំខ្មែរក្រហមបានប្រើប្រាស់ភាពស្របច្បាប់របស់សម្តេច នរោត្តម សីហនុ និងរបបរាជានិយម ដើម្បីតាំងខ្លួនថាជា "រដ្ឋាភិបាលស្របច្បាប់" របស់ប្រទេសកម្ពុជានៅលើឆាកអន្តរជាតិ ក្នុងចេតនាធ្វើឱ្យប្រទេសដែលមិនប្រកាន់លទ្ធិកុម្មុយនីស្ត និងមិនមានទំនោរឆ្វេងនិយម មានទំនុកចិត្តមកលើក្រុមរបស់ខ្លួន។ នៅក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមនឹងប្រើប្រាស់ភាពស្របច្បាប់នោះ ដើម្បីដណ្តើមអំណាចកាន់កាប់ទីក្រុងភ្នំពេញ។

---

៨. ព្រះរាជកំណត់ហេតុរបស់សម្តេច នរោត្តម សីហនុ មានចំណងជើងជាភាសាអង់គ្លេសថា "The Cup to the Dregs", ផ្នែកទី១, ជំពូកទី ២១, ទំព័រ ២-១០។

ទីបីគឺ ព្រះរាជវត្តមានរបស់សម្តេច នរោត្តម សីហនុ នៅលើទឹកដីកម្ពុជាអាចផ្លាស់ប្តូរមតិយល់ឃើញជាសាធារណៈរបស់ប្រជានុរាស្ត្រកម្ពុជាមួយផ្នែកធំឱ្យគាំទ្រ លន់ នល់ និងសម្ព័ន្ធមិត្តរបស់ លន់ នល់ ដោយសារតែភាពភ័យខ្លាចចំពោះបក្សកុម្មុយនីស្តខ្មែរ។

ទីបួនគឺ ព្រះរាជវត្តមានរបស់សម្តេច នរោត្តម សីហនុ ក្នុងឋានៈជាប្រមុខរដ្ឋប្រទេសកម្ពុជានឹងបញ្ចប់របប “សាធារណរដ្ឋ” បានយ៉ាងឆាប់រហ័ស។ ហេតុផលនេះ នឹងធ្វើឱ្យខូចផែនការរបស់ខ្មែរក្រហមដែលទាមទារឱ្យមានសង្គ្រាមយូរអង្វែង។ មានតែជម្លោះអូសបន្លាយប៉ុណ្ណោះ ដែលអាចធ្វើឱ្យខ្មែរក្រហមអាចបំបាក់ស្មារតីគាំទ្ររបបរាជានិយម និងការគាំទ្រចំពោះសម្តេច នរោត្តម សីហនុ របស់ប្រជានុរាស្ត្រកម្ពុជានៅតាមបណ្តាតំបន់ជនបទព្រមទាំងកម្ចាត់ អ្នកដែលស្មោះស្ម័គ្រចំពោះ សម្តេច នរោត្តម សីហនុ និងអ្នកមិនគាំទ្រលទ្ធិកុម្មុយនីស្តដទៃទៀត ដែលប្រឆាំងនឹងការឡើងកាន់អំណាចទាំងស្រុងរបស់ខ្មែរក្រហមបាន។

នៅទីក្រុងប៉េកាំង អ្នកការទូត និងអ្នកកាសែតបរទេសជាច្រើន បានចោទសួរទៅកាន់សម្តេច នរោត្តម សីហនុ ឥតឈប់ឈរ អំពីមូលហេតុដែលសម្តេចមិនផ្លាស់ទីស្នាក់ការកណ្តាលរបស់ខ្លួនមកកាន់ប្រទេសកម្ពុជាហើយដឹកនាំការតស៊ូពីទឹកដីប្រទេសកម្ពុជា។

សម្តេច នរោត្តម សីហនុ ជ្រាបថា ទ្រង់កំពុងគង់នៅក្នុងស្ថានភាពមួយដ៏លំបាក។ ប្រទេសជាច្រើនដែលបានគាំទ្រដល់ការតស៊ូរបស់ប្រជានុរាស្ត្រកម្ពុជាកាលពីដំបូងឡើយ មិនបានបន្តផ្តល់ការទទួលស្គាល់ការទូតចំពោះរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាទៀតទេ ឬបានឃ្លាតខ្លួនឆ្ងាយពីការតស៊ូរបស់ប្រទេសកម្ពុជា ដោយចាត់ទុកថាចលនានេះ គឺគ្រាន់តែជាចលនាអាយ៉ងរបស់ប្រទេសចិនដែលគ្មានអ្វីពាក់ព័ន្ធនឹងប្រជានុរាស្ត្រកម្ពុជាឡើយ។

នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧១ សម្តេច នរោត្តម សីហនុ បានផ្ញើទូរលេខមួយទៅកាន់ ខៀវ សំផន ដែលនាពេលនោះគាត់គឺជាឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងជាអ្នកគ្រប់គ្រងរដ្ឋាភិបាលនៅតំបន់រំដោះក្នុងប្រទេសកម្ពុជា។ នៅក្នុងទូរលេខនោះ សម្តេច នរោត្តម សីហនុ បានបញ្ជាក់អំពីគោលបំណងរបស់ព្រះអង្គក្នុងការធ្វើមាតុភូមិនិវត្តន៍ ឬយ៉ាងហោចណាស់យាងទស្សនកិច្ចទៅកាន់តំបន់រំដោះ។

ជាបឋម ទីមួយគឺ សម្តេច នរោត្តម សីហនុ បានពន្យល់នៅក្នុងទូរលេខនោះថាការដែលរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា អាចបង្ហាញរូបថតមួយចំនួន ដែលថតនៅតំបន់រំដោះ គឺពិតជាមានសារសំខាន់យ៉ាងក្រៃលែង។ នេះអាចបញ្ជាក់អំពីវត្តមានរបស់កងទ័ពប្រជានុរាស្ត្រកម្ពុជា ពោលគឺកងកម្លាំងកម្ពុជាយ៉ាងពិតប្រាកដមួយ ដែលបង្ហាញអំពីអំណាចពិតប្រាកដមួយរបស់ប្រជានុរាស្ត្រកម្ពុជារស់នៅក្នុងភូមិស្រុក និងតាមស្រែចម្ការរបស់ខ្លួននៅឯតំបន់ដែលត្រូវបានរំដោះថ្មីៗ។

ទីពីរគឺ សម្តេច នរោត្តម សីហនុ បានផ្តល់ជាសញ្ញាថា ការឃោសនារបស់សត្រូវប្រឆាំងនឹងចលនាតស៊ូបានធ្វើឱ្យខូចកេរ្តិ៍ឈ្មោះរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដោយលើកឡើងថាចលនាតស៊ូនេះ មិនមានលទ្ធភាពក្នុងការនាំយកប្រមុខរដ្ឋរបស់ខ្លួនគឺ សម្តេច នរោត្តម សីហនុ ពីទីក្រុងប៉េកាំងមកកាន់តំបន់រំដោះប្រទេសកម្ពុជាវិញនោះទេ!

ទីបីគឺ សម្តេចបានគូសបញ្ជាក់ថាកិច្ចការនយោបាយ និងការទូតនៅក្រៅប្រទេសកម្ពុជា មិនអាចរីកចម្រើនទៅមុខ និងមិនផ្តល់ជាផលប្រយោជន៍ដល់បុព្វហេតុនៃរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាឡើយ លុះត្រាតែចលនានេះអាចបង្ហាញទៅកាន់ពិភពលោកខាងក្រៅថា ខ្លួនមិនមែនជាអាយ៉ងរបស់ប្រទេសចិន ហើយពិតជាបានផ្សាភ្ជាប់ទំនាក់ទំនងយ៉ាងរឹងមាំជាមួយប្រជានុរាស្ត្រកម្ពុជាពិតប្រាកដមែន។

នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧១ ខៀវ សំផន បានឆ្លើយតបនឹងព្រះរាជសំណើរបស់ សម្តេច នរោត្តម សីហនុ ដោយបានលើកឡើងដូចខាងក្រោម (សម្រង់)៖

ទូរលេខរបស់សម្តេចប្រមុខរដ្ឋចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧១ បានមកដល់នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧១។ យើងខ្ញុំបានកោះប្រជុំសមាជិកនៃរណសិរ្សរួបរួមជាតិកម្ពុជាដែលឈរជើងនៅជួរមុខ និងនៅទូទាំងប្រទេសកម្ពុជាទាំងអស់ ដើម្បីពិចារណាលើសំណួរដែលសម្តេចបានលើកឡើង ដោយព្យាយាមធ្វើការវិភាគយ៉ាងល្អិតល្អន់អំពីស្ថានភាពនាពេលបច្ចុប្បន្ននេះ។

យើងខ្ញុំយល់ថាទាំងស្ថានភាពផ្នែកស្មារតី និងផ្នែកសម្ភារ ចលនាតស៊ូរបស់រណសិរ្សរួបរួមជាតិកម្ពុជានិងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជានៅក្រៅប្រទេសកម្ពុជាមានសភាពល្អបំផុតជាងទីណាៗទាំងអស់ ដោយអាចបង្កើតជាលទ្ធភាពក្នុងការកៀរគរកម្លាំងចូលរួមនៅក្នុងចលនាតស៊ូនៅក្នុងផ្ទៃប្រទេស តាមរយៈការផ្សព្វផ្សាយពីវិទ្យុប៉េកាំង ដែលជាមធ្យោបាយទំនាក់ទំនងជាមួយសារព័ត៌មាន និងកម្លាំងគាំទ្រផ្នែកនយោបាយជាបន្តបន្ទាប់នៅក្រៅប្រទេស។

យោងទៅតាមស្ថានភាពបច្ចុប្បន្ននៃចលនាតស៊ូរបស់យើង និងដើម្បីផលប្រយោជន៍របស់ប្រជាជន គឺជាការចាំបាច់ដែលសម្តេចប្រមុខរដ្ឋ និងសមាជិកស្ទួលជទៃៗទៀតនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាដែលតាំងទីនៅក្នុងទីក្រុងប៉េកាំងបន្តស្នាក់នៅទីនោះ។

ព្រះរាជវត្តមានរបស់សម្តេចប្រមុខរដ្ឋ និងសមាជិកស្ទួលជទៃៗទៀតរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា នៅក្នុងតំបន់រំដោះរបស់យើង នឹងជួយពង្រឹងចលនាតស៊ូរបស់យើងដោយគ្មានមន្ទិលសង្ស័យ។ យើងខ្ញុំទាំងអស់គ្នាទន្ទឹងរង់ចាំស្វាគមន៍ការយាងមកដល់របស់សម្តេចប្រមុខរដ្ឋយ៉ាងក្រៃលែង ក៏ប៉ុន្តែយើងខ្ញុំទាំងអស់គ្នាមានសេចក្តីព្រួយបារម្ភចំពោះសុវត្ថិភាពរបស់សម្តេច ជាពិសេសចំពោះការទម្លាក់គ្រាប់បែករបស់កងទ័ពជើងអាកាសអាមេរិកដែលប៉ុនប៉ងកម្ទេចកម្មាភិបាលដឹកនាំរបស់យើង។ គ្រាប់បែក បេ៥២ មិនស្ទាក់ស្ទើរក្នុងការកម្ទាត់មូលដ្ឋាន ឬតំបន់ដែលសង្ស័យថាជាទីស្នាក់អាស្រ័យរបស់យើងនោះទេ។[៩]

បេសកជនពិសេសរបស់ខ្មែរក្រហម អៀង សារី បានផ្តល់នូវអំណះអំណាងដូចគ្នាបន្ទាប់ពីធ្វើដំណើរទៅដល់ទីក្រុងប៉េកាំងនៅខែកញ្ញា ឆ្នាំ១៩៧១។ អៀង សារី បាននិយាយព្រមានអំពី "គ្រោះថ្នាក់ដល់អាយុជីវិត" ចំពោះការធ្វើដំណើរតាមផ្លូវលំហូជីមិញ ដែលជាផ្លូវតែមួយគត់ឆ្ពោះទៅកាន់ប្រទេសកម្ពុជា។ អៀង សារី ព្រមទាំងបានសង្កត់ធ្ងន់ និងអះអាងថាព្រះរាជជន្មាយុរបស់សម្តេច នរោត្តម សីហនុ "ដាច់ខាតត្រូវតែការពារមិនថាត្រូវលះបង់អ្វីក៏ដោយ"។[១០]

សម្តេច នរោត្តម សីហនុ ទ្រង់ព្រះលិខិតនៅក្នុងព្រះរាជកំណត់ហេតុថា ព្រះអង្គបានឆ្លើយតបទៅវិញ ដោយអនុលោមតាមកិច្ចព្រមព្រៀង រវាងសហរដ្ឋអាមេរិក និងវៀតណាមខាងជើងដែលទើបបុះហត្ថលេខារួចមក ដោយកំណត់ថាកងទ័ពជើងអាកាសសហរដ្ឋអាមេរិកបានបញ្ឈប់ការទម្លាក់គ្រាប់បែកលើផ្លូវលំហូជីមិញហើយ ហើយរដ្ឋាភិបាលទីក្រុងហាណូយបានយល់ព្រមទទួលខុសត្រូវក្នុងការជូនសម្តេចទៅកាន់តំបន់រំដោះនោះ។

អៀង សារី ដែលនៅពេលនោះបានបង្កើតសិទ្ធិអំណាចរបស់ខ្លួននៅក្នុងបណ្តាញចលនាតស៊ូកម្ពុជា ក្នុងទីក្រុងប៉េកាំង បានឆ្លើយតបថា ផ្លូវលំហូជីមិញគឺពោរពេញទៅដោយគ្រាប់បែកមិនទាន់ផ្ទុះ និងយុទ្ធភណ្ឌផ្សេងៗទៀត ព្រមទាំងបានបញ្ជាក់ថារដ្ឋាភិបាលហាណូយមិនអាចទទួលខុសត្រូវចំពោះគ្រោះថ្នាក់ដែលអាចកើតឡើងក្នុងអំឡុងពេលធ្វើដំណើរបាននោះទេ។

អៀង សារី បានបន្ថែមទៀតថា ជំនួសការដែលឱ្យ សម្តេច នរោត្តម សីហនុ យាងមកកាន់ ប្រទេសកម្ពុជា មេដឹកនាំចលនាតស៊ូកម្ពុជានឹងធ្វើដំណើរចូលគាល់ សម្តេច នរោត្តម សីហនុ នៅឯទីក្រុងហាណូយវិញ។ អៀង សារី អះអាងថា ប្រសិនបើមេដឹកនាំនៃចលនាតស៊ូ ជាអ្នករងគ្រោះដោយសារតែ គ្រាប់បែកអាមេរិកនោះចលនាតស៊ូរបស់កម្ពុជានឹងមិនត្រូវរងការខូចខាតឡើយ ពីព្រោះ សម្តេច នរោត្តម សីហនុ គង់នៅមានជីវិត។

សម្តេច នរោត្តម សីហនុ បានឆ្លើយតបទៅវិញថាគោលបំណងសំខាន់របស់ព្រះអង្គគឺមិនមែនគ្រាន់តែដើម្បី ជួបជាមួយនឹងមេដឹកនាំនយោបាយ ឬមេដឹកនាំយោធាណាដែលឈរជើងនៅតំបន់រំដោះនោះទេ។ ផ្ទុយទៅវិញ បញ្ហាចម្បងនោះគឺចលនាតស៊ូបានបាត់បង់នូវ

៩. សារទូរលេខរបស់ ខៀវ សំផន ផ្ញើជូន សម្តេច នរោត្តម សីហនុ ព្រះប្រមុខរដ្ឋ និងជាព្រះប្រធានរណសិរ្សរួបរួម ជាតិកម្ពុជា ថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧១។ ចម្លងជូនឯកអគ្គរាជទូត បណ្ឌិត ហ្វូលីយ៉ូ អេ. ហែលឡែស ដោយសម្តេច នរោត្តម សីហនុ។
១០. ដូចខាងលើ។

ភាពជឿជាក់ទាំងក្នុង និងក្រៅប្រទេសដោយសារតែសម្តេច នរោត្តម សីហនុ ក្នុងព្រះនាមជាព្រះប្រមុខរដ្ឋ និងជាព្រះប្រធាននៃរណសិរ្សរួបរួមជាតិកម្ពុជា មិនទទួលបានសិទ្ធិពីសំណាក់ថ្នាក់ដឹកនាំនៅខាងក្នុងប្រទេស សូម្បីតែការវិលមកជាន់លើទឹកដីកម្ពុជា។

ជាចុងក្រោយ សម្តេច នរោត្តម សីហនុ បានព្រមានមេដឹកនាំខ្មែរក្រហម និងថ្នាក់ដឹកនាំនៅទីក្រុងប៉េកាំង និងទីក្រុងហាណូយថាសម្តេចនឹងលាលែងពីតំណែងជាប្រមុខរដ្ឋ និងជាប្រធាននៃរណសិរ្សរួបរួមជាតិកម្ពុជា ប្រសិនបើព្រះអង្គមិនអាចធ្វើដំណើរទៅកាន់ប្រទេសកម្ពុជា សូម្បីតែក្នុងរយៈពេលខ្លីមួយប៉ុណ្ណោះនោះ។ លើសពីនេះ សម្តេចក៏បានគំរាមនឹងមិនចូលរួមនៅក្នុងកិច្ចប្រជុំកំពូលនៃចលនាមិនចូលបក្សសម្ព័ន្ធនៅប្រទេសអាល់ហ្សេរី នាពេលខាងមុខទៀតផងដែរ។

ការគំរាមកំហែងដាច់អហង្ការនេះបានបញ្ចប់នូវរាល់ការរារាំងរបស់ អៀង សារី ខៀវ សំផន និងបុគ្គលដទៃទៀត។ បុគ្គលទាំងនេះ បានយល់ព្រមឱ្យសម្តេចយាងមាតុភូមិនិវត្តន៍នៅខែមីនា ឆ្នាំ១៩៧៣ ប៉ុន្តែព្រះរាជដំណើរនេះមានរយៈពេលត្រឹមតែមួយខែប៉ុណ្ណោះ។

សម្តេច នរោត្តម សីហនុ និងព្រះជាយាបានយាងពីទីក្រុងប៉េកាំង ទៅកាន់ទីក្រុងហាណូយតាមរយៈយន្តហោះ ហើយបន្ទាប់មក ព្រះអង្គទាំងពីរយាងដំណើរតាមបណ្តោយផ្លូវលំហូជីមិញ ឆ្លងកាត់ទឹកដីប្រទេសឡាវ ហើយឈានចូលមកដល់ខេត្តស្ទឹងត្រែងស្ថិតនៅភាគខាងជើងនៃប្រទេសកម្ពុជា។

ក្នុងអំឡុងព្រះរាជដំណើរទ្រង់ទាំងពីរព្រះអង្គ បានជួបជាមួយមេដឹកនាំសំខាន់ៗនៃចលនាតស៊ូនៅក្នុងប្រទេស។ ព្រះអង្គ បានជួបជាមួយនឹង សាឡុត ស (ប៉ុល ពត) ដែលនៅពេលនោះមិនទាន់បង្ហាញសមាសភាពពិតរបស់ខ្លួននៅក្នុងឋានានុក្រមកុម្មុយនីស្តកម្ពុជានៅឡើយទេ ហើយនៅតែបន្ត “លាក់បាំងខ្លួន” នៅពីក្រោយខ្នង ខៀវ សំផន (ដែលជាឧបនាយករដ្ឋមន្ត្រីនៃរណសិរ្សរួបរួមជាតិកម្ពុជា)។ ព្រះអង្គក៏បានជួបជាមួយនឹង ហ៊ូ នឹម ដែលជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃនៃរណសិរ្សរួបរួមជាតិកម្ពុជា, ហ៊ូ យន់ ដែលជារដ្ឋមន្ត្រីក្រសួងព័ត៌មាននៃរណសិរ្សរួបរួមជាតិកម្ពុជា, និង ខៀវ សំផន ដែលជាអ្នកទទួលស្វាគមន៍សម្តេច នរោត្តម សីហនុ និង ព្រះជាយា ក្នុងអំឡុងព្រះរាជដំណើរមកកាន់ប្រទេសកម្ពុជា។

បុគ្គលទាំងបីរូបនេះ ត្រូវបានគេស្គាល់នៅក្នុងរង្វង់អ្នកសិក្សាស្រាវជ្រាវប្រទេសលោកខាងលិចថាជា “ខ្មោចទាំងបី” ដោយសារតែមានអ្នកស្រាវជ្រាវជនជាតិអូស្ត្រាលីម្នាក់ បានអះអាងថា បុគ្គលទាំងបីនេះ មិនបានឈរជើងនៅក្នុងព្រៃនៃប្រទេសកម្ពុជានោះទេ ក៏ប៉ុន្តែត្រូវបានប្រហារជីវិតតាមរាជបញ្ជារបស់សម្តេច នរោត្តម សីហនុ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០។ ទោះបីជាយ៉ាងណាក្តី ការពិតជាក់ស្តែង អ្នកទាំងបីគឺនៅមានជីវិតទាំងអស់គ្នា។ បច្ចុប្បន្ន ខៀវ សំផន កំពុងជាប់ឃុំឃាំងក្នុងប្រទេសកម្ពុជា ដោយត្រូវផ្តន្ទាទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិត ដែលចេញសេចក្តីសម្រេចដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលជាតុលាការមួយដែលទទួលបានការគាំទ្រដោយអង្គការសហប្រជាជាតិ ដើម្បីកាត់ទោសឧក្រិដ្ឋកម្មខ្មែរក្រហម។ ចំណែកឯ ហ៊ូ នឹម និង ហ៊ូ យន់ ត្រូវបានសម្លាប់នៅចុងទសវត្សរ៍ឆ្នាំ១៩៧០ ដោយ ប៉ុល ពត ដែលជាបុគ្គលលាក់កំបាំងនៅពីក្រោយអ្នកទាំងពីរ។[១១]

ព្រះរាជដំណើររបស់សម្តេច នរោត្តម សីហនុ និងព្រះជាយាបានធ្វើឡើងស្របពេលដែលយន្តហោះរបស់សត្រូវបានបង្កើនការទម្លាក់គ្រាប់បែកយ៉ាងគំហុកនៅក្នុងប្រទេសកម្ពុជា ហើយនេះគឺជាមូលហេតុដែលព្រះរាជដំណើររបស់ទ្រង់ប្រព្រឹត្តទៅដោយសម្ងាត់ជាទីបំផុត ឯអ្នកគាំទ្ររបស់សម្តេច នរោត្តម សីហនុ នៅទីក្រុងប៉េកាំងភាគច្រើនក៏មិនបានដឹងឮអំពីព្រឹត្តិការណ៍នេះដែរ។

---

១១. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬហៅថាសាលាក្តីខ្មែរក្រហម។



# ផ្នែកទី១
# ការឃ្លាតចេញដំណើរ

## នេះគឺជាសៀវភៅកំណត់ហេតុស្ដីពីការធ្វើដំណើររបស់ខ្ញុំ

ខ្ញុំមិនធ្លាប់កត់ត្រាកំណត់ហេតុស្ដីពីការធ្វើដំណើររបស់ខ្ញុំពីមុនមកនោះទេ។ ប៉ុន្តែថ្ងៃនេះខ្ញុំនឹងចាប់ផ្ដើមកត់ត្រាអំពីចំណាប់អារម្មណ៍របស់ខ្ញុំ ពីព្រោះថាការធ្វើដំណើរដែលយើងនឹងចាប់ផ្ដើមក្នុងរយៈពេលប៉ុន្មានថ្ងៃទៀត គឺជាដំណើរប្រវត្តិសាស្ត្រមួយ។

ដំណើររបស់យើង គឺចេញពីទីក្រុងហាណូយឆ្ពោះទៅកាន់តំបន់រំដោះនៃប្រទេសកម្ពុជាមាតុភូមិជាទីស្នេហា ដែលយើងបានឃ្លាតទៅអស់រយៈពេលជាងបីឆ្នាំកន្លងមក។ ដើម្បីទៅដល់មាតុភូមិបាន យើងត្រូវធ្វើដំណើរឆ្លងកាត់ផ្លូវលំហូជីមិញ ដែលមានឈ្មោះល្បីល្បាញនៅទូទាំងពិភពលោក! បន្ទាប់មក យើងនឹងបន្តដំណើរតាម “ផ្លូវលំ សីហនុ”! ខ្ញុំពិតជាសប្បាយចិត្តខ្លាំងណាស់ ដែលអាចធ្វើដំណើរបាន ពីព្រោះដំណើរនេះនឹងបង្ហាញថាយើងគឺជាសមាជិកពិតប្រាកដនៃចលនាតស៊ូ ហើយយើងមិនញញើតញញើមក្នុងការប្រឈមមុខនឹងគ្រោះថ្នាក់ទាំងអស់ ដើម្បីវិលត្រឡប់ទៅកាន់មាតុភូមិ និងជួបសួរសុខទុក្ខជនរួមជាតិ ដែលតស៊ូដោយអង់អាចនៅក្នុងប្រទេស។ ខ្ញុំនឹងព្យាយាមសរសេរអំពីចំណុចសំខាន់ៗ ពីព្រោះខ្ញុំមិនមែនជាអ្នកនិពន្ធនោះទេ!

# ថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ១៩៧៣

យើងចាកចេញពីទីក្រុងប៉េកាំង នៅវេលាម៉ោង ១៤ និង ៣០ នាទីរសៀល។ លោកនាយករដ្ឋ មន្ត្រី ជូ អេនឡាយ និងលោកជំទាវ រួមជាមួយនឹងសម្ដេច ប៉ែន នុត និងលោកជំទាវ បានអមដំណើរយើងទៅកាន់ព្រលានយន្តហោះ ព្រមទាំងជូនពរយើងឱ្យទទួលបានជោគជ័យពេញលេញ។ ការចាកចេញរបស់យើងនេះ បានធ្វើឡើងដោយសម្ងាត់បំផុត សូម្បីតែបុត្រាទាំងពីរអង្គរបស់យើងគឺ សីហមុនី និង នរិន្ទ្រពង្ស ដែលកំពុងតែសិក្សានៅទីក្រុងប្រាក និងទីក្រុងមូស្គូ ក៏មិនបានដឹងអំពីដំណើរនេះដែរ។

យើងមកដល់ទីក្រុងហាណូយនៅម៉ោង ១៨ និង ៣០ នាទីល្ងាច ម៉ោងនៅក្នុងប្រទេសវៀតណាម។



ការយាងមកដល់ទីក្រុងដុងហ្វយ

# ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៧៣

បន្ទាប់ពីចំណាយពេលប្រាំថ្ងៃនៅក្នុងទីក្រុងហាណូយ ដើម្បីរៀបចំសម្រាប់ការធ្វើដំណើរ ថ្ងៃនេះគឺជាថ្ងៃដែល "ដំណើរទស្សនកិច្ចប្រវត្តិសាស្ត្រ" របស់យើងចាប់ផ្ដើមហើយ។ ដូច្នេះ នៅម៉ោង ១១ និង ០០ នាទីព្រឹក យើងបានជិះយន្តហោះប្រភេទអ៊ីលយូហ្សិន ១៤ របស់រុស្ស៊ីឆ្ពោះទៅកាន់ស្រុកយ៉ាឡាំ។

នៅមុនពេលចេញដំណើរ យើងបានលាលោកនាយករដ្ឋមន្ត្រី ផាម វ៉ាន់ដុង[12] និងលោកឧត្តម សេនីយ៍ វ៉ូ ង្វៀន យ៉ាប និងលោកជំទាវ។ អ្នកទាំងអស់គ្នាមានអារម្មណ៍រំជួលចិត្តយ៉ាងខ្លាំង...ការហោះហើរបានប្រព្រឹត្តទៅយ៉ាងរលូន។ សម្លឹងមើលពីលើយន្តហោះមក យើងអាចមើលឃើញមាត់សមុទ្រ ជាពិសេសគឺខេត្តង៉េអាន ដែលជាកន្លែងកំណើតរបស់លោក នាយករដ្ឋមន្ត្រី ហូជីមិញ ជាទីនឹករឭក។ ខេត្តមួយនេះគឺជាទីកន្លែងដ៏គាប់ចិត្តរបស់ប្រជាជនវៀតណាមទាំងអស់។ យើងចុះចតនៅទីក្រុងដុងហូយ[13] នៅម៉ោង១២និង៣០នាទីថ្ងៃត្រង់។ បន្ទាប់មកយើងធ្វើដំណើរតាមរថយន្តហ្ស៊ីបទៅ ជឿងសឺន ដើម្បីឆ្ពោះទៅមូលដ្ឋានលេខ ៥៥៩។ យើងបានមកដល់ទីនេះនៅម៉ោង ១៤ និង ០០ នាទីរសៀល។ នៅទីនោះយើងត្រូវបានទទួលស្វាគមន៍ដោយមេបញ្ជាការប្រចាំផ្លូវលំហូជីមិញ។ នៅពេលរសៀលយើងធ្វើដំណើរកម្សាន្តតាមទូក តាមដងទន្លេគៀនយ៉ាង។ ដំណើរកម្សាន្តនេះប្រព្រឹត្តទៅដោយសេចក្ដីសោមនស្សជាពន់ពេក ហើយទេសភាពដងភ្នំត្រៀបត្រាជាជួរៗនៅពេលថ្ងៃហៀបលិច គឺពិតជាអស្ចារ្យខ្លាំងណាស់! យើងពិតជាសប្បាយរីករាយក្រៃលែងជាមួយនឹងសម្រស់ធម្មជាតិដ៏ត្រកាលនេះ!

នៅល្ងាចនោះ បន្ទាប់ពីទទួលទានអាហារពេលល្ងាចដ៏ស្និទ្ធស្នាលជាមួយមេបញ្ជាការមូលដ្ឋានរួច យើងបានចូលរួមទស្សនាការសម្ដែងសិល្បៈវប្បធម៌។ យើងពិតជាភ្ញាក់ផ្អើលនៅពេលឃើញជំនាញសិល្បៈដ៏ប៉ិនប្រសប់របស់ក្រុមសម្ដែង ហើយការសម្ដែងក៏រួមបញ្ចូលនូវចម្រៀង និងរបាំ។ រាត្រីដំបូងនៃដំណើរទស្សនកិច្ចរបស់យើងបានបញ្ចប់ទៅដោយភាពរីករាយនៅឯមូលដ្ឋាន៥៥៩។

១២. កំណត់ហេតុអ្នកបកប្រែភាសាអង់គ្លេសៈ ផាមវ៉ាន់ដុង គឺជាស្ថាបនិកម្នាក់នៃគណបក្សកុម្មុយនីស្តវៀតណាម និងជានាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ដែលក្រោយមកប្ដូរឈ្មោះជាសាធារណរដ្ឋសង្គមនិយមវៀតណាម បន្ទាប់ពីឆ្នាំ១៩៧៦ លោកបានបន្តបំពេញតួនាទីនេះ រហូតដល់ចូលនិវត្តន៍នៅឆ្នាំ១៩៨០។
១៣. កំណត់ហេតុអ្នកបកប្រែភាសាអង់គ្លេសៈ ដុងហូយ គឺជារាជធានីនៃខេត្តក្វាំងប៊ិញ ប្រទេសវៀតណាម។

# ថ្ងៃទី ២ ~ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៧៣

យើងបានចេញដំណើរនៅម៉ោង ៧ និង ០០ នាទីព្រឹក។ បន្ទាប់ពីធ្វើដំណើរអស់រយៈពេលប្រាំម៉ោង និងបានឈប់សម្រាកប្រមាណម្ភៃនាទី បន្ទាប់ពីឡើងទៅដល់រយៈកម្ពស់ ១០០៨ ម៉ែត្រ និងមកដល់ឆាលី បំពេលថ្ងៃត្រង់។ នេះគឺជាលើកទីមួយហើយដែលយើងបានឃើញ "ផ្លូវលំ ហូជីមិញ" ដ៏ល្បីល្បាញ។ យើងមានការស្លុតចិត្តយ៉ាងខ្លាំង។ គេបានប្រាប់យើងថាស្ថានភាពថ្ងៃស្អែកនឹងគួរឱ្យរន្ធត់ជាងនេះទៀត!

ប៉ុន្តែទេសភាពពិតជាស្រស់ស្អាតខ្លាំងណាស់! ក្នុងអំឡុងពេលឈប់សម្រាកមួយភ្លែតនេះ យើងស្តាប់ឮសូរសំឡេងសត្វទោចយំ និងគយគន់ទេសភាពជួរភ្នំលាតសន្ធឹងដាច់កន្ទុយភ្នែក។ យើងស្ទើរតែមិនចង់ ជឿអំពីទេសភាពដ៏ស្រស់អស្ចារ្យនេះ ... ការស្នាក់នៅឆាលី គឺពិតជាគួរឱ្យរីករាយណាស់។ កន្លែងនេះ ស្រស់ត្រកាល ព្រមទាំងមានទឹកធ្លាក់តូចមួយនៅចំពីមុខផ្ទះដែលយើងស្នាក់នៅទៀតផង។ មេបញ្ជាការប្រចាំទីតាំងនេះ បានចំណាយពេលរៀបចំការភ្ញាក់ផ្អើលដ៏រីករាយជាច្រើនសម្រាប់យើង ដោយចំណាយរយៈពេលតែប៉ុន្មានថ្ងៃប៉ុណ្ណោះ។

នៅល្ងាចនោះ យើងបានចំណាយពេលវេលាដ៏រីករាយ នៅទីវាលខាងក្រៅ ធ្វើការផ្លាស់ប្តូរយោបល់គ្នា និងស្តាប់របាយការណ៍ដែលបានរាយការណ៍ពីកងទ័ពជួរមុខឈរជើងនៅលើផ្លូវជាតិលេខ៩ ដែលជាកន្លែងមិត្តវៀតណាមរបស់យើងទទួលបានជ័យជម្នះដ៏អស្ចារ្យ។ មានរណ្តៅគ្រាប់បែកជាច្រើននៅក្បែរផ្ទះដែលយើងស្នាក់នៅ...ដើម្បីធានាសុវត្ថិភាព យើងត្រូវបន្តដំណើរទៅទាំងយប់។ ដូច្នេះ យើងបានចាកចេញពីទីកន្លែងដ៏ល្អឈ្អុះនោះទៅ។ ឆាលី គឺជាចំណុចចាប់ផ្តើមនៃផ្លូវលំហូជីមិញដែលយើងត្រូវធ្វើដំណើរ។

នៅពាក់កណ្តាលអធ្រាត្រ យប់ថ្ងៃទី២៨ ខែកុម្ភៈ យើងចេញដំណើរទៅកាន់ស៊ីឡាណុន។ ការធ្វើដំណើរនៅពេលយប់ ដែលមានរយៈពេលប្រាំបួនម៉ោង គឺចាប់ពីពាក់កណ្តាលអធ្រាត្ររហូតដល់ម៉ោង ៩ និង ០០ នាទីព្រឹក ថ្ងៃទី១ ខែមីនា គឺជាការធ្វើដំណើរគួរឱ្យចងចាំនិងមិនអាចភ្លេចបាន។

ផ្លូវនេះរលាក់ខ្លាំងជាងផ្លូវកាលពីម្សិលមិញទៅទៀត។ ប៉ុន្តែយើងបានធ្វើដំណើរតាមផ្លូវជាតិលេខ ៩ ដ៏ល្បីល្បាញនៅក្នុងឆ្នាំ១៩៧១! យើងមើលឃើញ ភូមិបានដុង និង ភូមិបានកែវ (ប្រទេសឡាវ) ព្រាលៗ ពីព្រោះពេលនោះគ្មានពន្លឺព្រះចន្ទទេ។ ទិដ្ឋភាពនៃរថក្រោះ និងរថយន្តធំៗ ....នៅតែដក់ជាប់ក្នុងការចងចាំរបស់ខ្ញុំជានិច្ច។

ទីតាំងនៃសមរភូមិឈ្លានពានលើប្រទេសឡាវផ្នែកខាងក្រោមក្នុងឆ្នាំ១៩៧១ នេះ គឺគ្រាន់តែជាចំណុចចាប់ផ្ដើមនៃដំណើរដ៏វែងឆ្ងាយតែប៉ុណ្ណោះ។ យើងធ្វើដំណើរនៅពេលយប់ ពីព្រោះយើងត្រូវឆ្លងកាត់ទីតាំងខ្លះៗដែលជាវាលរហោឋាន ដែលគ្មានសុវត្ថិភាពចំពោះការធ្វើដំណើរនៅពេលថ្ងៃ។ មិត្តវៀតណាមរបស់យើង ពិតជាមានគំនិតដ៏អស្ចារ្យក្នុងការបង្កើតផ្លូវធ្វើដំណើរនៅក្នុងព្រៃឫស្សីដែលមានចម្ងាយរាប់សិបគីឡូម៉ែត្រ ហើយអាចបិតបាំងអ្នកដំណើរបានយ៉ាងល្អ។ នេះគឺជាកិច្ចការដ៏មហិមា! ក្នុងអំឡុងពេលធ្វើដំណើរនៅពេលយប់ សម្ដេចទ្រង់ប្រឈួន នៅពេលយើងចរយាត្រាលើផ្លូវលេខ៩។ ដូចទៅនឹងក្ដីបារម្ភរបស់លោក អៀង សារី សម្ដេច ព្រះអង្គមិនស្រួលព្រះកាយចាប់តាំងពីដើមដំបូងនៃការធ្វើដំណើររបស់យើងមកម្ល៉េះ។ ទេវតាបានជួយថែរក្សាខ្ញុំ ហើយខ្ញុំអាចស៊ូទ្រាំនឹងការធ្វើដំណើរដ៏វែងឆ្ងាយនេះដោយក្លៀវក្លា។

នៅមុនថ្ងៃចេញដំណើររបស់យើងពីទីក្រុងហាណូយមួយថ្ងៃគឺនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៣ ឧត្ដមសេនីយ៍ យ៉ាប បានប្រគល់កាំភ្លើងខ្លីពីរដើមជូនសម្ដេច និងខ្ញុំ។ យើងនឹងរក្សាទុកកាំភ្លើងទាំងពីរនេះ នៅក្នុងសារមន្ទីរនៃចលនាតស៊ូ បន្ទាប់ពីរំដោះ!

# ថ្ងៃទី ៣ ~ ថ្ងៃទី១ ខែមីនា ឆ្នាំ១៩៧៣

នៅម៉ោង ៩ និង ០០ នាទីព្រឹក បន្ទាប់ពីធ្វើដំណើរអស់ប្រមាណជាប៉ែតសិបប្រាំគីឡូម៉ែត្រ យើងបានមកដល់ស៊ីឡាណុន ក្នុងតំបន់រំដោះប៉ះថេតឡាវ[១៤]។ នៅទីនេះ យើងឃើញមានទឹកធ្លាក់ដ៏ស្រស់ស្អាត អមជាមួយនឹងផ្ទាំងថ្មធំៗ និងទឹកប្លាធ្វង់ ដែលទាក់ទាញឱ្យយើងចង់ចុះទៅងូតទឹកជាខ្លាំង។ ប៉ុន្តែគ្រូពេទ្យ មិនអនុញ្ញាតឱ្យយើងចុះងូតទឹកត្រជាក់នោះទេ បន្ទាប់ពីការធ្វើដំណើរយ៉ាងនឿយហត់នេះ។ យើងមានអារម្មណ៍សប្បាយរីករាយដែលអាចគយគន់ទេសភាព និងងូតទឹកក្តៅឧណ្ហៗនៅទីនោះ។

ក្នុងអំឡុងពេលឈប់សម្រាកនៅកន្លែងនេះ មានយន្តហោះទម្លាក់គ្រាប់បែកបានហោះកាត់ពីលើយើង។ ក្នុងរយៈពេលបីឆ្នាំចុងក្រោយ នេះគឺជាលើកដំបូងដែលយើងបានឮស្វរសំឡេងយន្តហោះនេះ។ កន្លែងនេះ រំឭកខ្ញុំអំពីទីតាំងមួយនៅក្នុងប្រទេសកម្ពុជា គឺខេត្តកំពត នៅក្នុងស្រុកទឹកឈូ កំចាយ ដែលមានថ្មធំៗរលើបរលោង និងទឹកប្លាធ្វង់ហូរធ្លាក់ក្នុងសណ្ឋានជាទឹកជ្រោះតូចៗ...

នៅពេលយប់ យើងបានឮស្វរសំឡេងផ្ទុះយ៉ាងខ្លាំងមួយៈ គេបានប្រាប់យើងថា នោះគឺជាសំឡេងគ្រាប់បែកចង្កោម ដែលទម្លាក់ពីយន្តហោះសត្រូវហើយមិនទាន់ផ្ទុះ។ ខ្ញុំភ្លេចលើកឡើងថានៅពេល ដែលយើងចាកចេញពីមូលដ្ឋានលេខ៩៥៩ ដើម្បីធ្វើដំណើរទៅកាន់ធាលី ខ្ញុំឃើញមានដើមចេកព្រៃរាប់ពាន់ដើម ដែលគ្មានផ្លែប៉ុន្តែបានរួមផ្សំធ្វើឱ្យទេសភាពជួរភ្នំកាន់តែស្រស់បំព្រង។ ទន្ទឹមនឹងនេះ ក៏មានដើមប៉ប្រុកធំៗ និងដើមឈើត្រឈឹងត្រឈៃផ្សេងៗទៀតដែរ។

---

១៤. កំណត់សម្គាល់របស់អ្នកបកប្រែ៖ “ប៉ះថេតឡាវ” គឺជាឈ្មោះកាត់ក្នុងភាសាឡាវ សំដៅដល់បក្សកុម្មុយនីស្តឡាវក្នុងអំឡុងសង្គ្រាមវៀតណាម។



ព្រៃមួយកន្លែងនៅក្នុងប្រទេសកម្ពុជា

# ថ្ងៃទី ៨ ~ ថ្ងៃទី២ ខែមីនា ឆ្នាំ១៩៧៣

យើងចាកចេញពីស៊ីឡាណុននៅម៉ោង ៧ និង ០០ នាទីព្រឹក ដើម្បីធ្វើដំណើរទៅជំរំកាហ្សេ ៤ នៅកាណូយ។ យើងធ្វើដំណើរអស់រយៈពេលប្រាំមួយម៉ោង ស្មើនឹងចម្ងាយចិតសិបប្រាំគីឡូម៉ែត្រ។ ផ្លូវដែលយើងធ្វើដំណើរ គឺរលាក់ខ្លាំង និងហុយទូលោម ប៉ុន្តែអមដោយដើមឈើត្រឈឹងត្រឈៃ។ ដើមឈើទាំងនោះប្រាកដជាមានអាយុកាលមិនតិចជាងពីររយឆ្នាំនោះទេ។ នេះគឺជាព្រៃមួយនៅក្នុងតំបន់អាស៊ី ដែលមានវល្លិធំៗសំយុងចុះមកក្រោម រួមជាមួយនឹងដើមឈើដែលមានឫសរឹងមាំល្អ។ បន្ទាប់មក យើងធ្វើដំណើរឆ្លងកាត់ព្រៃឫស្សីដ៏ក្រាស់ក្រែល ដែលដុះត្រៀបត្រាបង្កើតបានជាច្រកផ្លូវធម្មជាតិមួយ។ យើងឈប់សម្រាកបន្តិច និងថតរូបខ្លះៗ។ យើងបានមកដល់ជំរំកាហ្សេ ៤ នៅម៉ោង ១៣ និង ០០ នាទីរសៀល។ លើកនេះមិត្តវៀតណាមបានសាងសង់ផ្ទះឫស្សីតូចមួយនៅក្នុងព្រៃសម្រាប់ឱ្យយើងស្នាក់នៅ។ ខ្ញុំពិតជានឹកស្មានមិនដល់ថា ក្នុងអំឡុងពេលធ្វើដំណើរ យើងអាចមាន ផ្ទះឫស្សីតូចមួយប៉ុន្តែប្រកបដោយ ផាសុកភាពដើម្បីស្នាក់អាស្រ័យនៅក្នុងព្រៃ ដោយរួមមានបន្ទប់ទឹក និងបង្គន់សម្រាប់ប្រើប្រាស់ទៀតផង។ យើងមាន អារម្មណ៍ស្រណុកសុខស្រួលហាក់បីដូចជានៅក្នុងទីក្រុងអ៊ីប៊ឹង។ បើនិយាយអំពីអាហារវិញ យើងទទួលទាន អាហារបារាំងជារៀងរាល់ថ្ងៃដោយរួមមាននំប៉័ងដុតថ្មីៗ បន្លែស្រស់ៗ និងសាច់គ្រប់ប្រភេទ! នេះហាក់បីដូចជាយើងកំពុងស្រស់ស្រូបអាហារនៅក្នុងទីក្រុងធំមួយយ៉ាងដូច្នោះដែរ!

នៅពេលរសៀល យើងបានធ្វើទស្សនកិច្ចខ្លីមួយទៅកាន់ជំរំមួយដែលមានឈ្មោះថាកាហ្សេ៤។ យើងបានឃើញអំពីការអនុវត្តវិធានការរបស់មិត្តវៀតណាមដើម្បីការពារខ្លួនពីការទម្លាក់គ្រាប់បែក ក៏ដូចជាទស្សនកិច្ចរោងកុន ផ្ទះបាយ ផ្ទះសិល្បៈ និងទីស្តុកទឹកហូរមកពីលើភ្នំ ដែលហាក់បីដូចជាហូរឥតដាច់។

បន្ទាប់ពីស្រស់ស្រូបអាហារពេលល្ងាច យើងបានទស្សនាការបញ្ចាំងខ្សែភាពយន្តមួយដែលមានចំណងជើងថា "កងទ័ពវ័យក្មេង"។ ខ្សែភាពយន្តនេះបង្ហាញអំពីមន្ត្រីក្រៅក្របខ័ណ្ឌម្នាក់ ដែលទើបតែបញ្ចប់ការសិក្សាពីសាលាយោធា ហើយបានចូលបម្រើការងារជាទ័ពជួរមុខ ដើម្បីតស៊ូប្រឆាំងនឹងអាណានិគមនិយមបារាំងនៅក្នុងឆ្នាំ១៩៥០។ ខ្សែភាពយន្តនេះផលិតឡើងយ៉ាងល្អឥតខ្ចោះ ហើយយើងទស្សនាលំហូរសាច់រឿងនោះយ៉ាងជក់ចិត្ត។ ខ្ញុំត្រូវតែលើកឡើងអំពីជម្រកលាក់ខ្លួនពីយន្តហោះចម្បាំង ដែលតែងតែសង់ឡើងនៅក្បែរផ្ទះដែលយើងស្នាក់នៅរៀងរាល់ពេលសម្រាកពីការធ្វើដំណើរ គឺចាប់តាំងពីយើងចាកចេញមកស៊ីឡាណុនម្ល៉េះ។ ជារៀងរាល់ថ្ងៃចាប់ពីម៉ោង ១២ និង ០០ នាទីថ្ងៃត្រង់ រហូតដល់ម៉ោង ១៦ និង ០០ នាទី យើងតែងតែឮសូរសំឡេងយន្តហោះសត្រូវ ហោះកាត់ពីលើយើង!

# ថ្ងៃទី ៩ ~ ថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៧៣

យើងចេញដំណើរនៅម៉ោង ៧ និង ០០ នាទីដូចធម្មតា។ ផ្លូវដែលយើងធ្វើដំណើរនៅថ្ងៃនេះ គឺពិតជារលាក់ និងហុយខ្លាំងណាស់។ ប្រសិនបើខ្ញុំមិនបានពាក់មួកសុវត្ថិភាពដែលខ្ញុំតែងតែយកមកតាមខ្លួនទេ នោះក្បាលរបស់ខ្ញុំនឹងពកជាក់ជាមិនខាន! ពីព្រោះថាយើងតែងតែបុកក្បាលជាមួយនឹងដំបូលឡានរហូត! ការធ្វើដំណើរចំណាយអស់រយៈពេលប្រាំមួយម៉ោង ហើយយើងឈានទៅមុខបានប៉ែតសិបគីឡូម៉ែត្របន្ថែមទៀត។ យើងបានមកដល់ជិតច្រាំងទន្លេសេកុង គឺនៅត្រង់ទន្លេសេណាំណាយ ភាគខាងជើងនៃភូមិបានផុន ដោយខ្លួនប្រាណប្រឡាក់ពេញដោយធូលីដី!

ប៉ុន្តែកន្លែងដែលយើងមកដល់នេះ គឺស្រស់ស្អាតហើយផ្ទះសម្រាប់ឱ្យយើងស្នាក់នៅ ត្រូវបានសាងសង់ឡើងក្រោមដើមឈើធំៗ អមជាមួយអូរតូចមួយនៅចំខាងមុខ។ ការសាងសង់ផ្ទះនេះ គឺពិតជាល្អខ្លាំងណាស់សម្រាប់ឱ្យយើងអាចចុះងូតទឹក! ប៉ុន្តែនៅពេលយើងកំពុងងូតទឹក យន្តហោះសត្រូវបានហោះហើរនៅពីលើយើងជាច្រើនលើកច្រើនសា! បេះដូងខ្ញុំលោតញាប់យ៉ាងខ្លាំង ព្រោះខ្ញុំគិតថាតើខ្ញុំ អាចរត់ទៅដល់ជម្រកលាក់ខ្លួនទាន់ពេលឬទេ។ ជម្រកលាក់ខ្លួនរបស់យើងស្ថិតនៅជិតបន្ទប់ស្នាក់របស់យើង ដែលយើងត្រូវត្បុលចូលទៅតាមរន្ធមួយនៅលើជញ្ជាំង។ ខ្ញុំមិនដឹងថាតើខ្ញុំអាចទៅដល់ជម្រកលាក់ខ្លួនរបស់យើងបានទាន់ពេល មុនពេលដែលគ្រាប់បែកទីមួយធ្លាក់ចុះមកដែរឬអត់នោះទេ! ប៉ុន្តែគ្មានរឿងអ្វីកើតឡើងឡើយនៅពេលនោះ ហើយបន្ទាប់ពីហោះហើរទៅវិញទៅមកជាច្រើនដង យន្តហោះសត្រូវបានចាកចេញទៅបាត់! ហ៊ឺ! ការធ្វើដំណើររបស់យើងមួយថ្ងៃទៀតក៏បានបញ្ចប់ទៅដោយរលូនទៅ!

នៅទីនេះ ក៏ដូចជានៅកន្លែងផ្សេងទៀតដែលយើងបានស្នាក់នៅ គឺមានសត្វមាន់តូកគី មាន់ស្រុក ជ្រូក និងសួនបន្លែ។ ហេតុនេះហើយបានជាអាហាររបស់យើងតែងតែមានមុខម្ហូបខុសៗគ្នា និងមានចំនួនច្រើនៗ។ នៅពេលដែលយើងធ្វើដំណើរឆ្ពោះទៅទិសខាងត្បូង ខ្ញុំកត់សម្គាល់ឃើញថា ទេសភាពគឺកាន់តែស្ងួតហែង និងគ្មានទឹកហូរដូចពីមុននោះទេ។ នេះគឺដោយសារតែរដូវប្រាំងបានឈានមកដល់។ នៅតាមបណ្តោយផ្លូវដែលយើងធ្វើដំណើរ យើងអាចមើលឃើញរណ្តៅដែលបន្សល់ទុកពីការទម្លាក់គ្រាប់បែករបស់សត្រូវ។ យើងអាចយល់បានថា សត្រូវបានទម្លាក់គ្រាប់បែកឥតស្រាកស្រាន្ត ប៉ុន្តែដោយគ្មានប្រយោជន៍ទាល់តែសោះ។ គ្រាប់បែកដែលសត្រូវទម្លាក់ចុះមក គឺកម្រប៉ះចំគោលដៅរបស់ខ្លួនណាស់!



ការឈប់សម្រាកនៅក្នុងព្រៃប្រទេសកម្ពុជា

# ថ្ងៃទី ៦ ~ ថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៣

នៅពេលយប់ដែលមានសភាពស្ងប់ស្ងាត់ហើយក្តី ក៏យើងនៅតែបានឮសូរសំឡេងយន្តហោះសត្រូវហោះពីលើយើងនៅម៉ោង ២១ និង ០០ នាទី។ សភាពនេះពិតជាចម្លែកខុសពីធម្មតា បើគិតចាប់តាំងពីថ្ងៃទី២២ ខែកុម្ភៈមក។ ថ្ងៃនេះ យើងបន្តឈប់សម្រាកនៅសេណាំណាយមួយថ្ងៃទៀត ហើយបន្ទាប់មកយើងនឹងចេញដំណើរនៅម៉ោងប្រហែល ១៦ និង ០០ នាទី ពីព្រោះផ្លូវនេះគឺជាវាលល្ហល្ហេវ ទើបយើងសម្រេចចិត្តធ្វើដំណើរនៅពេលយប់ ពោលគឺវាមានសុវត្ថិភាពជាង។ ដូច្នេះនៅពេលព្រឹក ខណៈពេលដែលខ្ញុំ កំពុងសរសេរសៀវភៅកំណត់ហេតុនេះ ក្រុមថតខ្សែភាពយន្ត ដែលរួមដំណើរមកជាមួយយើងកំពុងជាប់រវល់ផលិតខ្សែភាពយន្តឯកសារស្តីពីការវិលត្រឡប់របស់យើងមកកាន់តំបន់រំដោះរបស់ប្រទេសកម្ពុជា។

សម្តេចព្រះប្រមុខរដ្ឋ, បេសកជនពិសេស អៀង សារី និងរូបខ្ញុំផ្ទាល់ យើងទាំងបីគឺជា "តួអង្គ" ក្នុងខ្សែភាពយន្តឯកសារនេះ នៅខណៈពេលដែលយើងរង់ចាំឈានជើងចូលមកក្នុងទឹកដីប្រទេសកម្ពុជា ដែលយើងនឹងថតសកម្មភាពជាមួយមេដឹកនាំចលនាតស៊ូ ប្រជាជន អ្នកតស៊ូ និងព្រះសង្ឃនៅទីនោះ។

ក្មេងស្រីជនជាតិវៀតណាមមួយក្រុមបានមកជួបខ្ញុំ និងឱ្យខ្ញុំភ្លក្សទឹកដូងដ៏ឈ្ងុយឆ្ងាញ់! នៅម៉ោង ១៣ និង ០០ នាទី នៅពេលដែលយើងកំពុងសោយអាហារ យន្តហោះសត្រូវបានហោះកាត់ពីលើយើងទៀត។ ខ្ញុំភ្លេចលើកឡើងថាយើងពិតជារីករាយជាមួយនឹងសាច់ជ្រូកអាំង "ប្រកបដោយឱជារស" ក្នុងអំឡុងពេលសម្រាកនៅជំរំកាហ្សេ៤ នៅកាណូយ។ ចាប់តាំងពីយើងចេញដំណើរមក ម្ហូបអាហារគ្រប់ពេលទាំងអស់គឺសុទ្ធតែឈ្ងុយឆ្ងាញ់ខ្លាំងណាស់!



បន្ទាប់ពីចាកចេញពីសេណាំណាយ[១៥] នៅម៉ោង ១៥ និង ៣០ នាទី យើងធ្វើដំណើរអស់ចម្ងាយហាសិបប្រាំគីឡូម៉ែត្រ ហើយបានមកដល់សេណាយនៅម៉ោង ១៩ និង ០០ នាទី។ យើងបានធ្វើដំណើរឆ្លងកាត់ផ្លូវលេខ១៦ដែលសាងសង់ឡើងដោយបារាំងនៅមុនសង្គ្រាម។ នៅទីនោះ យើងអាចធ្វើដំណើរក្នុងល្បឿនសែសិបគីឡូម៉ែត្រក្នុងមួយម៉ោង! នេះគឺជាលើកទីមួយហើយចាប់តាំងពីការចាប់ផ្ដើមដំណើររបស់យើង ពីព្រោះជាធម្មតាយើងអាចធ្វើដំណើរបានត្រឹមតែដប់ ឬម្ភៃគីឡូម៉ែត្រប៉ុណ្ណោះក្នុងមួយម៉ោង។

ទេសភាពបានផ្លាស់ប្ដូរទម្រង់បន្តិចហើយ យើងកម្រនឹងឃើញទឹកអូរ ឬដើមឈើពណ៌បៃតងទៀតណាស់។ ដោយសារតែខែនេះ គឺជារដូវប្រាំង ហើយផ្លូវហុយដីទូលោម ទើបធ្វើឱ្យដើមឈើនៅតាមបណ្ដោយផ្លូវមានពណ៌ត្នោត។ ពេលខ្លះយើងជួបប្រទះកន្លែងដែលត្រូវបានបំផ្លិចបំផ្លាញទាំងស្រុង ដោយសារការទម្លាក់គ្រាប់បែករបស់សត្រូវ។ ដើមឈើពុះហែកជាពីរ ឬឆេះ ខ្លោចទៅជាផេះផង់ បន្សល់ទុកតែមែកទទេឈរត្រឹងចង្អុលទៅលើមេឃ ... នេះគឺពិតជាទិដ្ឋភាពដែលឆ្លុះបញ្ចាំងអំពីការបំផ្លិចបំផ្លាញ ខណៈដែលកន្លែងនេះគួរតែមានភាពស្រស់បំព្រង និងមានដើមឈើពណ៌បៃតងដូចពេលអតីតកាល។ ទោះបីជាយ៉ាងណាក៏ដោយ យើងនៅតែអាចមើលឃើញ ដើមត្នោតធំៗ និងដើមឈើចំណាស់ៗដទៃទៀត ដែលមានអាយុកាលរាប់សតវត្សរ៍ អមជាមួយនឹងមែកវល្លិ...

---

១៥. កំណត់ហេតុរបស់អ្នកបកប្រែជាភាសាអង់គ្លេស៖ សេណាំណាយមានទីតាំងស្ថិតនៅក្នុងខេត្តចំប៉ាសាក់នៃប្រទេសឡាវ។

# ថ្ងៃទី ៧ ~ ថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៣

បន្ទាប់ពីរាត្រីដ៏ស្ងប់ស្ងាត់ យើងភ្ញាក់ពីដំណេកជាមួយនឹងទេសភាពដ៏គួរឱ្យទាក់ទាញ។ ដោយសារតែល្បាចម្សិលមិញមេឃងងឹតខ្លាំងពេក ទើបយើងមិនអាចមើលឃើញអ្វីទាំងអស់។ នៅខាងមុខផ្ទះឫស្សីដ៏តូចរបស់យើងដែលមានបន្ទប់ទទួលទានអាហារ និងបន្ទប់គេងតូចមួយ ក៏មានជម្រកលាក់ខ្លួននៅពេលចាំបាច់នៅក្បែរនោះដែរ យើងឃើញទន្លេដ៏ធំល្វឹងល្វើយមួយដែលមានផ្ទាំងថ្មធំៗ និងទឹកធ្លាក់...ទីនេះពិតជាស្រស់ស្រាយខ្លាំងណាស់... នៅខាងក្រោមផ្ទះរបស់យើងមានគំនរស្លឹកឈើ...មានខ្យល់បក់តិចៗ...យើងចង់នៅទីនេះយូរជាងនេះ ប៉ុន្តែយើងត្រូវបន្តដំណើរទៅមុខដ៏វែងឆ្ងាយទៀត។

ព្រឹកនេះ សម្តេចបានចុះសម្អាតព្រះកាយជាមួយទឹកទន្លេ។ ខ្ញុំក៏បានសម្អាតខ្លួនបន្តិចដែរ។ បើអ្វីៗដំណើរការទៅបានល្អក្នុងរយៈពេលបីថ្ងៃទៀត យើងនឹងទៅដល់ភូមិអូរតាង៉ូវ[១៦] ដែលជាភូមិតូចមួយនៅតាមបណ្តោយព្រំដែននៃព្រះរាជាណាចក្រកម្ពុជា! បេះដូងខ្ញុំលោតញាប់ នៅពេលនឹករំពៃថាមិនយូរទៀតទេ យើងនឹងទៅដល់ទឹកដីកំណើត បន្ទាប់ពីឃ្លាតចាកឆ្ងាយអស់រយៈពេលបីឆ្នាំកន្លងមក ... នៅរសៀលនេះ បន្ទាប់ពីផ្អុំលក់មួយស្របក់ សម្តេច និងខ្ញុំបានចុះសម្អាតកាយជាមួយទឹកទន្លេម្តងទៀត។ ការងូតទឹកផ្តល់នូវអារម្មណ៍ស្រស់ស្រាយដល់យើងទាំងពីរ ពីព្រោះថាអាកាសធាតុក្តៅខ្លាំងណាស់។ យើងបានថតនូវសកម្មភាពពេលកំពុងដើរឆ្លងទឹកទន្លេ។ នៅពេលដែលកំពុងសរសេរសៀវភៅកំណត់ហេតុនេះ ខ្ញុំឮសូរសំឡេងផ្ទុះជាច្រើនដង។ សំឡេងផ្ទុះទាំងនេះ គឺចេញមកពីគ្រាប់បែកបង្កោម។ ការណ៍នេះបញ្ជាក់ថាមានគ្រាប់បែកបង្កោមជាច្រើននៅម្តុំក្បែរៗយើង ដែលពិតជាគ្រោះថ្នាក់ណាស់ប្រសិនបើយើងទៅឆ្ងាយពីផ្ទះដែលកំពុងស្នាក់នៅទីនោះ។ យន្តហោះសត្រូវបានហោះពីលើយើងម្តងទៀតនៅរសៀលនេះ។

---

១៦. កំណត់សម្គាល់របស់អ្នកបកប្រែភាសាអង់គ្លេស៖ ភូមិអូរតាង៉ូវមានទីតាំងស្ថិតនៅក្នុងខេត្តស្ទឹងត្រែងនៃប្រទេសកម្ពុជា។

នៅល្ងាចនេះ យើងបានទស្សនាខ្សែភាពយន្តចំនួនពីររឿង។ រឿងទីមួយគឺ ស្តីពីដំណើរផ្សងព្រេង និងវីរភាពរបស់អ្នកបើកឡានធំនៅលើផ្លូវលំហូជីមិញ ចំណែកឯរឿងទីពីរ គឺជាភាពយន្តឯកសារដែលបង្ហាញអំពីស្នាដៃដ៏គួរឱ្យកត់សម្គាល់របស់មិត្តវៀតណាម ដែលទទួលខុសត្រូវក្នុងការមើលថែរក្សាផ្លូវលំហូជីមិញនេះឱ្យអាចធ្វើដំណើរបាន ទោះបីជាមានការទម្លាក់គ្រាប់បែកដោយសត្រូវក៏ដោយ។ ខ្សែភាពយន្តនេះ ពិតជាគួរឱ្យរំជួលចិត្ត និងគួរឱ្យចាប់អារម្មណ៍ក្រៃលែង។

បន្ទាប់មកទៀត ស្នងការនយោបាយតំបន់ បានអញ្ជើញយើងទៅទទួលទានអាហារជាមួយកម្មាភិបាលមួយក្រុមរបស់គាត់។ ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅពេលបានឃើញតុដ៏ស្រស់ស្អាត ដែលមានការតុបតែងយ៉ាងប្រពៃ ដោយមានផ្កាភ្ញី កម្រាលតុស្រស់ស្អាត ចានក្បាន និងអាហារដែលមានរសជាតិឈ្ងុយឆ្ងាញ់! យើងមានអារម្មណ៍ថាហាក់បីដូចជាកំពុងតែទទួលទាន ក្នុងបន្ទប់អាហារនៅភោជនីយដ្ឋានដ៏ធំមួយនៅទីក្រុងប៉ារីស! អាហារពេលល្ងាចប្រព្រឹត្តទៅប្រកបដោយភាពស្និទ្ធស្នាល និងដោយប្រណីតភាព។ យើងបានស្តាប់មិត្តវៀតណាម និយាយអំពីរឿងរ៉ាវដែលបានកើតឡើងនៅលើផ្លូវលំហូជីមិញ។ នៅម៉ោង ៣ និង ៣០ នាទី យើងត្រូវចាកចេញពីសេណាយ ដើម្បីបន្តដំណើរលើកចុងក្រោយបង្អស់នៅលើទឹកដីប្រទេសឡាវ មុននឹងទៅដល់ព្រំដែនកម្ពុជា។





# ថ្ងៃទី ៨ ~ ថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៧៣

បន្ទាប់ពីធ្វើដំណើរអស់រយៈពេលប្រាំពីរម៉ោងនៅលើផ្លូវដែលរលាក់ និងហុយទូលោម យើងមកដល់សេស្វនៅម៉ោង ១១ និង ០០ នាទីព្រឹកនៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៧៣។ បន្ទាប់ពីធ្វើដំណើរអស់រយៈពេលបីម៉ោង យើងឈប់សម្រាករយៈពេលដប់នាទី។ ខ្ញុំរកមើលបំពង់ទឹករក្សាកម្ដៅចំនួនពីរ ដែលខ្ញុំបានរៀបចំទុកជាស្រេច មុនពេលចេញដំណើរ។ បំពង់មួយដាក់ទឹកតែ និងបំពង់មួយទៀតដាក់ទឹកអូវ៉ាន់ទីន។ ប៉ុន្តែនៅពេលខ្ញុំបើកគម្របមក គឺបែរជាមិនមានភេសជ្ជៈ ដ៏ឈ្ងុយឆ្ងាញ់ទាំងពីរនេះទេ ពីព្រោះតែផ្លូវរលាក់ខ្លាំងពេក ទើបធ្វើឱ្យភេសជ្ជកំពប់អស់រលីង! យើង បានសើចយ៉ាងអស់សំណើចទាំងអស់គ្នា!

មិត្តវៀតណាមម្នាក់ដែលរស់នៅទីនេះ បានឱ្យសាច់ជ្រូកព្រៃស្រស់ៗ ដែលគាត់ទើបតែសម្លាប់ហើយថ្មីៗមកយើង។ សាច់ជ្រូកព្រៃនេះ ប្រាកដជាអាចធ្វើជាម្ហូបដ៏ឈ្ងុយឆ្ងាញ់នៅពេលក្រោយបាន។ មុននឹងមកដល់សេស្វ យើងបានធ្វើដំណើរឆ្លងកាត់ទីកន្លែងខ្លះដែលរាងល្ហល្ហេវ ដោយមានដើមឈើដែលត្រូវបានកាប់បំផ្លាញជាកំណាត់ៗពីការទម្លាក់គ្រាប់បែករបស់សត្រូវ។ រណ្ដៅធំៗបន្សល់នៅពាសពេញលើផ្ទៃដី ហើយផ្ទៃរណ្ដៅខ្មៅខ្លោចដោយសារតែការផ្ទុះគ្រាប់បែក។ អ្វីៗបានហិនហោចអស់! ប៉ុន្តែ យើងក៏បានឃើញដើមឈើតូចៗទើបលាស់ថ្មី ដែលមានស្លឹកឈើ ចាំងរលេចជាមួយពន្លឺព្រះអាទិត្យ ... ពេលនោះយើងបានជិះកាណូតដើម្បីឆ្លងកាត់ទន្លេសេកុង។

នៅសេស្វ យើងចុះពីលើឡានហ្ស៊ីប ហើយធ្វើដំណើរដោយថ្មើរជើងប្រហែលជាសាមសិបនាទីដើម្បីទៅដល់ផ្ទះស្នាក់របស់យើងនៅលើភ្នំ។ ផ្ទះនេះមានរចនាបថបែបឡាវ និងនៅតែភ្ជាប់មកជាមួយនឹងជម្រកលាក់ខ្លួនសម្រាប់យើង។ ផ្ទះមួយខ្នងនេះ ត្រូវបានសង់ឡើងយ៉ាងអាថិកំបាំងនៅក្រោមដើមឈើធំៗ និងមានបរិយាកាសស្ងប់ស្ងាត់។ យើងរីករាយជាខ្លាំងនៅពេលទៅដល់សេស្វ ពីព្រោះផ្លូវធ្វើដំណើរគឺពិតជាពិបាកខ្លាំងណាស់។ យើងក៏សប្បាយចិត្តនៅពេលយើងអាចលាងជម្រះកាយពីធូលីដីដែលរុំជុំជិតសម្លៀកបំពាក់របស់យើង។ ខ្ញុំយល់ថា ខ្ញុំគួរតែនិយាយរៀបរាប់ខ្លះៗអំពីអ្នកបើកបររថយន្តរបស់យើងដែរ។ អ្នកបើកបររបស់យើងគឺពិតជាគួរឱ្យស្ញើចសរសើរណាស់! គាត់ពូកែ ហើយស្គាល់ច្បាស់គ្រប់ច្រកល្ហកនៃផ្លូវលំហូជីមិញស្ទូម្បីតែគាត់បើកបរនៅពេលយប់ និងមិនអាចប្រើភ្លើងចង្កៀងបំភ្លឺផ្លូវរបស់រថយន្តហ្ស៊ីបយ៉ាងណាក្តី យើងបានប្រើចង្កៀងដែលបាញ់ពន្លឺចុះទៅក្រោមជំនួសវិញ ដើម្បីកុំឱ្យយន្តហោះសត្រូវចាប់អារម្មណ៍។ យើងសំណាងល្អណាស់ដែលមានគាត់ជាអ្នកបើកបរឱ្យយើង។ លើសពីនេះទៅទៀត គាត់ថែមទាំងមានទឹកចិត្តល្អហើយតែងតែសួរនាំសុខទុក្ខរបស់យើងក្នុងអំឡុងពេលធ្វើដំណើរទៀតផង។

នៅពេលខ្ញុំភ្ញាក់ពីដំណេកនៅម៉ោងប្រហែល ២ និង ០០ នាទីរំលងអធ្រាត្រ ដើម្បីរៀបចំរបស់របរត្រៀមចេញដំណើរទៅមុខទៀត ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅពេលបានឃើញសត្វមួយក្បាលនៅក្បែរកញ្ចប់របស់របររបស់ខ្ញុំ ដែលមើលទៅដូចជាសត្វទន្សាយអញ្ចឹង ប៉ុន្តែតាមពិតទៅ វាគឺជាសត្វកណ្តុរដ៏ធំ និងធាត់មួយក្បាលទៅវិញទេ។ សត្វកណ្តុរនោះសម្លឹងមើលមុខខ្ញុំចំដោយគ្មានភាពភ័យខ្លាច។ សត្វកណ្តុរនៅលើភ្នំ គឺធំៗណាស់ ដូចដែលខ្ញុំបានឃើញផ្ទាល់ភ្នែកស្រាប់!

យើងបានចាកចេញពីសេស្វនៅម៉ោងប្រហែល ៣ និង ០០ នាទីព្រឹក ដោយក្តីអំណររីករាយពីព្រោះយើងគិតថានៅត្រឹមប៉ុន្មានម៉ោងទៀតតែប៉ុណ្ណោះ យើងនឹងទៅដល់មាតុភូមិវិញហើយ។ ខ្ញុំមិនអាចពិពណ៌នាអំពីអារម្មណ៍ខ្ញុំនៅពេលនោះបានឡើយ! ខ្ញុំពិតជាសោកស្តាយណាស់ដែលរូបខ្ញុំមិនមែនជាកវីនិពន្ធ ដែលអាចសរសេរបកស្រាយនៅក្នុងសៀវភៅកំណត់ហេតុមួយនេះនូវអារម្មណ៍ដែលខ្ញុំមាននៅពេលឃើញដែនដីមាតុភូមិរបស់ខ្លួនជាថ្មីម្តងទៀត!

# ផ្នែកទី២
# ការយាងមកដល់ប្រទេសកម្ពុជា

# ថ្ងៃទី ៩ ~ ថ្ងៃទី៧ ខែមីនា ឆ្នាំ១៩៧៣

យើងបានវិលត្រឡប់មកមាតុភូមិជាទីស្នេហាវិញហើយ បន្ទាប់ពីឃ្លាតទៅអស់រយៈពេលបីឆ្នាំ! ថ្ងៃនេះ គឺជាថ្ងៃដែលខ្ញុំចងចាំមិនភ្លេច! បន្ទាប់ពីការធ្វើដំណើរអស់រយៈពេលប្រាំពីរម៉ោង អមជាមួយការឈប់សម្រាកមួយស្របក់ ដើម្បីផ្លាស់ប្ដូរសម្លៀកបំពាក់ និងទទួលទានភេសជ្ជៈ។ យើងបានឆ្លងកាត់ទន្លេអូរតាង៉ូរ ដែលជាបន្ទាត់ព្រំដែនរវាងប្រទេសកម្ពុជា និងប្រទេសឡាវនៅវេលាម៉ោង១០ និង ០០ នាទីព្រឹក។ នៅពេលដែលយើងបានឈានជើងចូលមកដល់ក្នុងទឹកដីខ្មែរវិញ យើងមានសេចក្ដីរីករាយជាពន់ពេកណាស់ និងទទួលបានការស្វាគមន៍យ៉ាងកក់ក្ដៅដោយលោក ហ៊ូ នឹម ដែលជារដ្ឋមន្ត្រីក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលរួបរួមជាតិ និងលោក សុន សេន ជាប្រធានអគ្គសេនាធិការនៃកងទ័ពរំដោះប្រជានុរាស្ត្រកម្ពុជា[១៧] ព្រមទាំងអាជ្ញាធរពីររូបទៀតមកពីខេត្តស្ទឹងត្រែង។

សម្ដេច និងជនរួមជាតិរបស់យើងឱបគ្នាទៅវិញទៅមកដោយហទ័យញាប់ញ័រ និងសេចក្ដីត្រេកអរ។ អ្នកទាំងអស់គ្នាសើចហើយនិយាយក្នុងពេលតែមួយ! សម្ដេចមានព្រះរាជបន្ទូលថា "លោកមិនដឹងថាខ្ញុំសប្បាយចិត្តប៉ុណ្ណានោះទេដែលបានវិលត្រឡប់មកកាន់ប្រទេសកម្ពុជាម្ដងទៀត ហើយជួបជាមួយអស់លោកទាំងអស់គ្នា!" លោក ហ៊ូ នឹម និងលោក សុន សេន ឆ្លើយតបថា "យើងខ្ញុំទាំងអស់គ្នាបានទន្ទឹងរង់ចាំការយាងមកដល់របស់សម្ដេចជាយូរមកហើយ យើងខ្ញុំទាំងអស់គ្នាពិតជារីករាយក្រៃលែងដែលបានទទួលស្វាគមន៍សម្ដេចនៅថ្ងៃនេះ!" "ថ្ងៃនេះ គឺជាថ្ងៃប្រវត្តិសាស្ត្រនៃកំណាត់ត្រារបស់ប្រទេសកម្ពុជា!"

បន្ទាប់ពីសម្ដែងការគួរសមរួចមក សម្ដេចទ្រង់ក្រសោបយកដីមួយក្ដាប់ដៃពេញដាក់នៅក្នុងកន្សែងដៃរបស់ព្រះអង្គ បន្ទាប់មកសម្ដេចទ្រង់យកកញ្ចប់ដីជាទីសក្ការនៃមាតុភូមិជាទីស្នេហារបស់ព្រះអង្គ មកឱបជាប់ព្រះឱរា។ លោក ហ៊ូ នឹម ក៏បានយកដីខ្លះ រួចដាក់នៅលើកន្សែងដៃរបស់សម្ដេច ក្នុងកាយវិការជានិមិត្តរូបមួយ! បន្ទាប់មក យើងទៅសម្រាកនៅផ្ទះបណ្ដែតទឹកតូចមួយនៅប្រៀបនឹងទន្លេអូរតាង៉ូរ។

---

១៧. កំណត់សម្គាល់ពីអ្នកបកប្រែភាសាអង់គ្លេសៈ កងទ័ពរំដោះប្រជានុរាស្ត្រកម្ពុជា គឺជាពាក្យកាត់ក្នុងភាសាបារាំង។







សម្ដេចឪទ្រង់គង់នៅអង្គរ

យើងបានសំណេះសំណាលគ្នាអំពីព្រឹត្តិការណ៍ដែលបានកើតឡើងចាប់តាំងពីថ្ងៃធ្វើរដ្ឋប្រហារនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ យើងសោយទឹកដូងខ្មែរដែលលោក ហ៊ូ នឹម យកមកឲ្យ។ បន្ទាប់មកយើង បន្តដំណើរទៅកាន់គោលដៅរបស់យើង ដែលមានចម្ងាយប្រហែលជាសែសិបនាទីពីអូរតាង៉ូវ។ សម្តេច និងខ្ញុំមានអារម្មណ៍រំជើបរំជួល និងស្ងប់ចិត្តចំពោះការទទួលស្វាគមន៍យ៉ាងកក់ក្តៅ និងជាភាតរភាពពីជនរួមជាតិរបស់យើង។ យើងបានភ្លេចអស់នូវភាពនឿយហត់ពីការធ្វើដំណើរ ក្នុងរយៈពេលប្រាំបួនថ្ងៃកន្លងមកនេះ! លោក ហ៊ូ នឹម ជូនដំណឹងដល់យើងថា លោក ខៀវ សំផន នឹងទទួលស្វាគមន៍យើងនៅថ្ងៃទីពីរ ហើយលោក ហ៊ូ យន់ នឹងរង់ចាំទទួលស្វាគមន៍យើងនៅថ្ងៃទីបី!

នៅល្ងាចនោះ យើងទស្សនាទស្សនីយភាពសិល្បៈ សម្តែងដោយមិត្តវៀតណាមដែលបានរួមដំណើរមកជាមួយយើង។ យើងថែមទាំងទទួលបានសារជាញឹកញាប់ ពីមិត្តរបស់យើងនៅទីក្រុងហាណូយនិង ទីក្រុងប៉េកាំង ដែលសារទាំងនោះគឺពោរពេញទៅដោយសេចក្តីស្រឡាញ់ និងផ្តល់ឱ្យយើងនូវភាពស្ងប់ចិត្ត។

# ថ្ងៃទី ១០ ~ ថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៣

ខ្ញុំបានភ្ញាក់ពីដំណេកនៅម៉ោង ៧ និង ៣០នាទីព្រឹក បន្ទាប់ពីការលង់លក់ក្នុងរាត្រីមួយយ៉ាងស្កប់ស្កល់ និងជារាត្រីដំបូងលើទឹកដីខ្មែរ បន្ទាប់ពីឃ្លាតទៅអស់រយៈពេលបីឆ្នាំ ទោះបីជាមានយន្តហោះសត្រូវហោះពីលើយើងនៅម៉ោងប្រហែល ១០ និង ០០ នាទីកាលពីយប់មិញ និងម្តងទៀតនៅម៉ោង ៧ និង ០០ នាទីព្រឹកនេះក៏ដោយ។ ខ្ញុំពិតជាត្រេកអរណាស់ដែលអាចវិលត្រឡប់មកមាតុភូមិវិញ! ពេលព្រឹកបានបញ្ចប់ទៅយ៉ាងឆាប់រហ័ស ខណៈពេលដែលយើងសំណេះសំណាលជាមួយនឹងលោក ហ៊ូ នឹម និងលោក សុន សេន។ ក្មេងស្រីជនជាតិវៀតណាមមួយក្រុមបានយកផ្កាមកជូនខ្ញុំក្នុងឱកាសទិវាសិទ្ធិនារី។

បន្ទាប់មកយើងត្រូវបានអញ្ជើញឱ្យចូលរួមពិធីជប់លៀងមួយ ដែលរៀបចំឡើងដោយមិត្តវៀតណាម ដោយប្រព្រឹត្តទៅក្នុងបរិយាកាសស្និទ្ធស្នាល និងសាមញ្ញ។ នៅពេលល្ងាច រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា បានរៀបចំពិធីជប់លៀងមួយទៀត ដើម្បីអរគុណដល់មិត្តវៀតណាម និងអ្នកអមដំណើរមកជាមួយយើងដែលត្រូវបាកចេញពីទីនេះ ពីព្រោះចាប់ពីពេលនេះតទៅ ជនរួមជាតិកម្ពុជាជាអ្នករួមដំណើរ និងមើលថែទាំយើងវិញ។



សម្តេចឪ និងសម្តេចម៉ែ ព្រះអង្គរីករាយសោយផ្លែឈើខ្មែរ

# ថ្ងៃទី ១១ ~ ថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៧៣

យើងបន្តដំណើរនៅម៉ោង ៦ និង ០០ នាទីព្រឹក ហើយបន្ទាប់ពីធ្វើដំណើរអស់រយៈពេលបីម៉ោង យើងមកដល់ចំណុចតេ៥០។ នៅត្រង់ចំណុចនេះ យើងទទួលទានអាហារថ្ងៃត្រង់ ហើយសម្រាកបន្តិច។ ផ្លូវនេះស្រស់ស្អាត និងមានសត្វមាន់ព្រៃប៉ុន្មានក្បាលដើរយ៉ាងស្ងៀមស្ងាត់នៅតាមបណ្ដោយផ្លូវ។

នៅម៉ោង ១៥ និង ៣០ នាទី យើងចេញដំណើរម្តងទៀតដើម្បីទៅកន្លែងដែលលោក ខៀវ សំផន កំពុងរង់ចាំទទួលដំណើររបស់យើង។ ព្រៃស្រុកខ្មែរនៅតែស្រស់ស្អាត ទោះបីជាស្ថិតក្នុងអំឡុងពេលរដូវប្រាំងយ៉ាងណាក៏ដោយ។ រីឯទេសភាពព្រៃឈើ គឺស្ទើរតែនៅដដែល ហាក់បីដូចជាមិនទទួលរងភាពខូចខាតខ្លាំងពីការទម្លាក់គ្រាប់បែកនោះទេ។ បន្ទាប់ពីធ្វើដំណើរអស់ចម្ងាយប្រហែលសាមសិបពីរគីឡូម៉ែត្រ យើងបានជួបជាមួយនឹងលោក ខៀវ សំផន។ សម្ដេចនិងលោក ខៀវ សំផន ឱបគ្នា សំណេះសំណាលគ្នា និងសើចនៅក្នុងពេលតែមួយ!



សម្តេចឪ និងសម្តេចម៉ែ ជាមួយសត្វទោចដែលព្រះអង្គបិញ្ចឹម

លោក ខៀវ សំផន បានទូលសម្តេចថា“ប្រជាពលរដ្ឋខ្មែរពិតជាដឹងគុណសម្តេចណាស់! យើងខ្ញុំទាំងអស់គ្នារំពៃគិតដល់សម្តេចគ្រប់ពេលវេលា ហើយយើងខ្ញុំរីករាយជាពន់ពេកដែលបានស្វាគមន៍សម្តេចនៅថ្ងៃនេះ។ សូមសម្តេចវិលត្រឡប់មកមាតុភូមិវិញជាញឹកញាប់ហើយត្រឡប់មករស់នៅជាមួយយើងទាំងអស់គ្នាជារៀងរហូតទៅ ប្រសិនបើអាច!”

លោក សាឡុត ស[១៨] ដែលជាមេបញ្ជាការកងទ័ព និងមានកម្មាភិបាលជាន់ខ្ពស់មួយចំនួនផ្សេងទៀតក៏បានមកជាមួយលោក ខៀវ សំផន ដើម្បីទទួលស្វាគមន៍យើងដែរ។ ខ្ញុំសួរទៅកាន់លោក សាឡុត ស ថាតើខ្ញុំអាចជួបជាមួយនឹងភរិយារបស់លោកគឺ លោកស្រី ខៀវ ប៉ុណ្ណារី ក្នុងអំឡុងពេលដំណើរទស្សនកិច្ចរបស់យើងមកកាន់ប្រទេសកម្ពុជាបានដែរឬទេ? លោក សាឡុត ស យល់ស្របចំពោះសំណើរបស់ខ្ញុំ។ យើងសំណេះសំណាលគ្នាដោយក្តីរីករាយមុនពេលឡើងជិះទូក ខណៈដែលពេលល្ងាចហៀបនឹងមកដល់ ដើម្បីឆ្លងកាត់ទន្លេសេកុង។ យើងបានធ្វើដំណើរមកដល់ស្រុកសៀមប៉ាង។ នៅទីនេះ លោក ខៀវ សំផន បានរៀបចំពិធីជប់លៀងអាហារពេលល្ងាច។ នៅអំឡុងពេលដែលលោក ខៀវ សំផន កំពុងថ្លែងសុន្ទរកថាក្នុងពិធីជប់លៀង គេបានពន្លត់ភ្លើងចំនួនពីរដង ពីព្រោះថា យន្តហោះសត្រូវបានហោះកាត់ពីលើយើង ដើម្បីទម្លាក់គ្រាប់បែកនៅឆ្ងាយពីកន្លែងរបស់យើងបន្តិច។

លោក ខៀវ សំផន មិនបានបញ្ឈប់ការថ្លែងសុន្ទរកថាទេ គឺលោកបានបន្តទាំងក្នុងភាពងងឹត! បរិយាកាសនៅពេលនោះប្រព្រឹត្តទៅយ៉ាងកក់ក្តៅ! រាត្រីនេះបញ្ចប់ ទៅដោយរលូនទោះបីជាមានយន្តហោះសត្រូវទម្លាក់គ្រាប់បែកនៅតំបន់ក្បែរៗនោះក៏ដោយ។ ចាប់តាំងពីឈានចូលមកដល់ទឹកដីប្រទេសកម្ពុជាវិញ យើងបានឮសូរសំឡេងទម្លាក់គ្រាប់បែករបស់យន្តហោះសត្រូវកាន់តែសន្ធប់ទៅៗ។ បរិមាណគ្រាប់បែកដែលទម្លាក់ បានកើនឡើងជារៀងរាល់ថ្ងៃ។

---

១៨. កំណត់ហេតុអ្នកបកប្រែភាសាអង់គ្លេសៈ សាឡុត ស ដែលក្រោយមកត្រូវបានគេស្គាល់ថាជា ប៉ុល ពត គឺជាអគ្គលេខាធិការគណបក្សកុម្មុយនីស្តកម្ពុជា។ តាមរយៈដំណើររបស់សម្តេចព្រះនរោត្តម សីហនុ និងសម្តេចម៉ែ បានបង្ហាញឱ្យដឹងថា សាឡុត ស មិនបង្ហាញពីសមាសភាពពិតរបស់ខ្លួនក្នុងនាមជាមេដឹកនាំកម្មាភិបាលខ្មែរក្រហមជាន់ខ្ពស់នោះទេ។

# ថ្ងៃទី ១២ ~ ថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៧៣

យើងចេញដំណើរនៅម៉ោង ៣ និង ៣០ នាទីព្រឹក ឆ្ពោះទៅកាន់ថ្នល់ទទឹង។ នៅម៉ោងប្រហែលជា ៨ និង ០០ នាទី ឡានរបស់យើងបានបែកកង់។ ខណៈពេលកំពុងផ្លាស់ប្តូរសំបកកង់ឡាន យើងបានឮសូរសំឡេងយន្តហោះរបស់សត្រូវ។ បន្ទាប់មកក្នុងអំឡុងពេលធ្វើដំណើរនៅលើផ្លូវជាតិលេខ១៣ យើងបានឈប់ជាច្រើនលើកច្រើនសា នឹងថតរូបនៅក្បែរបង្គោលគីឡូម៉ែត្រដែលមានអក្សរសរសេរសម្គាល់ថា ក្រចេះ-ភ្នំពេញ។ ចាប់ពីម៉ោង ៣ និង ៣០ នាទីព្រឹករហូតដល់ ម៉ោង ៨ និង ០០ នាទី យើងធ្វើដំណើរតាមផ្លូវនៅក្នុងព្រៃ។ បន្ទាប់មក ចាប់ពីម៉ោង ៨ និង ០០ នាទី ដល់ម៉ោង ៩ និង ៣០ នាទី យើងបានបន្តដំណើរតាមបណ្តោយផ្លូវជាតិលេខ១៣ទៅមុខទៀត។ យើងធ្វើដំណើរតាមរថយន្តម៉ាកឡង់រ៉ូវ័រ។ លោក ខៀវ សំផន និងលោក ហ៊ូ នឹម ព្រមទាំងយុទ្ធជនម្នាក់អង្គុយនៅពីខាងក្រោយរីឯសម្តេច និងខ្ញុំគង់ក្បែរអ្នកបើកបរ។ ព្រៃឈើនៅក្នុងប្រទេសរបស់យើងគឺស្រស់ត្រកាលខ្លាំងណាស់ លាយឡំនឹងស្លឹកឈើពណ៌បៃតង និងពណ៌ត្នោតភ្លឺរលោង។

នៅពេលមកដល់ថ្នល់ទទឹង ត្រង់ចំណុចកែងព្រៃមួយ យើងរីករាយដែលបានជួបជាមួយនឹងភរិយារបស់លោក ហ៊ូ យន់[១៩] ដែលបានប្រាប់ថា ស្វាមីរបស់លោកស្រីរង់ចាំជួបជាមួយយើងនៅចំណុចឈប់សម្រាកបន្ទាប់។ លោកស្រីមានសុខភាពរឹងមាំ និងជាបុគ្គលប្រកបដោយសុទិដ្ឋិនិយម។ លោកស្រីបានរៀបចំអាហារខ្មែរដ៏ល្អឥតខ្ចោះសម្រាប់យើង!

នៅពេលរសៀល លោក ខៀវ សំផន បានសង្ខេបប្រាប់យើងអំពីស្ថានការណ៍នាពេលបច្ចុប្បន្ន។ បន្ទាប់មកសម្តេចបានព្រះរាជប្រទានអំណោយមួយចំនួនដែលយើងយកមកពីទីក្រុងប៉េកាំង និងទីក្រុងហាណូយជូនដល់ថ្នាក់ដឹកនាំចលនាតស៊ូនិងក្រុមយុទ្ធជន។ បន្ទាប់មក យើងបន្តថតខ្សែភាពយន្តឯកសារអំពីការធ្វើដំណើររបស់យើងតទៅទៀត។

ចាប់ពីម៉ោង ១១ និង ០០ នាទីព្រឹកមកទល់ពេលរសៀលនេះ យន្តហោះសត្រូវបានហោះកាត់កន្លែងយើងជាច្រើនដង ប៉ុន្តែជាសំណាងល្អ យន្តហោះសត្រូវមិនបានដឹងថាយើងនៅទីណានោះទេ ហើយក៏ហោះទៅទម្លាក់គ្រាប់បែកនៅកន្លែងដែលឆ្ងាយពីយើង។ ទោះបីជាយ៉ាងណាក្តី ក៏យើងនៅតែអាចឮសូរសំឡេងគ្រាប់បែកផ្ទុះនៅជិតទន្លេសេកុង លើផ្លូវលំសីហនុដែរ។

---

១៩. កំណត់ហេតុរបស់អ្នកបកប្រែភាសាអង់គ្លេស៖ ភរិយារបស់លោក ហ៊ូ យន់។ លោក ហ៊ូ យន់ គឺជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងជាមនុស្សម្នាក់ក្នុងចំណោមក្រុមមួយដែលមានឈ្មោះថា "ខ្មោច" ដែលត្រូវបានរាយការណ៍ថា គឺជាក្រុមមនុស្សដែលត្រូវបានសម្លាប់ដោយសម្តេច នរោត្តម សីហនុ នៅទសវត្សរ៍ឆ្នាំ ១៩៦០ នេះបើតាមការអះអាងរបស់អ្នកសិក្សាស្រាវជ្រាវជនជាតិអូស្ត្រាលីម្នាក់។ តាមការពិត លោក ហ៊ូ យន់ បានគេចខ្លួនចូលទៅក្នុងព្រៃ ហើយគឺជាមនុស្សម្នាក់ក្នុងចំណោមមនុស្សដំបូងដែលបានកាន់អាវុធប្រឆាំងនឹង លន់ នល់។ ខ្មែរក្រហមបានប្រហារជីវិតលោក ហ៊ូ យន់ នៅក្នុងខែសីហា ឆ្នាំ១៩៧៥។


55


528
ក្រចេះ
189


525
525

# ថ្ងៃទី ១៣ ~ ថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៣

យើងភ្ញាក់ពីដំណេកនៅម៉ោង ៧ និង ០០ នាទី រួមជាមួយនឹងសូរសំឡេងបក្សីយំចេចចាច! យើងសម្រាន្តលង់លក់យ៉ាងស្កប់ស្កល់ ទោះបីជាមានយន្តហោះសត្រូវហោះកាត់ក៏ដោយ ពីព្រោះថាយើងពិតជានឿយហត់ខ្លាំងណាស់។ គិតចាប់តាំងពីពេលចាកចេញដំណើរលើកដំបូងរបស់យើងពីទីក្រុង ហាណូយមក យើងអាចទម្លាប់ជាមួយនឹងជីវិតរស់នៅក្នុងព្រៃទៅហើយ។

ចំពោះយើង ព្រៃឈើនៅស្រុកខ្មែររបស់យើង មានសម្រស់ស្អាតជាងគេបំផុតនៅលើពិភពលោក។ ភរិយា លោក ហ៊ូ យន់ បានប្រាប់ខ្ញុំថាជីវិតរស់នៅក្នុងព្រៃគឺពិតជាមានភាពងាយស្រួលសម្រាប់លោកស្រី និងអ្នកតស៊ូដទៃទៀត។ តាមពិតទៅ ខ្ញុំធ្លាប់បានជួបលោកស្រីនៅក្នុងទីក្រុងភ្នំពេញនៅមុនពេលសង្គ្រាមដែរ។ នៅពេលនោះ លោកស្រីមានរូបរាងស្គមស្គាំង និងស្លេកស្លាំងណាស់ ក៏ប៉ុន្តែឥឡូវនេះ ខ្ញុំឃើញថាលោកស្រីមានសាច់មានឈាមជាងមុន ហើយមានសម្បុរស្រអែមដោយសារត្រូវដុតកម្លោចដោយកម្តៅព្រះអាទិត្យ។ ស្ត្រីខ្មែរទាំងអស់ដែលខ្ញុំបានជួបមានសុខភាពល្អ និងពោរពេញទៅដោយសុទិដ្ឋិនិយម។

ចាប់តាំងពីព្រឹកនេះរហូតដល់ពេលរសៀល យន្តហោះសត្រូវធ្វើសកម្មភាពជាច្រើនលើកច្រើនសា ហើយបានហោះកាត់ពីលើយើងជាញឹកញាប់ ដើម្បីទៅទម្លាក់គ្រាប់បែកនៅចម្ងាយប្រហែលជាដប់គីឡូម៉ែត្រពីកន្លែងរបស់យើង។ យន្តហោះទាំងនេះ ពិតជាគួរឱ្យរំខានណាស់!

យោងតាមកម្មាភិបាលម្នាក់ដែលមកពីខេត្តក្រចេះបានប្រាប់យើងថានេះគឺជាលើកដំបូង ក្នុងរយៈពេលបីឆ្នាំកន្លងមក ដែលគាត់បានឃើញយន្តហោះសត្រូវជាច្រើននៅក្នុងតំបន់នេះ។ ពីមុន តំបន់នេះស្ងប់ស្ងាត់ល្អណាស់។



សម្តេចម៉ែគង់នៅលើអង្រឹងជជែកគ្នាជាមួយភរិយារបស់លោក ហ៊ូ យន់



សម្តេចម៉ែ និងភរិយារបស់លោក ហ៊ូ យន់

សត្រូវច្បាស់ជាមានការសង្ស័យអំពីការវិលត្រឡប់របស់យើង មកកាន់ប្រទេសកម្ពុជាវិញជាក់ជាមិនខាន។ ហេតុនេះហើយ ទើបពួកសត្រូវកំពុងតាមស្វែងរកយើង! នៅពេលរសៀល គេបានទម្លាក់គ្រាប់បែកនៅចម្ងាយតែប៉ុន្មានគីឡូម៉ែត្រពីកន្លែងរបស់យើងប៉ុណ្ណោះ។ ដូច្នេះ ជនរួមជាតិរបស់យើងបានសម្រេចចិត្តផ្លាស់ប្ដូរកន្លែងភ្លាមៗ ពីព្រោះថាកន្លែងនេះមាន "គ្រោះថ្នាក់" ពេក។ ឆ្លៀតពេលដែលស្ថានភាពស្ងប់ស្ងាត់បន្តិច យើងក៏បានចាកចេញពីកន្លែងនោះនៅម៉ោងប្រហែល ១៨ និង ៣០ នាទី តាមរថយន្តម៉ែកហ្ស៊ីដេសពណ៌សដែលមានគ្របបិតបាំងបន្លំភ្នែកទាំងស្រុងដោយមែកឈើ និងស្លឹកឈើ។ យើងបានប្រើប្រាស់រថយន្តនេះសម្រាប់ធ្វើដំណើរតាំងពីម៉្សិលមិញមកម៉្លេះ ពីព្រោះថារថយន្តឡង់រ៉ូវ័របានខូចបាត់ទៅហើយ! យើងបានធ្វើដំណើរតាមបណ្ដោយផ្លូវជាតិលេខ១១៣ ប៉ុន្តែត្រូវឈប់ជាច្រើនដងដោយសារតែយន្តហោះសត្រូវ។ អ្នកតស៊ូរបស់យើងមួយចំនួន តាំងទីឈរយាមកាមនៅតាមដងផ្លូវ ហើយរាល់ពេលដែលស្ដាប់ឮសូរសំឡេងយន្តហោះសត្រូវ ពួកគាត់ នឹងបាញ់កាំភ្លើងឡើងទៅលើមេឃចំនួនពីរដង ដើម្បីផ្ដល់សញ្ញាមកយើង។

ខ្ញុំត្រូវសម្ដែងការអរគុណដល់ពន្លឺព្រះចន្ទ ដែលធ្វើឱ្យអ្នកបើកបររថយន្តម៉ែកហ្ស៊ីដេសរបស់យើង អាចបើកបរទៅមុខដោយមិនចាំបាច់ប្រើប្រាស់ភ្លើងចង្កៀងឡាន។ ទីបំផុតយើងបានមកដល់ច្រាំងទន្លេមេគង្គ។ បន្ទាប់មក យើងឡើងជិះកាណូតឆ្លងកាត់ទឹកទន្លេ ដែលមានសភាពស្ងប់ស្ងាត់។ នៅពេលយើងឆ្លងទៅដល់ត្រើយម្ខាងទៀតនៃទន្លេ យន្តហោះសត្រូវក៏បានបោះពួយមកវិញម្ដងទៀត។ យើងទាំងអស់គ្នាអង្គុយនៅក្នុងរថយន្តហ្ស៊ីប នៅខាងក្រោមដើមឈើធំដោយស្ងៀមស្ងាត់ និងទទួលទានផ្លែឪឡឹកដែលយុទ្ធជនរបស់យើងយកមកជូន។ ប្រសិនបើអ្នកបើកបរយន្តហោះសត្រូវ ដែលហោះនៅពីលើយើងដឹង ពួកគេប្រាកដជា "គាំងបេះដូងស្លាប់" ជាក់ជាមិនខាន!

ក្នុងអំឡុងពេលធ្វើដំណើរឆ្លងកាត់ទន្លេមេគង្គ យើងក៏បានឆ្លងកាត់ទីរួមខេត្តស្ទឹងត្រែង។ ប៉ុន្តែយើងមិនអាចមើលឃើញអ្វីទាំងអស់ ពីព្រោះថាមេឃងងឹតខ្លាំងពេក។ យើងអាចមើលឃើញតែពន្លឺភ្លើងព្រឹមៗចេញពីផ្ទះប្រជានុរាស្ត្រខ្លះតែប៉ុណ្ណោះ។ បន្ទាប់ពីយន្តហោះសត្រូវចាកចេញទៅ យើងបន្តដំណើរទៅមុខទៀតតាមរថយន្តហ្ស៊ីប ដែលមិត្តវៀតណាមបានឱ្យយើងខ្ចីប្រើប្រាស់។ នៅពេលធ្វើដំណើរតាមផ្លូវ យើង ត្រូវបិទភ្លើងចង្កៀងឡានជានិច្ច។ យើងបានមកដល់ស្រុកអន្លង់ក្រមួន ដែលស្ថិតនៅក្នុងព្រៃ។

ដោយសារយើងមិនបានយកសម្ភារផ្ទាល់ខ្លួនមកជាមួយ យើងត្រូវសម្រាកដំណេកនៅក្នុងអង្រឹងរហូតដល់ព្រឹកព្រលឹម។ នេះគឺជាបទពិសោធន៍ថ្មីមួយទៀតសម្រាប់យើង! ខ្ញុំមិននឹកស្មានថា អាកាសធាតុនៅក្នុងព្រៃត្រជាក់ខ្លាំងនៅក្នុងអំឡុងខែមីនានោះទេ! ខ្ញុំរងារញ៉័រខ្លួននៅពេលយប់ ហើយសំឡេងរំខានឥតស្រាកស្រាន្តចេញពីយន្តហោះរបស់សត្រូវបានរារាំងមិនឱ្យខ្ញុំសម្រាកបានស្រួលនោះទេ។ គេប្រាកដជាគិតថា យើងបានទាក់ទាញយន្តហោះសត្រូវទាំងនោះ បីដូចជាទឹកឃ្មុំទាក់ទាញរុយយ៉ាងដូច្នោះដែរ!

# ថ្ងៃទី ១៨ ~ ថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៧៣

ចាប់ផ្តើមចេញដំណើរនៅម៉ោង ៦ និង ០០ នាទីព្រឹក យើងចាកចេញពីខេត្តស្ទឹងត្រែង ហើយបន្តដំណើរឆ្លងកាត់ខេត្តព្រះវិហារដែលមានព្រៃឈើដ៏អស្ចារ្យ! ព្រៃនេះមានរុក្ខជាតិ ដែលស្រដៀងទៅនឹងដើមត្នោតមួយប្រភេទ ដែលមានសារប្រយោជន៍យ៉ាងខ្លាំងសម្រាប់ធ្វើជាដំបូលផ្ទះ ជញ្ជាំង ធុងទឹក ផ្ចិតបក់ បាវ កន្ទេល ... ផ្លូវដែលយុទ្ធជនរបស់យើងទើបតែកសាងរួចរាល់មានសភាពល្អ ហើយយើងបានមកដល់គោលដៅរបស់យើង គឺស្រុកកំពង់ក្រោមមុនពេលកំណត់។ ក្នុងអំឡុងពេលធ្វើដំណើរ យើងត្រូវឈប់ជាច្រើនដងដោយសារតែយន្តហោះសត្រូវ។ នៅពេលមួយ យើងថែមទាំងត្រូវបង្ខំចិត្តចាកចោលរថយន្តហ្ស៊ីប របស់យើង ដើម្បីជ្រកលាក់ខ្លួនក្រោមដើមឈើក្នុងអូរតូចមួយដែលស្ងួតហែងទៀតផង។

ស្រុកកំពង់ក្រោម គឺជាកន្លែងដែលស្រស់ស្អាត និងមានម្លប់ដើមឈើត្រជាក់រហឹម! ខ្ទមតូចមួយដែល បានរៀបចំសម្រាប់យើងត្រូវបានសាងសង់ឡើងដោយប្រើប្រាស់ដើមត្នោតមួយប្រភេទ។ ក្រុមថតរបស់យើងបានថតសកម្មភាពជាច្រើនឈុតនៅក្នុងខ្ទមនេះ ហើយសម្តេចបានសម្អាតព្រះកាយតាមបែបខ្មែរ ដោយដួសទឹកពីពាងធំមួយធ្វើអំពីដីឥដ្ឋ ស្រោចលើព្រះកាយរបស់ព្រះអង្គ។ នៅម៉ោង ១៩ និង ០០ នាទី យើងបានចាកចេញពីទីសំចតនេះ ហើយក្នុងអំឡុងពេលធ្វើដំណើរយើងត្រូវឈប់ជាច្រើនដងទៀត ទោះបីជាយើងធ្វើដំណើរដោយបិទភ្លើងចង្កៀងឡានក៏ដោយ។ ពន្លឺព្រះចន្ទបានបំភ្លឺនាំផ្លូវយើង។ សត្រូវបានទម្លាក់គ្រាប់បែក នៅខាងស្តាំដៃចម្ងាយប៉ុន្មានគីឡូម៉ែត្រប៉ុណ្ណោះ ពីផ្លូវដែលយើងកំពុងធ្វើដំណើរ។ សត្រូវបន្តទម្លាក់គ្រាប់បែកឥតឈប់ឈរអស់រយៈពេលជាច្រើនម៉ោង។ អណ្តាតភ្លើងឆាបឆេះឡើងនៅត្រង់ទីតាំងគោលដៅរបស់សត្រូវ ដែលមើលទៅដូចជាឃ្លាំងឱសថមួយ។ សកម្មភាពទម្លាក់គ្រាប់បែកបានកើតឡើងអស់រយៈពេលបីយប់មកហើយ។ ប្រហែលជាពួកសត្រូវគិតថា យើងនៅទីនោះហើយមើលទៅ! សត្រូវប្រាកដជាចង់ចាប់ខ្លួនយើង!

នៅពេលយើងមកដល់ទីតាំងដែលត្រូវឈប់សម្រាក គឺនៅម៉ោង ២២ និង ៣០ នាទី សម្តេចត្រូវបានទទួលស្វាគមន៍ យ៉ាងកក់ក្តៅដោយលោក ហ៊ូ យន់ ដែលគេស្គាល់ថាជា "ខ្មោចទីបី"! អ្នកទាំងពីរបានឱបគ្នា និងសំណេះសំណាលគ្នាយ៉ាងសប្បាយរីករាយ ... គ្រប់គ្នាមានអារម្មណ៍សប្បាយចិត្តយ៉ាងខ្លាំង។ យើងមើលឃើញថាលោក ហ៊ូ យន់ មានសុខភាពល្អ។ លោកមានសាច់មានឈាមជាងមុន និងនិយាយច្រើនជាងមុន បើប្រៀបទៅនឹងពេលមុនសង្គ្រាម។ រួមដំណើរមកជាមួយលោក ហ៊ូ យន់ គឺលោក នួន ជា[២០] ដែលជាសមាជិកថ្នាក់ដឹកនាំជាន់ខ្ពស់ម្នាក់ដែរ។

ពេញមួយយប់ សត្រូវបើកយន្តហោះប្រភេទ សេ១៣០ មកទម្លាក់គ្រាប់បែកនៅក្បែរៗជំរំរបស់យើង។ អ្នករាល់គ្នា ភ្ញាក់ពីដំណេក ហើយជ្រកនៅក្បែរៗជម្រកលាក់ខ្លួន។

បន្ទាប់ពីកន្លះម៉ោងកន្លងផុតទៅ យើងបន្តឮសូរសំឡេងគ្រាប់បែកទម្លាក់ពីសំណាក់សត្រូវនៅកន្លែងផ្សេងទៀត យើងក៏នាំគ្នាត្រឡប់ទៅសម្រាន្តវិញ។ ប្រហែលជាសត្រូវយល់ច្រឡំថាដើមឈើនោះគឺជាអ្នកតស៊ូរបស់យើងហើយមើលទៅ? នៅថ្ងៃបន្ទាប់ គឺថ្ងៃទី១៣ ខែមីនា ជនរួមជាតិរបស់យើងប្រាប់ថាសត្រូវបានធ្វើសកម្មភាពឥតល្ហែរពេញមួយយប់ដោយទម្លាក់គ្រាប់បែកដៅទៅលើដើមត្នោតមួយចំនួនដែលស្ថិតនៅក្បែរជំរំដែលចលនាតស៊ូរបស់យើងបោះបង់ចោល។ ជាលទ្ធផលព្រឹកនេះ យើងមិនមានទឹកត្នោតទទួលទាននោះទេ!

---

២០. កំណត់សម្គាល់អ្នកបកប្រែភាសាអង់គ្លេសៈ នួន ជា ទទួលបានការអប់រំនៅប្រទេសថៃ និងទទួលការបណ្តុះបណ្តាលមនោគមន៍វិជ្ជាកុម្មុយនីស្តនៅទីក្រុងហាណូយ។ នួន ជា បានកាន់កាប់តំណែងជារដ្ឋមន្ត្រី និងតំណែងក្នុងគណបក្សជាច្រើនក្នុងឆ្នាំ១៩៩៨ ក៏ដូចជាចូលរួមជាមួយនឹងរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន។ នួន ជា បានស្លាប់នៅក្នុងពន្ធនាគារក្នុងឆ្នាំ ២០១៩ បន្ទាប់ពីត្រូវបានកាត់ទោស និងត្រូវផ្តន្ទាទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិត។

# ថ្ងៃទី ១៥ ~ ថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៣

មកទល់ថ្ងៃនេះ យើងបានចាកចេញពីទីក្រុងហាណូយអស់រយៈពេលពីរសប្តាហ៍គត់។ ឥឡូវ ខ្ញុំបានស៊ាំទៅនឹងការរស់នៅក្នុងជីវិតបែបពនេចរ ដោយធ្វើដំណើរពីព្រៃមួយទៅព្រៃមួយទៀត ស៊ាំទៅនឹងការធ្វើដំណើរពេលយប់ ស៊ាំជាមួយនឹងផ្លូវថ្មល់ និងផ្លូវរទេះដែលរលាក់ និងហុយទ្រលោមទៅហើយ...នេះគឺជាជីវិតដែលអ្នកតស៊ូរបស់យើង បានរស់នៅអស់រយៈពេលបីឆ្នាំកន្លងមកនេះ។ ការដែលអាចចែករំលែកបែបផែនក្នុងការរស់នៅបែបដូចទៅនឹងអ្នកតស៊ូរបស់យើង ក្នុងរយៈពេលប៉ុន្មានសប្តាហ៍នេះ បានពង្រឹងសាមគ្គីភាព និងធ្វើឱ្យស្មារតីរបស់យើងរឹងប៉ឹងជាងមុន ព្រមទាំងបង្កើនការគោរពគ្នាទៅវិញទៅមកថែមទៀតផង។

នៅថ្ងៃមុខ យើងអាចនិយាយប្រកបដោយមោទកភាពថា យើងបានឆ្លងកាត់ជីវិតរស់នៅ "ក្នុងព្រៃម៉ាគី"[២១] ទោះបីជាមួយរយៈពេលខ្លីក៏ដោយ។ យើងមានសេចក្តីសុខជាពន់ពេក ដែលអាចរស់នៅជាមួយអ្នកតស៊ូរបស់យើង និងអាចឆ្លងកាត់គ្រោះថ្នាក់រួមគ្នាបានរហូតមកដល់ពេលនេះ។ សូម្បីតែសកម្មភាពសាហាវព្រៃផ្សៃរបស់យន្តហោះសត្រូវ ក៏មិនអាចបំបាក់ស្មារតីមួយនេះបានដែរ។

សម្តេច និងខ្ញុំទទួលបានការពិនិត្យសុខភាពជារៀងរាល់ថ្ងៃ ពីសំណាក់វេជ្ជបណ្ឌិតប្រុសពីរនាក់ និងវេជ្ជបណ្ឌិតស្រីម្នាក់ ដែលបានចាត់តាំងដោយលោក ខៀវ សំផន។ សុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់យើងទាំងពីរនាក់គឺល្អប្រសើរណាស់។ នៅល្ងាចនេះ ការធ្វើដំណើររបស់យើងមិនអាចប្រព្រឹត្តទៅបាននោះទេ។ នៅម៉ោងប្រហែល ១៩ និង ០០ នាទី ថ្នាក់ដឹកនាំចលនាតស៊ូក្នុងប្រទេស ដឹកនាំដោយ លោក ខៀវ សំផន ស្នើសុំឱ្យយើងពន្យារពេលធ្វើដំណើរមួយថ្ងៃ ពីព្រោះថា យោងតាមព័ត៌មានដែលទទួលបាន សត្រូវកំពុងធ្វើសកម្មភាពយ៉ាងគំហុកលើក្នុងលំហអាកាស នៅពីលើដងផ្លូវដែលយើងត្រូវធ្វើដំណើរឆ្លងកាត់។ នៅយប់នេះ យន្តហោះសត្រូវ ហាក់ដូចជាថមថយបុះបន្តិច ប៉ុន្តែសត្រូវបានទម្លាក់គ្រាប់បែកឥតឈប់ឈរទៅលើកន្លែងដែលយុទ្ធជនរបស់យើងកំពុងឈរជើងប្រយុទ្ធតស៊ូ គឺនៅក្នុងខេត្តតាកែវ ជុំវិញទីក្រុងភ្នំពេញ និងនៅលើផ្លូវជាតិលេខ ១។

---

២១. ព្រៃម៉ាគី សំដៅដល់ព្រៃដែលមានស្តេចយាងទៅដល់។



សម្តេចឪ  ព្រះអង្គរៀបចំព្រះកេសានៅក្នុងផ្ទះនៅលើភ្នំគូលែន

# ថ្ងៃទី ១៦ ~ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៣

នៅព្រឹកនេះ យើងបានធ្វើការពិភាក្សាខ្លះៗជាមួយលោក ខៀវ សំផន លោក ហ៊ូ យន់ លោក ហូ នឹម និង លោក សុន សេន។ យើងបន្តថតភាពយន្តឯកសារ និងថតរូបមួយចំនួន។ ម្តងម្កាល យើងឮសូរសំឡេងយន្តហោះសត្រូវហោះនៅពីលើយើងដែរ។

យើងចាកចេញពីទីកន្លែងនេះនៅម៉ោង ១៨ និង ៣០ នាទី ហើយបានឈប់ចំនួនពីរទៅបីដងក្នុងអំឡុងពេលធ្វើដំណើរ ដោយសារតែវត្តមានរបស់យន្តហោះសត្រូវ ជាពិសេសយន្តហោះប្រភេទ សេ១៣០ នោះតែម្តង។ យើងបានទៅដល់ និងសំចតនៅទីតាំងគោលដៅចំនួនពីររួចមកហើយ បន្ទាប់មក យើងក៏មកដល់គោលដៅទីបី គឺអូរក្បាលឈ្លូស ដែលសរុបមក យើងបានធ្វើដំណើរអស់ចម្ងាយជាងបីរយគីឡូម៉ែត្រមកហើយ។ គោលដៅដែលយើងបានមកដល់នៅម៉ោង ១ និង ០០ នាទីនេះ គឺខេត្តសៀមរាប។ យើងបានធ្វើដំណើរឆ្លងកាត់ខេត្តចំនួនបី គិតចាប់តាំងពីយើងបានមកដល់ប្រទេសកម្ពុជា ក្នុងនោះរួមមានខេត្តស្ទឹងត្រែង ខេត្តព្រះវិហារ និង ខេត្តសៀមរាប។

# ថ្ងៃទី ១៧ ~ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៣

ហេតុការណ៍ដ៏គួរឱ្យអស់សំណើចមួយបានកើតឡើងនៅម៉ោងប្រហែល ៩ និង ០០ នាទីព្រឹកនេះ។ អង្គរក្សខ្មែរពីរនាក់ឈ្មោះថា ហុង និង ប៉ាង ដែលទទួលបន្ទុករក្សាសុវត្ថិភាពរបស់យើង បានមកដាស់យើងឱ្យភ្ញាក់ពីដំណេកភ្លាមៗ។ អ្នកទាំងពីរបានប្រាប់ឱ្យយើងចូលទៅក្នុងជម្រកលាក់ខ្លួន ពីព្រោះយន្តហោះប្រភេទ សេ១៣០ របស់សត្រូវកំពុងហោះកាត់លើកន្លែងរបស់យើងហើយ។ អ្នកទាំងពីរប្រាប់យើងថា យន្តហោះសត្រូវបានទម្លាក់គ្រាប់បែកនៅជិតកន្លែងរបស់យើង។ តាមពិតទៅយើងអាចមើលឃើញពន្លឺរន្ទាលនៅលើផ្ទៃមេឃ។ នៅពេលដែលកំពុងលាក់ខ្លួនក្នុងជម្រក យើងឆ្ងល់ថាតើសត្រូវ អាចស្វែងរកយើងឃើញបានដោយរបៀបណា? ពីព្រោះយើងលាក់ខ្លួនបានយ៉ាងជិតល្អនៅក្នុងព្រៃឈើដ៏ស្រស់ស្អាតនៃខេត្តសៀមរាប!

នៅប៉ុន្មាននាទីក្រោយមក អគ្គសេនាធិការ គឺលោក សុន សេន បានចូលមក និងប្រាប់យើងថា យន្តហោះសត្រូវបានទៅបាត់អស់ហើយ។ រីឯពន្លឺរន្ទាលដែលយើងឃើញនៅលើផ្ទៃមេឃនោះ គឺមិនមែនជាអណ្តាតភ្លើងពីការទម្លាក់គ្រាប់បែកនោះទេ។ ពន្លឺនោះកើតមានដោយសារតែមេឃជិតភ្លៀងទៅវិញទេ! យើងទាំងអស់គ្នានាំគ្នាសើច! មួយម៉ោងក្រោយមក យើងឮស្នូរសំឡេងផ្គរលាន់ មានរន្ទះ ផ្លេកបន្ទោរ និងភ្លៀងធ្លាក់! នេះគឺជាភ្លៀងធ្លាក់លើកដំបូងបង្អស់ក្នុងឆ្នាំនេះ ដោយប្រជានុរាស្ត្រកម្ពុជាហៅថា“ភ្លៀងកក់ខែ”។ ហើយនេះក៏ជាលើកទីមួយដែលយើងឃើញភ្លៀងធ្លាក់ដំបូងបង្អស់ “នៅក្នុងប្រទេសកម្ពុជា” ចាប់តាំងពីយើងចាកចេញទៅអស់រយៈពេលបីឆ្នាំ។





សម្តេចម៉ែ ព្រះលិខិតលើសៀវភៅកំណត់ហេតុ

នៅពេលដែលខ្ញុំកំពុងសរសេរសៀវភៅកំណត់ហេតុនេះ មេឃកំពុងបង្អុរភ្លៀង.....នៅពេលរសៀល យើងបានប្រគល់អំណោយដល់យុទ្ធជនដែលនឹងបន្តរង់ចាំនៅទីកន្លែងនេះ រហូតដល់យើងវិលត្រឡប់មកវិញ។ នៅម៉ោង ១៨ និង ៣០ នាទី បន្ទាប់ពីរាំងភ្លៀង ពពកមីដេជាសពេញផ្ទៃមេឃ យើងក៏បន្តដំណើរទៅមុខទៀត។ ធ្វើដំណើរតាមផ្លូវដោយរក្សាភ្លើងចង្កៀងរថយន្តបិទជានិច្ច យើងបានទៅដល់គោលដៅដោយសុវត្ថិភាព បន្ទាប់ពីចំណាយពេល អស់រយៈពេលប្រាំម៉ោងកន្លះ ដើម្បីឆ្ពោះទៅកាន់ភ្នំគូលែន ដែលមានន័យថា "ភ្នំដែលមានដើមគូលែន"។

នៅពេលមើលឃើញទីកន្លែងនេះម្តងទៀត យើងមានអារម្មណ៍ជ្រួលច្របល់ពិបាកនឹងពិពណ៌នាណាស់! យើងត្រូវបានទទួលស្វាគមន៍យ៉ាងកក់ក្តៅដោយលោក កុយ ធួន និង ភរិយារបស់លោក ព្រមទាំងលោកស្រី ខៀវ ប៉ុណ្ណារី ដែលជាប្រធានសហភាពស្ត្រីកម្ពុជាប្រជាធិបតេយ្យ រួមជាមួយនឹងយុទ្ធជន យុទ្ធនារីរាប់រយនាក់ទៀត។

ដើរឆ្លងកាត់ស្ទូរទះដៃទ្រហឹងអឹងកងបណ្តើរ ចាប់ដៃបណ្តើរជាមួយមនុស្សជាច្រើន យើងបានដើរឆ្លងកាត់ខាងមុខក្រុមយុទ្ធជនដែលឈរជាជួរទាំងសងខាង។ បន្ទាប់មក យើងបានមកដល់ផ្ទះឈើតូចមួយ មានដំបូលប្រក់ស្បូវ។ ផ្ទះនេះត្រូវបានសាងសង់ជាពិសេសសម្រាប់យើង។ ផ្ទះនេះគឺជា "សេតវិមាន" របស់យើងនៅក្នុងតំបន់រំដោះ! ខ្ញុំស្រឡាញ់សំណង់ដែលមានរចនាបថបែបខ្មែរនេះខ្លាំងណាស់។

ផ្នែកខាងក្នុងផ្ទះក៏ស្អាតដែរ ហើយត្រូវបានតុបតែងប្រកបដោយសោភ័ណភាព។ ផ្ទះនេះ មានបន្ទប់សិក្សាមួយ បន្ទប់ទទួលភ្ញៀវតូចមួយ។ នៅចំកណ្តាលមានរាំងននមួយផ្ទាំង បាំងចែក បន្ទប់សិក្សា និងបន្ទប់ទទួលភ្ញៀវ ដាច់ដោយឡែកពីបន្ទប់គេង។ នៅក្នុងបន្ទប់គេង មានគ្រែមួយ តុមួយ ទូដាក់សម្លៀកបំពាក់មួយ និង "ក្តារជើ" មួយ។

ផ្ទះនេះថែមទាំងមានក្រាលព្រំក្រហម និងមានព្យួររាំងននៅជាប់នឹងបង្អួចតូចៗថែមទៀត។ នៅក្នុងផ្ទះក៏មានរុក្ខជាតិពណ៌បៃតង និងបានប្រាក់ធំមួយសម្រាប់ដាក់ទឹក.....ជាការពិតណាស់ បងប្អូនយុទ្ធជន បានរៀបចំលំអផ្ទៃក្នុងនៃផ្ទះនេះយ៉ាងពិសេសដើម្បីទទួលស្វាគមន៍យើង។ ចាប់តាំងពីយើងចាប់ផ្តើមធ្វើដំណើរមកនេះគឺជាលើកដំបូងដែលយើងមានផ្ទះ ដ៏ស្រស់ស្អាតបែបនេះ។ ផ្ទះនេះ ហ៊ុមព័ទ្ធទៅដោយដើមឈើពណ៌បៃតងដែលមាន អាយុកាលដ៏យូរលង់ណាស់មកហើយ។ ផ្ទះនេះ ហ៊ុមព័ទ្ធដោយរបង និង មានផ្កាអ័រគីដេព្យួរនៅច្រកចេញចូលថែមទៀតផង! ខ្ញុំពិតជាចង់រស់នៅទីនេះជាមួយសម្តេចរហូតដល់ថ្ងៃរំដោះណាស់! ប៉ុន្តែគួរឱ្យសោកស្តាយ យើងត្រូវតែចាកចេញនៅពេលឆាប់ៗនេះ ពីព្រោះយើងត្រូវបន្តបេសកកម្មនៅក្រៅ មាតុភូមិដើម្បីកម្លាំងជួរមុខ និងប្រជាជនកម្ពុជា។ ប៉ុន្តែខ្ញុំសូមមិននិយាយអំពីការចាកចេញនៅពេលនេះទេ ពីព្រោះការចាកចេញពីទីនេះគឺពិតជាគួរឱ្យសោកសៅណាស់!

# ថ្ងៃទី ១៨ ~ ថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៧៣

យប់ទីមួយរបស់យើងនៅភ្នំគូលែនបានបញ្ចប់ទៅដោយរលូន។ ខ្ញុំមិនបានឮសូរ សំឡេងយន្តហោះសត្រូវនោះទេ។ នៅម៉ោងប្រហែល ៧ និង ០០ នាទីព្រឹក យើងបានភ្ញាក់ពីដំណេកដោយសារតែសំឡេងចម្លែកមួយ។ នៅពេលដែលយើងចេញមកខាងក្រៅផ្ទះ យើងបានឃើញសត្វទោច ចំនួនពីរក្បាល និងខ្លាឃ្មុំខ្មៅមួយក្បាល! លោក កុយ ធួន បានយកសត្វទាំងនេះមកដើម្បីកំដរយើង!

នៅម៉ោងប្រហែលជា ១០ និង ០០ នាទី យើងទាំងអស់គ្នាធ្វើដំណើរទៅកាន់ទឹកជ្រោះ។ ថ្នាក់ដឹកនាំទាំងអស់នៃចលនាតស៊ូនៅក្នុងប្រទេស និងកម្មាភិបាលដទៃទៀតបានអមដំណើរមកជាមួយយើង។ ខ្ញុំសប្បាយរីករាយខ្លាំងណាស់ ដែលមានឱកាសមកកាន់ទីកន្លែងទាំងអស់នេះម្តងទៀត ពីព្រោះកាលពីមុន ខ្ញុំតែងតែធ្វើដំណើរមកកាន់ទីនេះ។ យើងបានថតរូបជាច្រើនសន្លឹក ហើយបន្តថតសកម្មភាពផ្សេងៗសម្រាប់ខ្សែភាពយន្ត។ នៅពេលរសៀល យើងទៅទស្សនាទន្លេដែលមានចម្លាក់ថ្ម។ សម្តេចបានចុះសម្អាតព្រះកាយដោយសេចក្តីរីករាយ ប៉ុន្តែទឹកនេះត្រជាក់ដូចទឹកកក! ខ្ញុំមិនហ៊ានចុះងូតទេ!



សម្តេចឪ និងសម្តេចម៉ែទ្រង់គង់នៅលើភ្នំគូលែន

# ផ្នែកទី៣
# ការឃោងជួបជាមួយប្រជានុរាស្ត្រកម្ពុជា



# ថ្ងៃទី ១៩ ~ ថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៣

នៅពេលព្រឹកម៉ោង ៨ និង ០០ នាទី សម្តេចទ្រង់ជួបប្រជុំជាមួយថ្នាក់ដឹកនាំនៃចលនាតស៊ូ។ អង្គប្រជុំបានបញ្ចប់ទៅនៅម៉ោង ១១ និង ៣០ នាទី។ ខ្ញុំបានចំណាយពេលជាងពីរម៉ោង ធ្វើការសំណេះសំណាលយ៉ាងស្និទ្ធស្នាល ជាមួយលោកស្រី ខៀវ ប៉ុណ្ណារី ជាប្រធានសហភាពស្ត្រីកម្ពុជាប្រជាធិបតេយ្យ និងភរិយារបស់លោក ហ៊ូ យន់ ព្រមទាំងភរិយារបស់លោក កុយ ធួន។

បន្ទាប់មក យើងបានជួបជុំគ្នា ហើយបន្តថតសកម្មភាពសម្រាប់ខ្សែភាពយន្តឯកសារស្តីពីការស្នាក់នៅរបស់យើងនៅលើភ្នំគូលែន។ នៅទីនេះមិនសូវជាមានយន្តហោះសត្រូវហោះកាត់ច្រើនទេ។ នៅល្ងាចម្សិលមិញ វិទ្យុប៊ីប៊ីស៊ីបានផ្សាយប្រកាសថា សត្រូវបានគំរាមកំហែងវៀតណាមខាងជើងដោយចោទប្រកាន់ថា វៀតណាមខាងជើងបានរំលោភបំពានលើបទឈប់បាញ់! ជាក់ស្តែង គឺជាចក្រពត្តិនិយម និងបក្ខពួកខ្លួនទៅវិញទេ ដែលបានរំលោភលើកិច្ចព្រមព្រៀងនេះតាំងពីដើមដំបូង! តើពួកគេហ៊ានទម្លាក់គ្រាប់បែកនៅវៀតណាមខាងជើងទៀតដែរឬទេ? សត្រូវទាំងនេះ ហ៊ានធ្វើអ្វីគ្រប់យ៉ាងដោយមិនញញើតឡើយ។

នៅម៉ោង ១៥ និង ០០ នាទី សម្តេចព្រះអង្គបន្តកិច្ចប្រជុំជាមួយបងប្អូននៃចលនាតស៊ូ ចំណែកខ្ញុំ បានជួបជាមួយបងប្អូនស្ត្រីខ្មែរនៃចលនាតស៊ូម្តងទៀតនៅម៉ោង ១៦ និង ០០ នាទី។ កិច្ចប្រជុំទាំងពីរ ពិតជាមានសារប្រយោជន៍ខ្លាំងណាស់។ យើងបានដោះដូរព័ត៌មាន និងទស្សនៈយល់ឃើញ ព្រមទាំងដាក់ចេញនូវផែនការសកម្មភាពរួមមួយ។ ព្រឹកនេះ យើងក៏បានទៅមើលផ្ទះបាយដែលរៀបចំបានយ៉ាងរៀបរយ និងស្អាតបាតដែរ។ យុទ្ធជនរបស់យើងដែលទទួលបន្ទុកនៅទីនេះបានប្រកាន់ខ្ជាប់ អនាម័យយ៉ាងតឹងរ៉ឹង។ ចំណែកឯម្ហូបអាហារដែលពួកគាត់បានចម្អិនគឺពិតជាឈ្ងុយឆ្ងាញ់ខ្លាំងណាស់!

នៅពេលល្ងាច ប្រហែលម៉ោង ១៩ និង ០០ នាទី មានការសម្តែងសិល្បៈមួយ។ រោងល្ខោនត្រូវបានរៀបចំយ៉ាងល្អឥតខ្ចោះ នៅក្រោមដើមឈើធំៗរុំព័ទ្ធទៅដោយវល្លិ៍ សំយុងចុះមកក្រោមដែលបង្កើតបានជាការតុបតែងបែបធម្មជាតិ ប្រកបទៅដោយសម្រស់ឥតគូប្រៀប! យុទ្ធជនបានឈរជាពីរជួរនៅសងខាងផ្លូវ ដើម្បីទទួលស្វាគមន៍ការមកដល់របស់យើង អមជាមួយនឹងតន្ត្រីបុរាណខ្មែរប្រគំឡើងដោយតន្ត្រីករវ័យក្មេងដ៏ចំណានមួយក្រុម។ ទស្សនីយភាពនេះបានចាប់ផ្តើមឡើងដោយការថ្លែងសុន្ទរកថារបស់លោក ហូ នឹម និងចម្រៀងស្វាគមន៍ ដែលនិពន្ធឡើងដើម្បីថ្វាយព្រះកិត្តិយសចំពោះសម្តេច។ នៅមានទស្សនីយភាពជាច្រើនផ្សេងទៀត។ ទស្សនីយភាពចម្រៀង និងរបាំ បង្ហាញអំពីការតស៊ូយ៉ាងមោះមុតរបស់ប្រជាជនខ្មែរប្រឆាំងនឹងចក្រពត្តិនិយម និងបក្ខពួក, ជីវភាពប្រចាំថ្ងៃនៅតំបន់រំដោះ, ការបង្កបង្កើនទិន្នផល, ជ័យជម្នះដ៏ត្រចះត្រចង់លើទីតាំងពោធិ៍ចិនតុង, និងទស្សនីយភាពនៃចម្រៀង និងរបាំរបស់ជនជាតិភាគតិច។ ការសម្តែងបានបញ្ចប់ទៅដោយជោគជ័យ។ អ្នករាល់គ្នាសើចក្អាកក្អាយ និងពេញចិត្តចំពោះការសម្តែងនេះណាស់។ នៅចុងបញ្ចប់ យើងឡើងទៅលើឆាកដើម្បីអបអរសាទរដល់សិល្បករ និងប្រគល់វត្ថុអនុស្សាវរីយ៍មួយចំនួនដល់អ្នកទាំងអស់គ្នា។ សម្តេចព្រះអង្គថ្លែងសុន្ទរកថាឥតព្រាងទុកមួយ ដើម្បីអបអរសាទរ និងថ្លែងអំណរគុណដល់ក្រុមសិល្បៈចំពោះស្មារតីស្នេហាជាតិ និងការសម្តែងដ៏ស្ទាត់ជំនាញដែលបង្កើតជាការភ្ញាក់ផ្អើលដ៏សប្បាយរីករាយសម្រាប់យើង។



# ថ្ងៃទី ២០ ~ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៣

នៅថ្ងៃនេះ កាលពីបីឆ្នាំមុន ជនក្បត់ជាតិ លន់ នល់ បានធ្វើរដ្ឋប្រហារ ដែលធ្វើឱ្យបាត់បង់សន្តិភាព អព្យាក្រឹតភាព និងឯករាជ្យភាពរបស់ប្រទេសកម្ពុជា ហើយបង្កជា ទុក្ខវេទនាសព្វគ្រប់បែបយ៉ាងចំពោះប្រទេសជាតិ និងប្រជាជនយើង។ កាលពីបីឆ្នាំមុន យើងស្លុតចិត្ត និងពោរពេញទៅដោយភាពក្រៀមក្រំ។ ប៉ុន្តែនៅថ្ងៃនេះ បន្ទាប់ពីការតស៊ូយ៉ាងអង់អាចក្លាហានរបស់ប្រជាជនយើងអស់រយៈពេលបីឆ្នាំមក យើងអាចនិយាយបានថាយើងជិតឈោងចាប់ជ័យជម្នះចុងក្រោយបានហើយ។ នេះគឺជាមូលហេតុដែលធ្វើឱ្យយើងមានភាពរីករាយនៅពេលបានវិលត្រឡប់មកកាន់មាតុភូមិជាទីស្នេហា ជាមួយជនរួមជាតិ ហើយអាចអបអរសាទររួមគ្នាជាមួយនឹងចលនាតស៊ូនៅក្នុងប្រទេស ក្នុងឱកាសខួបលើកទីបីនៃការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា។ យើងក៏មានការសោកស្ដាយដែរ នៅពេលនឹកឃើញដល់ទុក្ខវេទនាដ៏ធំធេងដែលកើតមានឡើងមកលើជន រួមជាតិរបស់យើង ដែលកំពុងតែរស់នៅក្នុងតំបន់ក្រោមការគ្រប់គ្រងរបស់ជនក្បត់ជាតិនេះ។

នៅព្រឹកនេះ ការប្រជុំដ៏ធំមួយបានធ្វើឡើងនៅកន្លែងជាមួយគ្នានឹងការសម្ដែងសិល្បៈកាលពីល្ងាចថ្ងៃមុន។ មានមនុស្សប្រហែល ១ ម៉ឺននាក់ បានចូលរួម ហើយក្នុងនោះរួមមាន ព្រះសង្ឃ, ក្រុមយុវជន, និងប្រជាជន។ នៅម៉ោងប្រហែល ៧ និង ០០ នាទី សម្ដេចយាងមកដល់ទីកន្លែងប្រជុំ ជាមួយនឹងលោក ខៀវ សំផន និងទតមើលកងទ័ពរំដោះ និងអាវុធដែលដកហូតបានពីសត្រូវ។ ថ្នាក់ដឹកនាំដទៃទៀតនៃចលនាតស៊ូ រួមមានលោក ហ៊ូ យន់, លោក ហ៊ូ នឹម, លោក សុន សេន, លោក សាឡុត ស និងអ្នកដទៃទៀតអមដំណើរសម្ដេច និងលោក ខៀវ សំផន។ ក្រុមយុវជន បានច្រៀងចម្រៀងជាតិយើងគឺបទនគររាជ។ កិច្ចប្រជុំនេះចាប់ផ្ដើមនៅម៉ោង ៧ និង ៣០ នាទី ដោយផ្ដើមពីការបន់ស្រន់តាមទំនៀមទម្លាប់ព្រះពុទ្ធសាសនា ដែលហៅថា "ជយន្តោ" សូត្រឡើងដោយព្រះសង្ឃចំនួនដប់អង្គ ដើម្បីទទួលស្វាគមន៍សម្ដេច។ កម្មវិធីបន្ទាប់ គឺការថ្លែងសុន្ទរកថាពីលោក ខៀវ សំផន, ព្រះសង្ឃមួយអង្គ, អ្នកតំណាងប្រជាជនមួយរូប និងជាចុងក្រោយដោយលោក សុន សេន។



នៅចុងបញ្ចប់ សម្តេចព្រះអង្គថ្លែងសុន្ទរកថាមួយ ដែលជារឿយៗតែងតែត្រូវបានបង្អាក់ដោយសូរហោរកញ្ជៀវដែលពោរពេញដោយក្តីរីករាយ និងសំឡេងឃោសនាបន្លឺឡើងពីសំណាក់យុទ្ធជន ដើម្បីអបអរសាទរការយាងត្រឡប់មកវិញរបស់សម្តេច និងគម្រប់ខួបលើកទី៣ នៃរណសិរ្សរួបរួមជាតិកម្ពុជា។

បន្ទាប់ពីកិច្ចប្រជុំ សម្តេចបានយាងជួបសំណេះសំណាលយ៉ាងស្និទ្ធស្នាលជាមួយព្រះសង្ឃ និងអ្នកតំណាងប្រជាជនដែលឈរជាជួររង់ចាំទទួលស្វាគមន៍ព្រះអង្គ។ បន្ទាប់មក អមដោយសំឡេងសាទរពីក្រុមអ្នកចូលរួមអបអរសម្តេច និងខ្ញុំបានចាកចេញពីកន្លែងនោះ។ ព្រឹកនេះគឺជាពេលវេលាដ៏រំភើបរីករាយមួយដែលយើងទាំងអស់គ្នាបានទន្ទឹងរង់ចាំអស់រយៈពេលជាយូរណាស់មកហើយ!

នៅម៉ោង ១៦ និង ០០ នាទី សម្តេច និងខ្ញុំព្រមទាំងថ្នាក់ដឹកនាំចលនាតស៊ូ ទាំងប្រុសទាំងស្រី បានទៅព្រះវិហារដើម្បីគោរព និងបួងសួងដល់ព្រះពុទ្ធប្បដិមាដ៏ធំដែលបានឆ្លាក់នៅលើផ្ទាំងថ្ម។ ទីកន្លែងនេះ គឺពិតជាមានភាពមហស្ចារ្យណាស់ និងបានរំឭកយើងនូវការចងចាំអំពីអតីតកាលដ៏រីករាយជាច្រើន ... ពីព្រោះយើងតែងតែមកកាន់ទីនេះជានិច្ច នៅមុនថ្ងៃទី១៨ ខែមីនា ឆ្នាំ ១៩៧០! ព្រះពុទ្ធប្បដិមាដ៏ធំដែលឆ្លាក់នៅលើផ្ទាំងថ្មនេះ មានបាតទំហំប្រហែលសាមសិបម៉ែត្រ និងកម្ពស់ប្រហែលប្រាំមួយឬប្រាំពីរម៉ែត្រ។ ខ្ញុំធ្វើការបន់ស្រន់បួងសួងដោយសុទ្ធចិត្ត ដើម្បីប្រទេសជាតិ ដើម្បីសន្តិភាព និងដើម្បីគ្រួសារខ្ញុំ។ យើងបានថតរូបអនុស្សាវរីយ៍នៅខាងក្រោមផ្ទាំងថ្ម។

នៅពេលល្ងាច រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាបានរៀបចំអាហារពេលល្ងាចដើម្បីថ្វាយកិត្តិយសចំពោះសម្តេច។ ថ្នាក់ដឹកនាំទាំងប្រុសទាំងស្រី មានវត្តមាននាឱកាសនេះ។ អាហារពេលល្ងាចបានប្រព្រឹត្តទៅក្នុងបរិយាកាសស្មោះស្ម័គ្រ និងកក់ក្តៅ! នេះគឺពិតជាពេលវេលាដ៏រីករាយបំផុត! ដំណើរទស្សនកិច្ចរបស់យើងទៅកាន់តំបន់រំដោះ បានពង្រឹងសាមគ្គីភាពរវាងយើង និងបងប្អូនជនរួមជាតិនៅឯមាតុភូមិ ដែលនេះគឺជាសាមគ្គីភាពជាធ្លុងមួយឥតបែកខ្ញែក និងនៅស្ថិតស្ថេរបរិកាល។ យើងបានស្បថស្បែសច្ចារួមគ្នា។



សម្តេចម៉ែព្រះអង្គគង់នៅភ្នំគូលេន ជាមួយនឹងលោកស្រី ខៀវ ប៉ុណ្ណារី (ឆ្វេង) និង ភរិយាលោក ហ៊ូ យន់ (ស្តាំ)







# ផ្នែកទី៨

# ការយាងត្រឡប់ទៅប្រទេសចិនវិញ

# ថ្ងៃទី ២១ ~ ថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៧៣

ថ្ងៃនេះក៏ជាថ្ងៃដ៏វិសេសវិសាលមួយសម្រាប់យើងដែរ។ យើងបានធ្វើដំណើរចេញពីភ្នំគូលែននៅម៉ោង ៣ និង ០០ នាទីព្រឹក ហើយបន្ទាប់ពីធ្វើដំណើរអស់រយៈពេលពីរម៉ោងកន្លះ យើងបានមកដល់...អង្គរ! ដើមកំណើតនៃអរិយធម៌ និងជានិមិត្តរូបរបស់ជាតិយើង! អង្គរដែលយើងអាចរំដោះបានតាំងពីខែដំបូងនៃចលនាតស៊ូរបស់យើងគឺនៅខែមិថុនា ឆ្នាំ១៩៧០! ខ្ញុំពុំអាចរកពាក្យមកពិពណ៌នាអំពីអារម្មណ៍របស់សម្តេច និងខ្ញុំនៅពេលយើងចុះពីលើរថយន្តបានឡើយ។

ឱ! អង្គរដ៏អស្ចារ្យអើយ! កំពូលប្រកបដោយអានុភាពរបស់អ្នកផុសឡើងកណ្តាលវេហា បែងបាំងនឹងស្ងួសែងព្រះទិនករដំបូងបំផុតនាព្រឹកព្រលឹម! ដើម្បីបានជួបអ្នកម្តងទៀតយើងបានធ្វើដំណើរដ៏វែងឆ្ងាយ និងពោរពេញទៅដោយគ្រោះថ្នាក់! យើងមិនខ្លាចរអាចំពោះកងទ័ព លន់ នល់ ដែលស្ថិតនៅចម្ងាយតែ ១៥០០ ម៉ែត្រពីយើងនោះសោះឡើយ។ ប៉ុន្តែយើងត្រូវមកកាន់ទីនេះ ដើម្បីឱ្យពិភពលោកទាំងមូលដឹងថា យើងពិតជាបានមកដល់តំបន់រំដោះ ដោយបង្ហាញតាមរយៈខ្សែភាពយន្តឯកសារ និងរូបថតដែលយើងបានថតទុក ដែលយើងនៅកៀកនឹងសត្រូវបំផុត។ ខ្សែភាពយន្តឯកសារ និងរូបថតទាំងនេះ គឺជាភស្តុតាង ដែលពុំអាចប្រកែកបាន។ ខណៈពេលដែលយើងកំពុងទស្សនាប្រាសាទអង្គរ ប្រកបដោយមនោសញ្ចេតនាជ្រាលជ្រៅ យើងបានឮស្នូរកាំភ្លើងរបស់សត្រូវបាញ់ឡើងទៅលើមេឃនៅកៀកទៅនឹងទីកន្លែងរបស់យើង។ មើលទៅសត្រូវប្រហែលជាតែងតែធ្វើបែបនេះ ដើម្បីផ្តល់ភាពក្លាហានដល់ខ្លួនឯង! ដូច្នេះ ពួកគេបញ្ចោតខ្លួនឯង ហើយខ្ជះខ្ជាយគ្រាប់កាំភ្លើងដែលចៅហ្វាយនាយរបស់ពួកគេបានផ្តល់ឱ្យដោយគ្មានបានលទ្ធផលអ្វីទាល់តែសោះក្រៅពីធ្វើឱ្យយើងអស់សំណើច! ពិតជាគួរឱ្យអាសូរណាស់!

យើងសម្លឹងមើលទៅលើការខូចខាតនៅលើប្រាង្គប្រាសាទអង្គរពោរពេញទៅដោយកំហឹង ដែលការខូចខាតទាំងនេះបានបង្កឡើងដោយសកម្មភាពឧក្រិដ្ឋរបស់ជនក្បត់ជាតិ។ ផ្នែកជាច្រើននៃប្រាង្គប្រាសាទបានទទួលរងការខូចខាតដោយសារតែគ្រាប់កាំភ្លើង និងគ្រាប់បែករបស់ពួកក្រុមនេះ... យើងចាកចេញពីប្រាសាទអង្គរវត្តដោយមិនដាច់អាល័យនៅម៉ោងប្រហែលជា ៦ និង ៣០ នាទី។ បន្ទាប់មក យើងធ្វើដំណើរទៅប្រាសាទបាយ័នដែលជាប្រាសាទដ៏ល្បីល្បាញកម្រិត



សម្តេចម៉ែព្រះអង្គគង់នៅប្រាសាទអង្គរវត្ត (រូបថតដោយសម្តេចឪ)






រូបថតឆ្វេងខាងលើ៖ ព្រះឆាយាលក្ខណ៍
សម្តេចឪ ថតដោយសម្តេចម៉ែ

រូបថតស្តាំខាងក្រោម៖ ព្រះឆាយាលក្ខណ៍
សម្តេចម៉ែ ថតដោយសម្តេចឪ



ពិភពលោកមួយទៀត បន្ទាប់ពីប្រាសាទអង្គរវត្ត។ ប្រាសាទបាយ័ន មានកំពូលចំនួនហាសិបដែលកំពូលនីមួយៗមានឆ្លាក់នូវចម្លាក់ព្រហ្មមុខបួន។ ក្នុងអំឡុងពេលទស្សនកិច្ចយើងបានឮសូរសំឡេងកាំភ្លើង និងកាំភ្លើងធំរបស់សត្រូវ ហើយបន្ទាប់មកយើងឃើញយន្តហោះប្រភេទ អេហ្វ១០៥ ហោះកាត់ពីលើយើងជាច្រើនដង ប៉ុន្តែជាសំណាងល្អសត្រូវមិនបានមើលឃើញយើងនោះទេ!

បន្ទាប់ពីទស្សនាប្រាសាទបាយ័ន យើងបន្តដំណើរទៅកាន់ប្រាសាទបន្ទាយស្រី។ ប្រាង្គប្រាសាទដ៏ស្រស់ស្អាតនេះ សាងសង់ឡើងពីថ្មពណ៌ផ្កាឈូក ដែលមានក្បាច់ចម្លាក់យ៉ាងល្អប្រណីត។ នៅទីនោះ យើងបានថតសកម្មភាពខ្លះៗសម្រាប់ខ្សែភាពយន្តឯកសារ និងថតរូបភាពជាច្រើនទៀត។

យើងទទួលទានអាហារថ្ងៃត្រង់ ក្រោមម្លប់ដើមឈើធំៗនៅក្នុងព្រៃ ហើយសម្រាន្តលង់លក់មួយស្របក់នៅក្នុងអង្រឹង។ ក្នុងអំឡុងពេលសម្រាក យន្តហោះសត្រូវហោះកាត់ពីលើយើងជាបន្តបន្ទាប់ ដោយគ្មានការសង្ស័យថាយើងកំពុងស្ថិតនៅក្រោមដើមឈើឡើយ! យើងពិតជាមានសំណាងល្អមែន! ប៉ុន្តែ នៅពេលដែលយើងតស៊ូដើម្បីបុព្វហេតុដ៏ត្រឹមត្រូវ គឺដើម្បីឯករាជ្យភាពជាតិយើង ព្រះជាម្ចាស់ដ៏ស័ក្តិសិទ្ធិនឹងការពារយើង!

នៅម៉ោងប្រហែល ១៨ និង ៣០ នាទី យើងចាកចេញពីប្រាសាទបន្ទាយស្រីដើម្បីវិលត្រឡប់ទៅប្រទេសចិនវិញ ដោយធ្វើដំណើរឆ្លងកាត់វៀតណាមខាងជើង។ ដំណើរទស្សនកិច្ចទៅកាន់ប្រាសាទបន្ទាយស្រី គឺជាចំណុចទស្សនាចុងក្រោយនៃដំណើរទស្សនកិច្ចនៅតំបន់រំដោះ។ សំណួរផុសឡើងនៅពេលនេះគឺ តើយើងត្រូវធ្វើយ៉ាងដូចម្តេច ដើម្បីចាកចេញពីប្រទេសកម្ពុជាដោយសុវត្ថិភាពដើម្បីបន្តបេសកកម្មរបស់យើងនៅបរទេស។ ខ្ញុំលើកលែងលោកស្រី ខៀវ ប៉ុណ្ណារី និងលោក កុយ ធួន ព្រមទាំងភរិយារបស់លោក ដោយអ្នកទាំងនេះត្រូវវិលត្រឡប់ទៅចូលរួមជាមួយបងប្អូននៃចលនាតស៊ូនៅសមរភូមិដទៃទៀត។

យើងត្រឡប់ទៅប្រើប្រាស់រថយន្តហ្ស៊ីប រុស្ស៊ីវិញ ពីព្រោះយើងបានប្រើប្រាស់រថយន្តម៉ាក ៤០៤ ធ្វើដំណើរពីភ្នំគូលែនទៅប្រាសាទបន្ទាយស្រី ដើម្បីគេចពីភ្នែកអ្នកស៊ើបការណ៍របស់សត្រូវដែលលាក់ខ្លួននៅក្បែរនោះ។ លោក កុយ ធួន ចង់ប្រគល់សត្វទោចចំនួនពីរក្បាល និងខ្លាឃ្មុំខ្មៅមួយក្បាលនោះឱ្យមកយើងដើម្បីយកទៅប្រទេសចិន។ ប៉ុន្តែ យើងទទួលយកទៅជាមួយតែសត្វទោច ចំនួនពីរក្បាលតែប៉ុណ្ណោះ។

បន្ទាប់ពីធ្វើដំណើរបានបីម៉ោងកន្លះ នៅពេលយប់ យើងបានមកដល់អូរក្បាលឈ្លូស ដែលជាកន្លែងយើងធ្លាប់លាក់ខ្លួន ដោយគិតថាសត្រូវបានស្វែងរកយើងឃើញហើយ។

យើងបានសាងអនុស្សាវរីយ៍ជាច្រើនក្នុងអំឡុងពេលនៃការធ្វើដំណើរនេះ! ប្រាសាទអង្គរវត្ត ប្រាសាទបាយ័ន និងប្រាសាទបន្ទាយស្រី! តើយើងពិតជាបានទៅកន្លែងដ៏ពិសិដ្ឋទាំងនេះមែនឬ? ប្រាកដណាស់! ប៉ុន្តែវាហាក់បីដូចជាសុបិនមួយអ៊ីចឹង! បងប្អូនរបស់យើងនៅក្នុងប្រទេស បានរៀបចំយ៉ាងល្អប្រពៃ ហើយយើងពិតជាមានមោទកភាពក្រៃលែង!

# ថ្ងៃទី ២២ ~ ថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៣

ទោះបីជាឮស្នូរសំឡេងយន្តហោះរបស់សត្រូវយ៉ាងណាក៏ដោយ ក៏នៅពេលយប់យើងបានសម្រាកគ្រប់គ្រាន់ដែរ ពីព្រោះថាខ្ញុំចាប់ផ្តើមស៊ាំនឹងសំឡេងនេះទៅហើយ។ យើងឮការផ្សព្វផ្សាយតាមវិទ្យុថា លន់ នល់ បាន បញ្ជាឱ្យចាប់ខ្លួនសមាជិករាជវង្សជាច្រើនអង្គ បន្ទាប់ពីអ្នកបើកបរយន្តហោះម្នាក់បានធ្វើការទម្លាក់គ្រាប់បែកនៅវិមានរបស់ខ្លួន។ ខ្ញុំត្រូវតែសរសេររៀបរាប់អំពីរឿងនេះ។

នៅថ្ងៃទី១៧ ខែមីនា មេបញ្ជាការកងទ័ពអាកាសកម្ពុជា សូ ភត្រា[២២] ដែលជាស្វាមីរបស់ បុទុម បុប្ផា បុត្រីរបស់សម្តេច បានទម្លាក់គ្រាប់បែកជាច្រើនគ្រាប់ទៅលើវិមានរបស់ លន់ នល់ ប៉ុន្តែគ្រាប់បែកដែលទម្លាក់នោះ ធ្លាក់ចំរបង និងផ្នែកខ្លះនៃបន្ទាយយោធានៅខាងក្រោយវិមានរបស់ លន់ នល់ តែប៉ុណ្ណោះ និងមានអ្នករងរបួសមួយចំនួន។ សូ ភត្រា បានបើកយន្តហោះរត់គេចខ្លួនផុត។ យោងតាមព័ត៌មានដែលយើងទទួលបាន សូ ភត្រា បានចុះចតយន្តហោះនៅតំបន់រំដោះបានដោយសុវត្ថិភាព។ ប៉ុន្តែយើងមិនទាន់ទទួលបានការបញ្ជាក់ច្បាស់លាស់ណាមួយ អំពីដំណឹងនេះពីខាងយើងនៅឡើយទេ។ របប លន់ នល់ កាន់តែមានភាពរង្គោះរង្គើទៅៗ។ អស់រយៈពេលជាច្រើនសប្តាហ៍មកហើយ កូដកម្មបានផ្ទុះឡើងនៅតាមបណ្តារោងចក្រ សាលារៀន និងសាកលវិទ្យាល័យ។ ទីបញ្ចប់ជិតឈានចូលមកដល់ហើយ។

នៅវេលាម៉ោង ១៨ និង ៣០ នាទី យើងធ្វើដំណើរចាកចេញពីកន្លែងនេះទៅកាន់កំពង់ក្រោម ដែលជាកន្លែងដែលយើងបានស្នាក់នៅចំនួនពីរយប់ជាប់គ្នាពីមុន។ ចាប់ពីល្ងាចនេះទៅសកម្មភាពឧក្រិដ្ឋកម្មរបស់សត្រូវនឹងកើនឡើង ពីព្រោះយើងបានចូលមកដល់ខេត្តព្រះវិហារវិញហើយ។ យើងត្រូវឈប់ជាច្រើនដងក្នុងអំឡុងពេលធ្វើដំណើរ ពីព្រោះយន្តហោះប្រភេទ អេស៊ី ១៣០ របស់សត្រូវ កំពុងធ្វើការហោះហើរឆ្វាត់ឆ្វៀលទៅវិញទៅមកនៅពីលើយើង។ នៅពេលធ្វើដំណើរមកដល់កំពង់ក្រោម យើងបានឮស្នូរទម្លាក់គ្រាប់បែករបស់សត្រូវនៅចម្ងាយតែប៉ុន្មានគីឡូម៉ែត្រពីទីតាំងរបស់យើងតែប៉ុណ្ណោះ ហើយស្នូរសំឡេងនេះនៅបន្តរហូតដល់ពេលព្រឹក។ ក្បួនធ្វើដំណើររបស់យើងត្រូវតែបំបែកគ្នា។ សមាជិកថ្នាក់ដឹកនាំបលនាតស្វ៊ីមួយចំនួនមិនបានចូលរួមដំណើរជាមួយយើងទេ រហូតទាល់តែព្រឹកព្រលឹមបន្តិច បន្ទាប់ពីការទម្លាក់គ្រាប់បែកបញ្ចប់ទៅនិងនៅពេលដែលស្ថានភាពស្ងប់ស្ងាត់វិញ។

---

២២. ខ្មែរក្រហមបានសម្លាប់មេបញ្ជាការកងទ័ពអាកាសកម្ពុជា សូ ភូត្រា ជាមួយកូនៗនិងភរិយា គឺសម្តេចព្រះអង្គម្ចាស់ក្សត្រី នរោត្តម បុទុមបុប្ផា ដែលជាបុត្រីរបស់សម្តេច ព្រះនរោត្តម សីហនុ។ នៅឆ្នាំ ១៩៩៤ សម្តេចព្រះ នរោត្តម សីហនុ បានប្រោសព្រះរាជទានគោរមងារជាព្រះអង្គម្ចាស់ សីហនុ សូ ភូត្រា ដល់មេបញ្ជាការកងទ័ពអាកាសកម្ពុជារូបនេះ។

# ថ្ងៃទី ២៣ ~ ថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៧៣

យន្តហោះសត្រូវបានធ្វើសកម្មភាពពេញមួយថ្ងៃដោយគ្មានការឈប់សម្រាក។ បើតាមសម្ដេចនិងខ្ញុំយល់ នេះគឺជាលើកដំបូងហើយដែលយើងបានសោយទឹកត្នោត ក្នុងរយៈកាលជាងបីឆ្នាំកន្លងមកនេះ។ ទឹកត្នោតមានរសជាតិផ្អែមមុត និងក្រអូបឈ្ងុយឆ្ងាញ់! យើងមិនគួរអស់សង្ឃឹមក្នុងជីវិតឡើយ។ អ្វីៗគ្រប់យ៉ាងដែលយើងប៉ងប្រាថ្នាអាចកើតឡើងនៅពេលដែលយើងមានភាពអត់ធ្មត់។ នោះគឺជាមូលហេតុដែលខ្ញុំដឹងច្បាស់ថាការរំដោះប្រទេសកម្ពុជាគឺខិតជិតមកដល់ហើយ។ នៅល្ងាចម្សិលមិញ កងជីវពលស្ត្រីធ្វើសកម្មភាពការពារតាមដងផ្លូវចម្ងាយប្រហែលម្ភៃគីឡូម៉ែត្រ។ កងជីវពលស្ត្រី គឺពោរពេញទៅដោយភាពក្លាហាន និងប្រយុទ្ធយ៉ាងអង់អាចទាំងនៅសមរភូមិមុខ និងសមរភូមិខាងក្រោយ។ កងជីវពលស្ត្រីបង្រៀនគ្នាទៅវិញទៅមកអំពីរបៀបដេរឯកសណ្ឋាន។ កងជីវពលស្ត្រីទទួលបន្ទុកបង្កបង្កើនទិន្នផល និងចូលរួមក្នុងការងារតាមមូលដ្ឋាន និងចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពនយោបាយក្រោមលំអាននៃគណៈកម្មាធិការរណសិរ្សរួបរួមជាតិកម្ពុជា។ ខ្ញុំពិតជាមានមោទកភាពជាអនេកចំពោះជនរួមជាតិរបស់ខ្ញុំណាស់!

យើងត្រូវចេញដំណើរនៅម៉ោង ១៩ និង ០០ នាទី ពីព្រោះពេលនេះគឺជាខែរនោច។ បន្ទាប់ពីធ្វើដំណើរបានប៉ុន្មានគីឡូម៉ែត្រ ដោយសារតែផ្លូវងងឹតខ្លាំងពេក រថយន្តហ្ស៊ីបរបស់យើងបានបុកមួយទំហឹងជាមួយនឹងដើមឈើ។ ខណៈពេលនោះខ្ញុំកំពុង ឱនខ្លួនទៅខាងមុខដើម្បីសម្លឹងមើលផ្លូវ ហើយក៏ត្រូវទង្គិចទៅនឹងកៅអីជួរមុខ និងបុកត្រូវបបូរមាត់របស់ខ្ញុំយ៉ាងខ្លាំង! បបូរមាត់ផ្នែកខាងក្រោមរបស់ខ្ញុំ ដាច់រលាត់ និងហូរឈាមយ៉ាងច្រើន! ភ្លាមៗនោះ បបូរមាត់របស់ខ្ញុំឡើងហើមប៉ោង។ នេះគឺជា "គ្រោះថ្នាក់" លើកដំបូងដែលខ្ញុំជួបប្រទះ ចាប់តាំងពីការចាកចេញដំណើរពីទីក្រុងប៉េកាំង។ យើងឈប់នៅទីនោះប្រមាណមួយម៉ោង ហើយនៅពេលដែលព្រះចន្ទរះខ្ពស់ត្រដែតយើងចាប់ផ្ដើមដំណើរឡើងវិញ ដើម្បីទៅដល់ភ្នំតែលមុនពេលពាក់កណ្ដាលអធ្រាត្រ។ ព្រៃនៅទីនោះមានសភាពក្រាស់ណាស់។

# ថ្ងៃទី ២៨ ~ ថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៧៣

ព្រឹកនេះ ក្រោយភ្ញាក់ពីដំណេក ខ្ញុំបានពិនិត្យមើលបបូរមាត់របស់ខ្ញុំ តាមកញ្ចក់ឆ្លុះមុខតូចមួយដែលខ្ញុំបានយកមកតាមខ្លួន។ បបូរមាត់ខ្ញុំមានសភាពហើម និងឈឺផ្សារ ទោះបីជាមុខរបួសបានជាសះស្បើយបន្តិចហើយក៏ដោយ។ ដោយសារតែយើងព្យាយាមគេចខ្លួនពីយន្តហោះប្រភេទ បេ៥២, អាសេ១៣០, និង អេហ្វ១០៥ ទើបយើងបុកជាមួយនឹងដើមឈើ! ពិតជាកំប្លែងណាស់! ខ្ញុំអាចនិយាយអួតប្រាប់អ្នកផងទៃថា ខ្ញុំបានបង្ហូរឈាមពីរបីដំណក់ដែរក្នុងអំឡុងពេលតស៊ូ ដើម្បីរំដោះប្រទេសជាតិរបស់យើងប្រឆាំងនឹងពួកឈ្លានពានចក្រពត្តិ!

ក្នុងអំឡុងពេលធ្វើដំណើរ "សំឡេង" ដែលបង្កឡើងដោយយន្តហោះរបស់សត្រូវ បន្លឺសូរឥតឈប់ឈរ។ ថ្នាក់ដឹកនាំនៃចលនាតស៊ូ មានទឹកចិត្តល្អ និងបានសួរនាំអំពីសុខភាពរបស់យើងព្រមទាំងផ្តល់ថ្នាំមួយចំនួនដល់យើងថែមទៀត។ ការចេញដំណើរត្រូវបានកំណត់នៅម៉ោង ២៣ និង ០០ នាទី ពីព្រោះបន្ទាប់ពី ឧប្បត្តិហេតុកាលពីល្ងាចម្សិលមិញបានកើតឡើង យើងត្រូវរង់ចាំទាល់ព្រះចន្ទបញ្ចេញពន្លឺ ទើបចាប់ផ្តើមចេញដំណើរ។

បន្ទាប់ពីឈប់សម្រាកតាមផ្លូវប៉ុន្មានដង យើងបានមកដល់អន្លង់ក្រមួន នៅម៉ោង ០២ និង ៣០ នាទីព្រឹក។ នៅទីនោះយើងមានអារម្មណ៍ថារងាបន្តិច។

# ថ្ងៃទី ២៥ ~ ថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៣

អន្លង់ក្រមួន គឺជាកន្លែងដែលយើងសម្រាកនៅក្នុងអង្រឹងកាលពីថ្ងៃមុន។ យប់នេះ ទីតាំងសម្រាប់ដំណេករបស់យើងរៀបចំបានប្រសើរជាងមុន។ មុនពេលយាងផ្ទំ សម្ដេច និងខ្ញុំ បានសោយថ្នាំអាស្ពីរីន ព្រោះយើងមានអារម្មណ៍ស្រៀវស្រាញបន្តិច។ នៅម៉ោង ៦ និង ០០ នាទីព្រឹក សំឡេងទ្រហោយំនៃសត្វទោចរបស់យើងបានដាស់យើងឱ្យភ្ញាក់ឡើងភ្លាមៗ។ សម្ដេចបានប្រញាប់ប្រញាល់យាងចេញទៅក្រៅខ្ទម ដើម្បីទៅមើលសត្វទោចទាំងពីរក្បាល។ ខ្ញុំចាំបាច់ត្រូវសរសេររៀបរាប់នូវអ្វីដែលបានកើតឡើងកាលពីម្សិលមិញនៅភ្នំតែល មុនពេលយើងចេញដំណើរ។

ខ្ញុំធ្លាប់បានសរសេររៀបរាប់រួចហើយថាលោក កុយ ធួន បានប្រគល់ សត្វទោចចំនួនពីរក្បាលឱ្យកំដរយើងនៅឯភ្នំគូលែន។ សត្វទោចមួយក្បាលដែលមានមាឌធំ អាយុជិតពីរឆ្នាំ រីឯមួយក្បាលទៀតមានអាយុទើបតែប៉ុន្មានខែតែប៉ុណ្ណោះ។ យើងនាំយកសត្វទោចទាំងពីរក្បាលនេះទៅកាន់ទីក្រុងប៉េកាំងជាមួយគ្នា។ ទោចទាំងពីរបានចាប់ផ្ដើមទម្លាប់ក្នុងការរស់នៅជាមួយយើងហើយ។ សម្ដេចព្រះអង្គសព្វព្រះហឫទ័យសត្វទោចដែលមានមាឌធំជាង ពីព្រោះវាតែងតែបង្ហាញក្ដីស្រឡាញ់ចំពោះសម្ដេច និងតែងឱបតោងព្រះសុរងរបស់សម្ដេចជាប់។ ខ្ញុំចូលចិត្តសត្វទោចដែលមានមាឌតូចជាង ទោះបីជាវារាងកាចបន្តិចក៏ដោយ។

ល្ងាចម្សិលមិញ នៅម៉ោងប្រហែលជា ២០ និង ០០ នាទី យុទ្ធជនរបស់យើងបាននាំយក សត្វទោចទាំងពីរក្បាល ដើម្បីត្រៀមចេញដំណើរ។ នៅគ្រានោះ សត្វទោចដែលមានមាឌធំមានភាពភិតភ័យ ហើយប្រុងនឹងខាំដៃផ្ទាំរបស់យើង។ បន្ទាប់មក វាក៏ភ្ញាក់ក្រញ៉ាង ហើយលោតកញ្ច្រោល ធ្វើឱ្យប្រទ្បោរបស់វារបូតធ្លាក់ចេញ។ សត្វទោចមួយក្បាលធំនោះ បានឆ្លៀតឱកាសលោតតោងឡើងទៅលើដើមឈើហើយបាត់ខ្លួនទៅនៅយប់នោះ។

សម្ដេចព្រះអង្គសោកសៅយ៉ាងខ្លាំង ពីព្រោះព្រះអង្គពិតជាសព្វព្រះហឫទ័យចំពោះសត្វទោចមួយក្បាលនោះណាស់។ ទោះបីជាយើងព្យាយាមស្រែកហៅយ៉ាងណាក៏ដោយ ក៏វាមិនព្រមបង្ហាញខ្លួនដែរ។ យើងចាកចេញពីទីកន្លែងនោះដោយសង្វេគ។ ប៉ុន្តែយើងបានទុកឱ្យយុទ្ធជនរបស់យើងខ្លះ រួមជាមួយនឹងសត្វទោចមួយក្បាលទៀតនៅទីនោះ ដើម្បីទាក់ទាញសត្វទោចដែលរត់បាត់នោះឱ្យត្រឡប់មកវិញ។ ហើយនេះគឺជាអ្វីដែលបានកើតឡើង។ យើងបានឃើញសត្វទោចទាំងពីរក្បាល នៅព្រឹកនេះ។

ពួកវាកំពុងតែតោងយោលខ្លួនទៅវិញទៅមកនៅនឹងមែកឈើយ៉ាងសប្បាយរីករាយ។ សត្វទោចដែលរត់បាត់ទៅនោះ មើលឃើញសម្តេចភ្លាម ក៏ហាក់ទៅរកព្រះអង្គ និងមិនចាកចេញពីទ្រង់ទៀតទេ! នេះគឺជាសញ្ញាដ៏ល្អ! យើងមានទំនុកចិត្តក្នុងយកជ័យជម្នះ លើសត្រូវរបស់យើង។

ថ្ងៃនេះក៏ជាខួបលើកទីបីនៃការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា និងសេចក្តីថ្លែងការណ៍ជាប្រវត្តិសាស្ត្រនៃថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ របស់សម្តេច។ ថ្នាក់ដឹកនាំទាំងអស់នៃពលនាតស៊ូក្នុងប្រទេស លោក ខៀវ សំផន, លោក ហ៊ូ យន់, លោក ហូ នឹម, លោក សុន សេន, និងលោក អៀង សារី បានមកជូនពរសម្តេចប្រមុខរដ្ឋ។ លោក ខៀវ សំផន ក៏បានជូនសម្តេចនូវ កាំភ្លើងវែងចំនួនពីរដើម ដែលបានដកហូតពីសត្រូវ។

កាំភ្លើងវែងទាំងពីរដើមនោះគឺជាកាំភ្លើងប្រភេទ “៧៩” និង ប្រភេទ “អាអ៊ែរ ១៩”។ យើងបានជួបជុំប្រមូលផ្តុំគ្នាយ៉ាងសប្បាយរីករាយ ព្រមទាំងសោយទឹកតែ និងស្ករសូកូឡា។ ខ្ញុំគិតថា នៅឯទីក្រុងប៉េកាំងវិញ សម្តេច ប៉ែន នុត ប្រាកដជាបានរៀបចំទទួលភ្ញៀវនៅថ្ងៃនេះ ដើម្បីអបអរសាទរឱកាសនេះជាក់ជាមិនខាន។ សម្តេច និងខ្ញុំមានសេចក្តីសោមនស្សរីករាយ ដែលអាចប្រារព្ធខួបលើកទីបីនៃរណសិរ្សរួបរួមជាតិ និងកងទ័ពរំដោះជាតិកម្ពុជា ជាមួយនឹងបងប្អូនរបស់យើងនៅលើទឹកដីប្រទេសកម្ពុជា! យើងនឹងរង់ចាំប្រារព្ធពិធីអបអរសាទរថ្ងៃរំដោះភ្នំពេញនៅថ្ងៃណាមួយជាមិនខាន!

កន្លែងដែលយើងកំពុងស្នាក់នៅថ្ងៃនេះ គឺខុសពីកន្លែងដទៃទៀត។ កន្លែងនេះគឺធ្លាប់ជាភូមិមួយ ដូច្នេះមានដើមឈើហូបផ្លែជាច្រើន ដែលមានដូចជាដើមស្វាយធំៗ, ដើមអម្ពិល, ដើមក្រូចថ្លុង និងដើមឈើជាច្រើនប្រភេទទៀត។ អាកាសធាតុនៅទីនេះត្រជាក់។ ខ្ញុំចង់ចែករំលែករឿងមួយទៀតដែលកើតឡើងនៅរសៀលនេះ។ ដោយមានអារម្មណ៍ថាដូចជាមានអ្វីប៉ះជើង ខ្ញុំបានរលាស់ជើងដើម្បីឱ្យវាជ្រុះទៅលើដី រួចខ្ញុំក៏ក្រឡេក។ តើខ្ញុំបានឃើញអ្វីទៅ? គឺសត្វ ខ្យាដំរីដ៏ធំមួយ ដែលមានទំហំប្រហែលសាមសិបសង់ទីម៉ែត្រ! ខ្ញុំស្លុតគាំងដោយអារម្មណ៍ភ័យខ្លាច ព្រោះខ្ញុំមិនចូលចិត្តពពួកសត្វល្អិតនោះទេ។ សំណាងហើយដែលវាមិនបានទិចជើងខ្ញុំ។ ពិសខ្យាដំរី អាចបណ្តាលឱ្យមានការឈឺពើតហើយពេលខ្លះអាចបណ្តាលឱ្យក្តៅខ្លួនខ្លាំងទៀតផង។ ខ្ញុំពិតជាសំណាងល្អមែន!

តើនឹងមានរឿងអ្វីកើតឡើងបន្តទៀត? យើងត្រូវរស់នៅក្នុងព្រៃរយៈពេលពីរសប្តាហ៍ទៀត មុននឹងធ្វើដំណើរទៅដល់ទីក្រុងហាណូយ! ប៉ុន្តែរឿងរ៉ាវល្អក់ចិត្តតូចតាចដែលបានកើតឡើងទាំងនេះគឺ គ្មានអ្វីប្រៀបផ្ទឹមបាននឹងភាពសប្បាយរីករាយក្នុងការវិលត្រឡប់មកមាតុភូមិរបស់យើងវិញនោះទេ! នៅល្ងាចនេះ យើងមិនអាចចាកចេញដំណើរបានទេ ពីព្រោះតែយន្តហោះសត្រូវបានទម្លាក់គ្រាប់បែកជាបន្តបន្ទាប់រយៈពេលម្ភៃបួនម៉ោងពេញនៅត្រង់កន្លែងដែលយើងប្រុងនឹងធ្វើដំណើរទៅនោះ។ ពីខេត្តស្ទឹងត្រែងទៅខេត្តក្រចេះ គ្រាប់បែកបេ៥២, អេហ្វ១០៥, អូវេ១០ និងអាសេ ១៣០ រាប់តោនត្រូវបានទម្លាក់ស្ទើរតែគ្រប់នាទី។ ហេតុការណ៍នេះបង្កការស្អប់ខ្ពើមយ៉ាងខ្លាំងក្លាពីសំណាក់យុទ្ធជននិងប្រជាជនរបស់យើង ព្រមទាំង ពង្រឹងការប្តេជ្ញាចិត្ត ការតស៊ូដើម្បីរំដោះប្រទេសជាតិរបស់ពួកគាត់ថែមទៀតផង។

# ថ្ងៃទី ២៦ ~ ថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៧៣

ពេញមួយយប់ យន្តហោះសត្រូវ ជាពិសេសយន្តហោះប្រភេទ អេស៊ី១៣០ បានទម្លាក់គ្រាប់បែកនៅត្រង់ទីតាំងក្បែរជំរំរបស់យើង។ ខ្ញុំសួរខ្លួនឯងថា តើយើងអាចបន្តដំណើរទៅមុខទៀតបានដោយរបៀបណា? ពីព្រោះនៅមានគ្រាប់បែកចង្កោម និងគ្រាប់បែកប្រភេទពន្យារពេលផ្ទុះ នៅមិនទាន់ផ្ទុះនៅឡើយ ស្ថិតលើផ្លូវដែលយើងត្រូវធ្វើដំណើរ។ ជាពិសេស យើងត្រូវធ្វើដំណើរនៅពេលយប់អធ្រាត្រ! ល្ងាចម្សិលមិញ យើងទាំងអស់គ្នាស្តាប់វិទ្យុប៉េកាំង ផ្សព្វផ្សាយសារសំឡេងដែលសម្តេចបានថតទុកមុនពេលយើងចាកចេញពីទីក្រុងហាណូយ សម្រាប់ឱកាសខួបលើកទីបីនៃការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា។ ការចាក់ផ្សាយសារសំឡេងគឺពិតជាល្អណាស់។ ថ្ងៃនេះ សត្រូវឈ្លានពានបានបន្តបង្កើនការឆក់យកជីវិត និងការបំផ្លិចបំផ្លាញនៅក្នុងទឹកដីកំណើតរបស់យើង។

ប្រជាកសិករលែងហ៊ានចាកចេញពីផ្ទះទៀតហើយ ពីព្រោះប្រសិនបើសត្រូវឃើញនរណាម្នាក់មិនថាដើរ ឬជិះកង់ ឬម៉ូតូទេ ពួកគេប្រាកដជាបាញ់សម្លាប់បុគ្គលនោះ ដោយមិនអាណិតអាសូរជាមិនខាន ហើយបន្ទាប់មករាយការណ៍ថា ខ្លួនបានកម្ទាត់ "វៀតកុង" ឬ "វៀតណាមខាងជើង"។ កាលពីយប់ម្សិលមិញ អ្នកតស៊ូម្នាក់ដែលរស់នៅចម្ងាយពីរ ឬបីគីឡូម៉ែត្រពីទីតាំងយើងបានអុជ បារីជក់ ហើយក៏មានប្រតិកម្មតបភ្លាមៗដោយមិនចាំយូរ។ យន្តហោះប្រភេទ អាសេ ១៣០ បានតម្រង់គ្រាប់កាំភ្លើងបាញ់មករកគាត់។ សំណាងហើយដែលអ្នកតស៊ូរបស់យើង អាចរត់គេចខ្លួនបាន! ដូច្នេះ នៅល្ងាចនេះ យើងត្រូវរង់ចាំបន្តិចសិន។

# ថ្ងៃទី ២៧ ~ ថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧៣

នេះគឺជាថ្ងៃទីបីហើយ ដែលយើងស្នាក់នៅក្នុងស្រុកអន្លង់ក្រមួន។ យប់មិញ មានសភាពស្ងប់ស្ងាត់ ថ្វីត្បិតតែមានការទម្លាក់គ្រាប់បែកខ្លះនៅមិនឆ្ងាយពីកន្លែងយើងក្តី។ ដោយសារថ្ងៃនេះគឺជាថ្ងៃអាទិត្យ ខ្ញុំគិតថាអ្នកបើកយន្តហោះរបស់សត្រូវប្រហែលជាឆ្លៀតឱកាសឈប់សម្រាកមួយថ្ងៃ ហើយឱ្យយើងស្រណុកចិត្តបន្តិច។ ប៉ុន្តែជាក់ស្តែងគឺមិនមែនអ៊ីចឹងទេ! នៅម៉ោងប្រហែល ៩ និង ០០ នាទីយន្តហោះជាច្រើនបានហោះជុំវិញជំរំរបស់យើង។ អ្នកតស៊ូរបស់យើងប្រាប់ថា នេះគឺមានន័យថាសត្រូវត្រៀមនឹងទម្លាក់គ្រាប់បែក និងបានប្រាប់ឱ្យខ្ញុំទៅជម្រកលាក់ខ្លួន។ ពេលនោះ ខ្ញុំកំពុងតែមានសាប៊ូចូលភ្នែក និងបំពោកសាប៊ូនៅលើពាសពេញខ្លួនប្រាណ។ ខ្ញុំប្រវេប្រវាសម្អាតខ្លួនយ៉ាងឆាប់រហ័ស និងទៅលាក់ខ្លួនជាមួយអ្នកដទៃទៀត។

ជាសំណាងល្អ គ្រាប់បែកមិនបានទម្លាក់ចំ "ភូមិ" របស់យើងទេ។ ខ្ញុំអាចមើលឃើញយ៉ាងច្បាស់ យន្តហោះប្រភេទ បេ៥២ ដែលមានទំហំធំប៉ុនទូកយ៉ាងច្បាស់ក្រឡែត ខណៈដែលយន្តហោះកំពុងហោះបន្ទាបខ្លួន ហើយមានយន្តហោះប្រភេទ អេហ្វ១០៥ជាច្រើនព័ទ្ធនៅសងខាង។ ពិតជាចម្លែកណាស់ដែលយន្តហោះសត្រូវហោះពីលើយើងដោយឥតឈប់ឈរ! តើសត្រូវកំពុងតែសង្ស័យអ្វីមួយឬយ៉ាងដូម្តេច? វិទ្យុនៅទីក្រុងម៉ានីល បានផ្សព្វផ្សាយនៅព្រឹកនេះជាភាសាអង់គ្លេសថាសត្រូវបានធ្វើតាមសំណើរបស់ជនក្បត់ជាតិ លន់ នល់ ដោយបន្តការទម្លាក់គ្រាប់បែកនៅលើទឹកដីប្រទេសកម្ពុជាទាំងមូលក្នុងរយៈពេលដប់ប្រាំបីថ្ងៃបន្តបន្ទាប់គ្នា! ជាការពិតណាស់ ពួកចក្រពត្តិនិយមទាំងនេះ មានអាកប្បកិរិយាច្រឡោមខាម និងឌឺដងចំពោះមតិអន្តរជាតិដែលថ្កោលទោសលើខ្លួន! ជាថ្មីម្តងទៀត នៅល្ងាចនេះយើងនៅតែមិនអាចចាកចេញដំណើរបាននោះទេ។ ប្រសិនបើការទម្លាក់គ្រាប់បែកទាំងនេះមិនបានកើតឡើង យើងប្រហែលជាទៅជិតដល់ព្រំដែនបាត់ទៅហើយ។ ប៉ុន្តែ នេះមិនបានធ្វើឱ្យសម្តេចខកព្រះទ័យឡើយ ផ្ទុយទៅវិញគឺព្រះអង្គសប្បាយព្រះទ័យទៅវិញទេ ដែលព្រះអង្គអាចពន្យារពេលស្នាក់នៅក្នុងប្រទេសកម្ពុជាបានយូរជាងមុន! នៅពេលរសៀល យើងចូលដំណេកដោយស្លៀកសម្លៀកបំពាក់សម្រាប់ធ្វើដំណើរ ដើម្បីត្រៀមខ្លួនរួចរាល់អាចចេញដំណើរបានភ្លាមៗ។

# ថ្ងៃទី ២៨ ~ ថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៧៣

យប់មិញ ខ្ញុំសម្រាកដំណេកមិនលក់ទាល់តែសោះ ប៉ុន្តែសម្តេចទ្រង់អាចផ្ទំលង់លក់ធម្មតា។ យើងស្លៀកសម្លៀកបំពាក់ និងរៀបចំរបស់របរប្រួចរាល់ជាស្រេច ដើម្បីត្រៀមខ្លួនចេញដំណើរបានគ្រប់កាលៈទេសៈ។ សត្រូវបានទម្លាក់គ្រាប់បែកជាច្រើនគ្រាប់នៅជុំវិញជំរំរបស់យើង។

មើលទៅយើងប្រហែលជាត្រូវចាកចេញនៅល្ងាចនេះហើយ បើទោះបីជាការទម្លាក់គ្រាប់បែកនៅតែបន្តក៏ដោយ ពីព្រោះបើយើងនៅកន្លែងនេះបន្ថែមមួយថ្ងៃទៀត គឺពិតជាមានគ្រោះថ្នាក់ខ្លាំងសម្រាប់យើង។ ការធ្វើដំណើរនៅតាមផ្លូវអាចប្រឈមនឹងការលំបាកខ្លាំង ពីព្រោះការទម្លាក់គ្រាប់បែកកាន់តែខិតមកជិតជំរំយើង។ ម្យ៉ាងវិញទៀត ដោយសារតែអំឡុងពេលនេះគឺជាខែរនោច វានឹងកាន់តែងងឹតថែមទៀត។ ផ្លូវនេះមានគ្រោះថ្នាក់ខ្លាំង ជាពិសេសដោយសារតែមានគ្រាប់បែកពន្យារពេលផ្ទុះរាប់រយគ្រាប់នៅមិនទាន់ផ្ទុះនៅឡើយ។ ទោះជាយ៉ាងណាក៏ដោយ យើងជឿជាក់លើទេវតា និងបងប្អូន នៃចលនាតស៊ូរបស់យើង។

ខ្ញុំបានបេះរបៀបចងអង្រឹងដូចអ្នកតស៊ូដែរ ហើយខ្ញុំមានមោទកភាពចំពោះខ្លួនឯងណាស់! នៅល្ងាចម្សិលមិញ យោងតាមព័ត៌មានទទួលបានមកពីប្រទេសចិន មេបញ្ជាការកងអាកាស សូ ភូត្រា ព្រះធីតុបតីរបស់សម្តេច ដែលបានទម្លាក់គ្រាប់បែកនៅវិមានរបស់ លន់ នល់ បានរត់គេចខ្លួនទៅដល់កោះហៃណានប្រទេសចិន។ យើងសប្បាយចិត្តណាស់ បន្ទាប់ពីបានទទួលដំណឹងនេះ! គឺពិតជាការប្រថុយប្រថានខ្លាំងណាស់សម្រាប់អ្នកបើកយន្តហោះ ដែលត្រូវហោះហើរយន្តហោះតូចប្រភេទ តេ២៨ ពីទីក្រុងភ្នំពេញទៅដល់កោះហៃណាន! លើសពីនេះទៅទៀត គឺត្រូវហោះឆ្លងកាត់វៀតណាមខាងត្បូង! ខ្ញុំក៏បានទទួលសារពីលោកជំទាវភរិយារបស់សម្តេច ប៉ែន នុត[២៣] ដែលផ្តល់ឱ្យខ្ញុំនូវអារម្មណ៍ធូរស្បើយ។ ថ្វីបើមានចម្ងាយឆ្ងាយរវាងយើងនិងប្រទេសចិនពិតមែន យើងនៅតែអាចរក្សាទំនាក់ទំនងជាមួយគ្នារហូត។ នៅពេលដែលខ្ញុំកំពុងសរសេរសៀវភៅកំណត់ហេតុនេះមានសត្វកំប្រុកពីរក្បាលបានប្រឡែងលេងជាមួយគ្នា និងលោតពីដើមឈើមួយទៅដើមឈើមួយទៀត។

---

២៣. កំណត់ហេតុរបស់អ្នកបកប្រែភាសាអង់គ្លេសៈ លោកជំទាវ ប៉ែន នុត សំដៅដល់ភរិយារបស់សម្តេច ប៉ែន នុត ដែលជានាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។

ប្រាកដជាល្អខ្លាំងណាស់ ប្រសិនបើយើងអាចស្នាក់នៅក្នុងភូមិនេះបានយូរជាងនេះដោយគ្មានយន្តហោះសត្រូវហោះទៅវិញទៅមក។ សត្រូវពិតជាចាប់ផ្តើមធ្វើឱ្យខ្ញុំធុញទ្រាន់ហើយ។ សមមិត្ត ប៉ាំង បានយកផ្លែ “មាក់ប្រាង” ដ៏ឈ្ងុយឆ្ងាញ់មកឱ្យយើង។ ផ្លែឈើនេះ បេះចេញពីក្នុងព្រៃប្រទេសកម្ពុជាយើងវាមានពណ៌លឿង និងមានទឹកច្រើន។ នេះគឺជាលើកដំបូងក្នុងរយៈពេលបីឆ្នាំកន្លងមកហើយដែលយើងបានឃើញផ្លែមាក់ប្រាង។



# ថ្ងៃទី ២៩ ~ ថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៣

ថ្ងៃនេះ យើងនៅរស់រានមានជីវិតនៅឡើយ! ខ្ញុំត្រូវរំឭកឡើងវិញនូវព្រឹត្តិការណ៍ដែលកើតឡើងកាលពីល្ងាចម្សិលមិញ ដោយសារតែកន្លែងដែលយើងស្នាក់នៅពេលនេះ មានសភាពប្រសើរជាង បើប្រៀបធៀបទៅនឹងអន្លង់ក្រមួន។ យើងបានឈប់សម្រាកនៅក្នុងព្រៃមួយ ដែលមិនសូវមានដើមឈើលាស់បៃតងស្រងាត់ ហើយយើងត្រូវសម្រាកនៅក្នុងអង្រឹងដោយគ្មានអ្វីដណ្ដប់ ពីព្រោះកន្លែងដែលត្រូវជ្រើសរើសដើម្បីទទួលយើងកាលពីល្ងាចម្សិលមិញ ប្រកបដោយគ្រោះថ្នាក់ខ្លាំងពេក។ ហេតុនេះយើងត្រូវបន្តដំណើររហូតមកដល់ទីកន្លែងនេះនៅម៉ោង ៦ និង ០០ នាទីព្រឹក។

យើងបានសម្រាក ហើយខ្ញុំមានឱកាសសរសេររៀបរាប់អំពីព្រឹត្តិការណ៍ថ្មីៗមួយចំនួនដែលបានកើតឡើង។ នៅម៉ោងប្រហែល ១៨ និង ០០ នាទីល្ងាចម្សិលមិញ យើងបាននិយាយលាលោក ហ៊ូ យន់ និងភរិយារបស់លោក ព្រមទាំង លោក ហ៊ូ នឹម ដោយសារតែយើងត្រូវកាត់បន្ថយចំនួនអ្នករួមដំណើរ ពីព្រោះតែបញ្ហាសន្តិសុខ។ ការលាគ្នាទៅវិញទៅមក ប្រកបដោយភាពមិនដាច់អាល័យ។ សម្ដេច និងមេដឹកនាំទាំងពីរនៃចលនាតស៊ូបានឱបគ្នាយ៉ាងកក់ក្ដៅហើយសន្យាថានឹងជួបគ្នាក្នុងពេលមួយឆ្នាំទៀត។ ភរិយារបស់លោក ហ៊ូ យន់ និងខ្ញុំបានឱបគ្នាយ៉ាងកក់ក្ដៅព្រមទាំងជូនពរនិងអរគុណគ្នាទៅវិញទៅមក។ យើងនិយាយគ្នាច្រើនដើម្បីបន្លប់អារម្មណ៍ពិតរបស់យើង។ ប៉ុន្តែគ្រាន់តែគិតថាយើងនឹងជួបគ្នាម្ដងទៀតនៅឆ្នាំក្រោយ ធ្វើឱ្យការលាគ្នានៅពេលនេះមិនសូវពិបាកទទួលយក។

រស់នៅក្នុងជីវិតតស៊ូជាមួយគ្នាអស់រយៈពេលបីសប្ដាហ៍កន្លងមកនេះ យើងកាន់តែមានកោតសរសើរបងប្អូនរបស់យើងដែលតស៊ូនៅក្នុងប្រទេស ចំពោះភាពក្លាហាន ភាពមុះមុត និងសុទិដ្ឋិនិយម។ សម្ដេចនិងខ្ញុំចាប់ផ្ដើមទម្លាប់ខ្លួនជាមួយនឹងជីវិតរស់នៅបែបនេះ ទោះបីជាពិបាកបន្តិចមែន ប៉ុន្តែគួរឱ្យរំភើបណាស់! អាចនិយាយបានថា យើងក៏បានតស៊ូប្រឆាំងនឹងជនឈ្លានពានបរទេស និងបក្ខពួក។ នេះគឺដោយសារតែមិនមែនងាយស្រួលសម្រាប់យើងក្នុងការគេចខ្លួនពីអ្នកស៊ើបការណ៍ និងការទម្លាក់គ្រាប់បែកផតឈប់ឈររបស់សត្រូវទេ!

បន្ទាប់មក យើងបានធ្វើដំណើរចម្ងាយដប់ប្រាំបួនគីឡូម៉ែត្រពីអន្លង់ក្រមួនទៅកាន់ទន្លេមេគង្គទាំងយប់ងងឹតក្នុងល្បឿនយឺតៗ។ យុទ្ធជនម្នាក់បានដើរនៅពីមុខឡានហ្ស៊ីបរបស់យើងដើម្បីនាំផ្លូវ ពីព្រោះយើងមើលមិនឃើញអ្វីទាំងអស់។ នៅពេលទៅដល់មាត់ទន្លេ យើងឈប់រង់ចាំ ដើម្បីស្ដាប់សភាពការណ៍មួយភ្លែត។ នៅពេលឃើញថាស្ថានភាពស្ងប់ស្ងាត់ល្អ យើងប្រញាប់ប្រញាល់ឡើងលើទូកហើយឆ្លងទឹកទន្លេក្នុងរយៈពេលត្រឹមតែដប់នាទី។ បេះដូងខ្ញុំលោតញាប់ខ្លាំង ពីព្រោះប្រសិនបើយន្តហោះប្រភេទ អេស៊ី១៣០ វិលត្រឡប់មកវិញ ខ្ញុំនឹងមិនមានជីវិតដើម្បីបន្តសរសេរសៀវភៅកំណត់ហេតុរបស់ខ្ញុំបានទេនៅថ្ងៃនេះ!

នៅពេលទៅដល់ច្រាំងទន្លេម្ខាងទៀត យើងចុះពីលើទូកយ៉ាងរហ័ស។ នៅពេលនោះ យន្តហោះសត្រូវបានវិលត្រឡប់មកវិញនៅច្រាំងទន្លេម្ខាងទៀត! សត្រូវចាប់ផ្ដើមទម្លាក់គ្រាប់បែកគ្រប់ទីកន្លែងនៅលើផ្លូវដែលយើងទើបតែចាកចេញមុននេះបន្តិច! យើងអាចមើលឃើញពន្លឺភ្លើងពណ៌ក្រហមព្រាកៗនៅលើមេឃរាល់ពេលដែលយន្តហោះប្រភេទ បេ៥២ទម្លាក់គ្រាប់បែក! យើងអាចនិយាយមើលទៅហាក់បីដូចជាភ្នំភ្លើងដែលកំពុងផ្ទុះ!

ការទម្លាក់គ្រាប់បែកមានរយៈពេលមួយម៉ោង ខណៈពេលដែលយើងលាក់ខ្លួននៅក្រោមដើមស្វាយធំមួយ។ នៅពេលដែលគិតថាយើងមកដល់មុនសត្រូវត្រឹមតែរយៈពេលពីរនាទីប៉ុណ្ណោះខ្ញុំមានអារម្មណ៍ភ្ញាក់ព្រឺត! សត្រូវក៏បានឆ្លងមកទម្លាក់គ្រាប់បែកនៅច្រាំងទន្លេខាងយើងដែរ ប៉ុន្តែនៅឆ្ងាយតែបន្តិចពីដើមស្វាយដែលយើងកំពុងលាក់ខ្លួន។ នៅពេលស្ថានភាពស្ងប់ស្ងាត់ទៅវិញ យើងបន្តដំណើរនៅក្នុងរថយន្តចិនចំណាស់មួយគ្រឿងវិញម្ដង។ រថយន្តឡង់រ៉ូវើចាស់នោះ មានតែមួយគ្រឿង ហើយមិនអាចផ្ទុកយើងទាំងអស់គ្នាបាន។ ម៉្យាងវិញទៀត រថយន្តនេះមិនដំណើរការល្អ។ សម្ដេចនិងខ្ញុំ គង់នៅជួរខាងមុខក្បែរអ្នកបើកបរ រីឯលោក ខៀវ សំផន, លោក អៀង សារី, លោក សុន សេន, និងលោក សាឡុត ស ព្រមទាំងកម្មាភិបាលមួយចំនួនទៀតអង្គុយនៅខាងក្រោយ។ រថយន្តនេះជាប្រភេទរថយន្តគ្មានដំបូលគ្របពីក្រោយ។

យើងបានផ្លាស់ប្ដូររថយន្តអស់ជាច្រើនគ្រឿងមកហើយ ចាប់តាំងពីការចាប់ផ្ដើមដំណើរមក។ ដំបូងយើងប្រើប្រាស់រថយន្តម៉ាកហ្ស៊ីបរបស់រុស្ស៊ី បន្ទាប់មករថយន្តឡង់រ៉ូវើរបស់អង់គ្លេស បន្ទាប់មកទៀតគឺ រថយន្តម៉ែកហ្សីដេសរបស់អាល្លឺម៉ង់, ក្រោយមកគឺរថយន្តបារាំង ៤០៤, និងចុងក្រោយគឺរថយន្តចិន! យើងធ្វើដំណើរយឺតៗក្នុងទីងងឹតដោយឈប់រៀងរាល់១៥នាទីម្ដង។ ប៉ុន្តែរាល់ពេលដែល យើងត្រូវបន្តដំណើរទៅមុខទៀត អ្នកបើកបររវើបញ្ឆេះម៉ាស៊ីនដោយបង្ខំជាច្រើនដង។ បើមិនធ្វើបែបនេះទេ ឡាននឹងមិនដំណើរការទៅមុខឡើយ។ ឡានមួយគ្រឿងនេះគឺពិតជាចាស់មែនទែន! យើងធ្វើដំណើរពេញមួយយប់ ដូចនេះហើយ នៅម៉ោងប្រហែល ៦ និង ០០ នាទីព្រឹក យើងបានមកដល់ដោយសុវត្ថិភាពនៅក្នុងព្រៃដែលមានចម្ងាយប្រហែលម្ភៃប្រាំគីឡូម៉ែត្រពីស្រុកសៀមប៉ាង។ តំបន់នេះមិនសូវមានគ្រោះថ្នាក់នោះទេ ពីព្រោះថាមិនសូវមានការទម្លាក់គ្រាប់បែកច្រើន។

ព្រឹកនេះយើងសោយ "ប្រ៊ូមក្វាន" មួយកំប៉ុង ដែលយើងបានយកមកពីទីក្រុងប៉េកាំង ហើយបានរក្សាទុកសម្រាប់ថ្ងៃដែលយើងខ្វះស្បៀងអាហារ!

# ថ្ងៃទី ៣០ ~ ថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៧៣

ឱ! អូរតាង៉ូវ! ថ្ងៃនេះយើងនៅអូរតាង៉ូវ! បន្ទាប់ពីធ្វើដំណើរឆ្លងកាត់ផ្លូវដ៏លំបាក យើងបានមកដល់ទីនេះនៅម៉ោងប្រហែល ១០ និង០០ នាទីព្រឹក។ បន្ទាប់ពីសម្រាកបានគ្រប់គ្រាន់ហើយ ខ្ញុំនឹងព្យាយាមសរសេរអំពីព្រឹត្តិការណ៍ដែលបានកើតឡើងកាលពីម្សិលមិញ។

យើងចាកចេញពីក្នុងព្រៃនៅម៉ោង ២២ និង ០០ នាទី ហើយធ្វើដំណើរដោយប្រើប្រាស់ រថយន្តរបស់ចិនដូចដើម។ មុនពេលចាកចេញ យើងបាននិយាយលាលោក សាឡុត ស ដូច្នេះគឺនៅសល់តែលោក ខៀវ សំផន, សុន សេន និងអៀង សារី ដែលនឹងត្រឡប់ ទៅប្រទេសចិន វិញជាមួយយើង។

សម្តេចបានប្រោសព្រះរាជទានកាមេរ៉ាដល់លោក ហ៊ូ នឹម ចំណែកខ្ញុំវិញ បានទុកថ្នាំពេទ្យខ្លះជូនលោកស្រី ខៀវ ប៉ុណ្ណារី និងលោកស្រីភរិយាលោក ហ៊ូ យន់។ ខ្ញុំក៏បានឱ្យឧបករណ៍ចាក់កាសែ្សតស្តាប់ របស់ខ្ញុំទៅលោក ហ៊ូ យន់ និងម៉ាស៊ីនថតរូបប្រភេទប៉ូឡារ៉ូដរបស់ខ្ញុំទៅឱ្យលោក សុន សេន។ ចំណែកឯយុទ្ធជនទាំងពីរដែលជាអង្គរក្សរបស់យើងនិងបានមើលថែសុវត្ថិភាពយើងទាំងយប់ទាំងថ្ងៃ គឺ ហុង និង ប៉ាង បានទទួលនាឡិកាមួយម្នាក់ពីសម្តេច។

យើងបានផ្តាំផ្ញើលោក ហ៊ូ នឹម ឱ្យប្រគល់វត្ថុអនុស្សាវរីយ៍មួយចំនួនថ្វាយព្រះអង្គម្ចាស់ ភូរីស្សរ៉ា[២៤] និងភរិយាព្រមទាំងបុត្រារបស់សម្តេច ដូចជាព្រះអង្គម្ចាស់ រាវីវង្ស និង ព្រះអង្គម្ចាស់ ខេមានុរក្ស[២៥] ដែលមិនអាចមកជួបយើងបានពីព្រោះពួកទ្រង់នៅតំបន់ឆ្ងាយ។ យើងបានបន្តដំណើរដោយមិនមានភ្លើងបំភ្លឺផ្លូវ យ៉ាងពពីមពពើម ព្រោះគ្មានពន្លឺព្រះចន្ទបំភ្លឺទៀតឡើយ។ អ្នកតស៊ូម្នាក់គឺសមមិត្ត ហុង បានក្រោកឈរឡើងនៅលើរឺមក្បែរអ្នកបើកបររថយន្តដើម្បីប្រាប់ផ្លូវទៅកាន់ទិសដៅបន្ទាប់។

---

២៤. ព្រះអង្គម្ចាស់នរោត្តមភូរីស្សរ៉ាគឺជាអតីតរដ្ឋមន្ត្រីក្រសួងការបរទេសប្រទេសកម្ពុជាដែលត្រូវបានខ្មែរក្រហមប្រហារជីវិតនៅឆ្នាំ ១៩៧៦។

២៥. ព្រះអង្គម្ចាស់ នរោត្តម រាវីវង្សនិងព្រះអង្គម្ចាស់ នរោត្តម ខេមានុរក្ស គឺជាបុត្រារបស់សម្តេចព្រះ នរោត្តម សីហនុ និងព្រះនាងស៊ីសុវត្ថិ ពង្សាមុនី ដែលជាបុត្រីរបស់ព្រះមហាក្សត្រស៊ីសុវត្ថិ មុនីវង្ស។ ព្រះអង្គម្ចាស់ទាំងពីរអង្គ បានចូលរួមក្នុងការតស៊ូបន្ទាប់ពីរដ្ឋប្រហារខែមីនា ឆ្នាំ១៩៧០។ព្រះអង្គម្ចាស់រាវីវង្ស បានសោយទិវង្គតនៅក្នុងព្រៃដោយសារជំងឺគ្រុនចាញ់នៅខែសីហា ឆ្នាំ១៩៧៣។ ខ្មែរក្រហមបានធ្វើគុតព្រះអង្គម្ចាស់ ខេមានុរក្ស ក្នុងឆ្នាំ១៩៧៦។

នៅពេលយើងទៅជិតដល់ស្រុកសៀមប៉ាង សមមិត្ត ហុង បានចុះពីលើរថយន្តហើយដើរនៅពីខាងមុខដើម្បីប្រាប់ផ្លូវអ្នកបើកបរ។ ផ្លូវនេះទទួលរងការទម្លាក់គ្រាប់បែក កាលពីប៉ុន្មានថ្ងៃមុនទម្លាក់ដោយយន្តហោះប្រភេទ បេ៥២ និងបានបន្សល់ទុករណ្តៅជាងមួយរយ ហើយនៅពេលរសៀលខ្លះ គ្រាប់បែកបង្កោមដែលមិនទាន់ផ្ទុះមួយចំនួនបានផ្ទុះឡើង។ យើងគិតថាអាចនៅមានគ្រាប់បែកដែលមិនទាន់ផ្ទុះដទៃទៀត នៅជុំវិញកន្លែងរបស់យើង។ ហើយប្រសិនបើយើងប៉ះត្រូវមួយគ្រាប់ណា... នោះនឹងជាទីអវសានរបស់យើងមិនខាន!

យើងមកដល់ស្រុកសៀមប៉ាងនៅម៉ោង ៣ និង ០០ នាទីព្រឹក ហើយបានឆ្លងកាត់ទន្លេសេកុងភ្លាមៗ។ នៅលើច្រាំងទន្លេម្ខាងទៀត មិត្តវៀតណាមកំពុងរង់ចាំទទួលយើង។ មិត្តវៀតណាមមានការព្រួយបារម្ភយ៉ាងខ្លាំង ពីព្រោះមិនមានដំណឹងអំពីស្ថានភាពរបស់យើង ហើយពួកគេដឹងថាយើងស្ថិតនៅក្រោមការគំរាមកំហែងប្រចាំថ្ងៃពីយន្តហោះសត្រូវ។ មិត្តវៀតណាមបានស្នើសុំឱ្យយើងស្រូតដំណើរដើម្បីទៅដល់អូរតាង៉ូវ ពីព្រោះនៅទីនោះនឹងមិនសូវមានគ្រោះថ្នាក់។ ដូច្នេះ យើងត្រូវនិយាយលាបងប្អូនដែលតស៊ូនៅក្នុងប្រទេសត្រឹមនេះពីព្រោះពួកគេត្រូវវិលត្រឡប់ទៅតស៊ូនៅជួរមុខវិញ។

លោក ខៀវ សំផន បានលើកឡើងថានៅពេលដែលបងប្អូនជិតនឹងឃ្លាតចេញពីសម្តេច បងប្អូនរឹតតែគិតរំពៃដល់សម្តេចជាងមុន។ សម្តេចបានឆ្លើយតបថា ព្រះអង្គពុំដែលមានព្រះបំណងចាកចេញពីបងប្អូននៃចលនាតស៊ូនិងពីប្រទេសកម្ពុជាឡើយ! សម្តេចមានរាជបន្ទូលបន្ថែមថា“ប៉ុន្តែយើងនឹងជួបគ្នាម្តងទៀតនៅឆ្នាំក្រោយ”។ “សូមសម្តេចយាងត្រឡប់មកវិញឱ្យបានញឹកញាប់។ ព្រះរាជវត្តមានរបស់សម្តេច គឺជាសេចក្តីអំណរ និងជាការលើកទឹកចិត្តដ៏ធំមួយសម្រាប់ប្រជានុរាស្ត្រកម្ពុជា” លោក ខៀវ សំផន បានក្រាបបង្គំទូលតបទៅសម្តេច។ ការនិយាយលាគ្នាលើកនេះ ពោរពេញដោយអារម្មណ៍រំជួលចិត្តយ៉ាងខ្លាំង ពីព្រោះបន្ទាប់ពីនេះមក យើងនឹងបន្តដំណើរជាមួយមិត្តវៀតណាម។ យើងបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបងប្អូនទាំងអស់ដែលបានមើលថែទាំយើង ក្នុងអំឡុងពេលធ្វើដំណើរមកកាន់ប្រទេសកម្ពុជា បន្ទាប់មកយើងចូលទៅក្នុងរថយន្តហ្ស៊ីបដោយអារម្មណ៍ក្តុកក្តួលបំផុត ...

ចាប់ពីម៉ោង ៥ និង ០០ នាទី ដល់ ១០ និង ០០ នាទីព្រឹក យើងបានធ្វើដំណើរក្នុងល្បឿនយ៉ាងលឿន! ហាក់បីដូចជាកំពុងប្រណាំងរថយន្ត! ចាប់តាំងពីចាកចេញពីដុងហូយមក នេះគឺជា លើកទីមួយហើយដែលអ្នកបើកបរជនជាតិវៀតណាមរបស់យើងបើករថយន្តលឿនខ្លាំងបែបនេះ។ ខ្ញុំបានសួរពីមូលហេតុ។ អ្នកបើកបរបានឆ្លើយតបថា“ យើងត្រូវតែឆ្លងកាត់តំបន់គ្រោះ ថ្នាក់ឱ្យបានលឿនតាមដែលអាចធ្វើទៅបាន”។ តាមការពិតនៅតាមសងខាងផ្លូវនិងសូម្បី តែនៅលើផ្លូវ យើងអាចឃើញរណ្តៅធំៗដោយសារតែការទម្លាក់គ្រាប់បែករបស់យន្តហោះប្រភេទ បេ៥២ កាលពីប៉ុន្មានថ្ងៃមុន។ នៅមានដើមឈើដែលកំពុងឆេះភ្លើងនៅឡើយ...បីសប្តាហ៍មុននៅតាម ផ្លូវចូលទៅកាន់ប្រទេសកម្ពុជាមិនមានហេតុការណ៍បែបនេះកើតឡើងទេ។ ផ្លូវនៅល្អធម្មតា ហើយមេឃមានសភាពស្ងប់ស្ងាត់។

អ្នកបើកបររបស់យើងពិតជាគួរឱ្យកោតសរសើរណាស់! អ្នកបើកបរផ្សេងប្រហែលជាបើកធ្លាក់រណ្តៅបាត់ទៅហើយ។ ជារឿយៗខ្ញុំអាចឃើញដើមឈើនៅចំពីមុខ ប៉ុន្តែរថយន្តរបស់យើងតែងតែជៀសផុត! ហើយដោយសភាពបែបនេះ បន្ទាប់ពីឆ្លងកាត់ផ្លូវលំបាកខ្លាំងផង និងទាំងញាប់ញ័រក្នុងអារម្មណ៍ផង យើងបានមកដល់អូរតាង៉ូវនៅពេលព្រឹក។ នេះគឺជាចំណតចុងក្រោយរបស់យើងនៅលើទឹកដីកម្ពុជា។ ថ្ងៃនេះគឺជាថ្ងៃឈប់សម្រាកសម្រាប់យើង។ យើងនឹងបន្តដំណើររបស់យើងបន្តទៀតនៅម៉ោង ៣ និង ០០ នាទីព្រឹក នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៣។

# ថ្ងៃទី ៣១ ~ ថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧៣

នៅព្រឹកនេះ យើងសម្រាកបានយូរ។ មិត្តវៀតណាមបានជូនរោមសត្វក្រោកដ៏ស្រស់ស្អាតមកយើង។ បន្ទាប់មក មិត្តវៀតណាម បានរៀបចំពិធីជប់លៀងអាហារពេលល្ងាចតូចមួយដើម្បី អបអរសាទរជោគជ័យរបស់យើង ហើយជូនពរឱ្យយើងធ្វើដំណើរប្រកបដោយសុវត្ថិភាព។

យើងត្រូវចូលសម្រាកឥឡូវនេះហើយ ព្រោះនៅម៉ោង ៣ និង ០០ នាទី យើងនឹងចាកចេញពីអូរតាង៉ូវ និងប្រទេសកម្ពុជា។ លាហើយមាតុភូមិជាទីស្នេហា ខ្ញុំប្រាកដជាត្រឡប់មកវិញ! ខ្ញុំបានចំណាយពេលបីសប្តាហ៍ដែលមិនអាចបំភ្លេចបានជាមួយបងប្អូននិងអ្នកតស៊ូរបស់យើង។ ខ្ញុំអាចទៅទស្សនាកន្លែងដែលខ្ញុំស្រឡាញ់ ដូចជា ប្រាសាទអង្គរវត្ត, ប្រាសាទបាយ័ន, ប្រាសាទបន្ទាយស្រី, និងភ្នំគូលែន។ យើងនឹងជួបគ្នាម្តងទៀតនៅឆ្នាំក្រោយ!

# ថ្ងៃទី ៣២ ~ ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៣

នៅម៉ោងប្រហែល ៤ និង ០០ នាទីព្រឹក យើងចាកចេញពីអូរតាង៉ូវហើយឈានចូលទៅក្នុងទឹកដីប្រទេសឡាវ។ ដូច្នេះយើងបានចាកចេញពីមាតុភូមិជាទីស្រឡាញ់របស់យើងហើយ! យើងមានអារម្មណ៍សោកសង្រេង ពីព្រោះមានការចងចាំជាច្រើនប្រកបដោយអនុស្សាវរីយ៍កើតមានឡើង ក្នុងរយៈពេលបីសប្តាហ៍នៅក្នុងប្រទេសកម្ពុជា។ ប៉ុន្តែយើងមាន សុទិដ្ឋិនិយម ពីព្រោះបងប្អូននៃបលនាតស្វ៊ូបានអញ្ជើញយើងឱ្យត្រឡប់មកវិញញឹកញាប់តាមដែលកាលៈទេសៈអនុញ្ញាត។ ថ្ងៃណាមួយ យើងនឹងវិលត្រឡប់មកវិញ និងស្នាក់នៅក្នុងប្រទេសជារៀងរហូត។ នៅពេលនោះប្រទេសកម្ពុជានឹងត្រូវបានរំដោះទាំង ស្រុងនិងយ៉ាងពិតប្រាកដ!

បន្ទាប់ពីបានធ្វើដំណើរអស់មួយរយម្ភៃគីឡូម៉ែត្រ យើងបានមកដល់សេស្វនៅម៉ោង ១០ និង ៣០ នាទីព្រឹក។ ផ្លូវដែលយើងធ្វើដំណើរមកកាន់ទីនេះ គឺពិតជាពិបាកណាស់។ ក្នុងអំឡុងពេលធ្វើដំណើរ ខ្ញុំបាននឹកឃើញពាក្យសម្តីរបស់ឧត្តមសេនីយ៍ យ៉ាប ប្រាប់មកយើងមុនពេលចាកចេញ ពីទីក្រុងហាណូយថា "អ្នកនឹងមានអារម្មណ៍ហាក់បីដូចជាកំពុងជិះសេះនៅក្នុងរថយន្តហ្ស៊ីបអ៊ុឹចឹង!" ហើយនេះគឺជាអារម្មណ៍ដែលខ្ញុំមានអារម្មណ៍នៅពេលឥលូវនេះ! ជារៀងរាល់ថ្ងៃ ខ្ញុំតោងកៅអីជួរមុខរបស់ឡានហ្ស៊ីបជាប់នៅរាល់ពេលដែលកំពុងធ្វើដំណើរដើម្បីទប់លំនឹងខ្លួនកុំឱ្យរលាក់ខ្លាំងពេក។ ប៉ុន្តែវិធីនេះមិនបានជួយអ្វីច្រើនទេ ហើយបាតដៃខ្ញុំចាប់ផ្តើមក្រិន។ យើងនឹងចំណាយពេលពេញមួយថ្ងៃ និងសម្រាកមួយយប់នៅទីនេះ។ យើងនឹងបន្តដំណើរនៅម៉ោងប្រហែល ៣ និង ០០ នាទីព្រឹក ដើម្បីឆ្ពោះទៅកាន់សេណាំណយ។ យើងនឹងធ្វើដំណើរតាមផ្លូវគោកចម្ងាយមួយរយគីឡូម៉ែត្រ បន្ទាប់មកជិះកាណូតដើម្បីឆ្លងកាត់ទន្លេសេកុង មុននឹងទៅដល់គោលដៅ។

ក្រៅពីផ្លូវដែលពិបាកខ្លាំង មានរឿងមួយទៀតដែលផ្លាស់ប្តូរបរិយាកាសនៃការធ្វើដំណើររបស់យើង។ ចាប់ពីត្រង់កន្លែងនេះទៅ យើងនឹងឮសូរសំឡេងយន្តហោះកាន់តែតិចទៅៗ។ នៅទីកន្លែងនេះមានសភាពស្ងប់ស្ងាត់ បើប្រៀបធៀបទៅនឹងប្រទេសកម្ពុជា។ យោងតាមព័ត៌មានចុងក្រោយពីប្រភពដែលអាចជឿទុកចិត្តបាន ជនឈ្លានពានបរទេសបានបញ្ជូនយន្តហោះប្រភេទ បេ៥២ ចំនួន៧៨គ្រឿង ដើម្បីទម្លាក់គ្រាប់បែកទៅលើប្រទេសរបស់យើងជារៀងរាល់ថ្ងៃ! ហើយ លន់ នល់ បានបញ្ជាឱ្យកងកុម្មង់ដូ ទម្លាក់គ្រាប់បែកនៅម្តុំស្រុកសៀមប៉ាងនៅថ្ងៃទី២៦ ខែមីនា ដើម្បីចាប់ខ្លួននិងធ្វើឃាតយើង។ សត្រូវពិតជាបានរិះរកសព្វគ្រប់វិធី។ ប៉ុន្តែទេវតាប្រទានពរឱ្យយើងចៀសផុតពីគ្រោះថ្នាក់ទាំងអស់នេះ ពីព្រោះយើងមិនដែលក្បត់ជាតិឬប្រជានុរាស្ត្រកម្ពុជានោះទេ ផ្ទុយទៅវិញគឺយើងតែងតែបម្រើជាតិដោយស្មោះស្ម័គ្រ។ យើងការពារបុព្វហេតុដ៏ត្រឹមត្រូវមួយរបស់យើង គឺឯករាជ្យភាពនៃប្រទេសកម្ពុជា។

# ថ្ងៃទី ៣៨ ~ ថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៣

យើងបានមកដល់សេណាំណាយព្រឹកនេះ នៅម៉ោង ៩ និង ០០នាទី។ ទីនេះ គឺជាកន្លែងដែលខ្ញុំចូលចិត្តបំផុត។ កន្លែងនេះ មានភាពស្រស់ស្អាតគួរឱ្យទាក់ភ្នែកអមជាមួយនឹងរុក្ខជាតិបៃតងស្រងាត់ ភ្នំនិងទន្លេ ដែលហូរនៅចំពីមុខខ្ទមរបស់យើង។ សម្តេចចុះសម្អាតព្រះកាយក្នុងទន្លេចំនួនពីរដងគឺនៅពេលព្រឹក និងពេលរសៀល។ នេះគឺពិតជាការសម្រាកដ៏ល្អសម្រាប់យើង។ ខ្ញុំក៏បានចុះហែលទឹកបន្តិចដែរនៅរសៀលនេះ។



សម្តេចឪ ព្រះអង្គបង្ហាញរូបថតក្នុងអំឡុងពេលយាងដំណើរទស្សនកិច្ចទៅកាន់នាយករដ្ឋមន្ត្រី ជូ អេនឡាយ និងមេដឹកនាំប្រទេសចិនដទៃទៀត

# ថ្ងៃទី ៣៥ ~ ថ្ងៃទី២ ខែមេសា ឆ្នាំ១៩៧៣

រាត្រីម្សិលមិញមានសភាពស្ងប់ស្ងាត់ល្អ។ ព្រឹកនេះយើងចុះងូតទឹកទន្លេ។ ថ្ងៃនេះ គឺជាថ្ងៃឈប់សម្រាកចុងក្រោយរបស់យើង។ យើងនឹងបន្តដំណើរនៅម៉ោង ១៦ និង ០០ នាទី ឆ្ពោះទៅកាន់គោលដៅបន្ទាប់។ ក្នុងរយៈពេលប៉ុន្មានថ្ងៃចុងក្រោយនេះ យើងបានទទួលសារដ៏ស្និទ្ធស្នាល និងកក់ក្ដៅជាច្រើនពីសម្ដេច ប៉ែន នុត, ថ្នាក់ដឹកនាំប្រទេសវៀតណាម, និងឯកឧត្ដមនាយករដ្ឋមន្ត្រី ផ្វ អេនឡាយ។ សារទាំង នេះបានបង្កើនទំនុកចិត្តនិងលើកទឹកចិត្តយើងឱ្យបន្តដំណើរដ៏វែងឆ្ងាយទៅមុខ នៅលើផ្លូវដែលរលាក់ និងហុយទូលោម ព្រមទាំងពោរពេញដោយគ្រោះថ្នាក់! ខណៈពេលដែលខ្ញុំកំពុងទម្រេតខ្លួនលើអង្រឹងនីឡុង ដែលជាអំណោយរបស់បងប្អូនខ្មែរយើង ខ្ញុំបាននឹករំពៃម្ដងទៀតអំពីដំណើរទស្សនកិច្ចប្រកបដោយអនុស្សាវរីយ៍ នាពេលថ្មីៗនេះនៅក្នុងមាតុភូមិរបស់យើង។ រាល់សកម្មភាពទាំងអស់របស់ខ្ញុំ ស្ថិតនៅជក់ជាប់ក្នុងចិត្តខ្ញុំ។

យើងនឹងមិនបំភ្លេចសេចក្តីស្រឡាញ់ ការស្វាគមន៍ដ៏កក់ក្ដៅ និងរាល់ទឹកចិត្តប្រពៃ ពីសំណាក់បងប្អូនអ្នកតស៊ូក្នុងផ្ទៃប្រទេស គឺចាប់ពីថ្នាក់ដឹកនាំជាន់ខ្ពស់រហូតដល់យុទ្ធជនតស៊ូទាំងឡាយ។ អនុស្សាវរីយ៍ ដែលមិនអាចកាត់ថ្លៃបានទាំងនេះ នឹងស្ថិតនៅក្នុងបេះដូងនិងស្មារតីរបស់សម្ដេចជារៀងរហូត។ ឥឡូវនេះ យើងទទួលបានកម្លាំងថ្មីមួយទៀត ដើម្បីបន្តបំពេញបេសកកម្មដែលប្រជា ជនយើងប្រគល់ឱ្យ គឺបន្តសកម្មភាពនៅក្រៅប្រទេសដើម្បីសម្រេចបាននូវការយល់ដឹង និងការគាំទ្រពីពិភពលោកទាំងមូល  បំពោះការតស៊ូដើម្បីឯករាជ្យភាពនិងការរំដោះប្រទេសជាតិរបស់យើង។

ក្រោយចាកចេញពីសេណាំណាយនៅម៉ោង ១៦ និង ០០ នាទី យើងបានមកដល់សេណាយ នៅម៉ោងប្រហែលជា ១៩ និង ០០ នាទី បន្ទាប់ពីធ្វើដំណើរដោយគ្មានបញ្ហាអ្វី។ ពុំឃើញមានយន្តហោះសត្រូវហោះកាត់ពីលើយើងទេ។ គណៈកម្មាធិការនយោបាយនៃមូលដ្ឋានយោធា បានអញ្ជើញយើងទៅទទួលទានអាហារពេលល្ងាច។ ថ្ងៃស្អែកយើងនឹងចាកចេញទៅកាន់ស៊ីឡាណុននៅម៉ោង ៦ និង ០០ នាទី។

# ថ្ងៃទី ៣៦ ~ ថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៣

យើងធ្វើដំណើរមកដល់ ស៊ីឡាណុន នៅម៉ោង ១១ និង ០០នាទី។ ដោយសារអាកាសធាតុក្តៅខ្លាំង យើងបានចុះងូតទឹកជ្រោះរហូតទាល់តែយន្តហោះប្រភេទ អេហ្វ ១០៥ ចំនួនពីរ ហោះមកជិត ទើបយើងត្រូវចាកចេញពីទឹកជ្រោះដោយសោកស្តាយ។ យើងពិតជារីករាយណាស់ដែលបានងូតទឹកត្រជាក់ក្រោមអាកាសធាតុក្តៅខ្លាំងបែបនេះ។ អាចនិយាយបានថា យើងពិតជាទាក់ទាញយន្តហោះសត្រូវមែនទែន។ មិនថាយើងទៅទីណា យន្តហោះសត្រូវតែងទៅដល់ទីនោះ! សំណាងល្អមិនមានមនុស្សច្រើននៅទីនេះ។ នៅរសៀលនេះ សម្តេច បានចុះសម្អាតព្រះកាយនៅទឹកជ្រោះម្តងទៀតយ៉ាងរហ័ស។ មិត្តវៀតណាម បានប្រគល់សេកដ៏ស្រស់ស្អាតចំនួនប្រាំបីក្បាលដាក់នៅក្នុងទ្រុងមួយដល់យើង! យើងនឹងនាំសត្វសេកទាំងនេះទៅប្រទេសចិន រួមជាមួយនឹងសត្វទោចចំនួនពីរក្បាលយកមកពីប្រទេសកម្ពុជា ដែលបានកំដរការធ្វើដំណើររបស់យើងពីភ្នំគូលែនមកបានយ៉ាងល្អ។ យើងនឹងបន្តដំណើរនៅល្ងាចនេះនៅម៉ោង ប្រហែល ២២ និង ០០ នាទី ពីព្រោះយើងត្រូវធ្វើដំណើរលើផ្លូវជាតិលេខ៩ ដ៏ល្បីល្បាញ និងបានសុង។ ដោយសារទីនោះ ជាកន្លែងល្ហល្ហេវមិនមានដើមឈើបិតបាំងយើងត្រូវធ្វើដំណើរនៅពេលយប់ដើម្បីធានាសុវត្ថិភាពរបស់យើង។ ដូច្នេះខ្ញុំនឹងសម្រាកឱ្យបានគ្រប់គ្រាន់មុនពេលចេញដំណើរ។ អាកាសធាតុក្តៅខ្លាំងណាស់ ធ្វើឱ្យខ្ញុំទទួលទានទឹកតែអស់ជាច្រើនពែង!

# ថ្ងៃទី ៣៧ ~ ថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៧៣

បន្ទាប់ពីដំណើរដ៏យូរមានរយៈពេលប្រាំបីម៉ោង យើងបានមកដល់ធាលីនៅម៉ោង ៦ និង ០០ នាទីព្រឹក។ នៅទីនេះខុសពី ស៊ីឡាណុន ដែលមានអាកាសធាតុក្ដៅខ្លាំង។ ឥឡូវនេះ យើងកំពុងស្ថិតនៅលើ "ជួរភ្នំជឿងសឺនដ៏អស្ចារ្យ"[២៦] ដែលមានអាកាសធាតុត្រជាក់ខ្លាំង។ យើងទាំងអស់គ្នាសម្រាកនៅពេលព្រឹក។ បន្ទាប់ពីស្រស់ស្រូបអាហារពេលព្រឹករួច យើងបានថតរូបជាមួយសមាជិកទាំងអស់ដែលរួមដំណើរជាមួយយើង។ នៅម៉ោងប្រហែល ១៦ និង ៣០ នាទី មានការបញ្ចាំងខ្សែភាពយន្តមួយបង្ហាញអំពីដំណើរទស្សនកិច្ចរបស់ក្រុមសិល្បៈនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ទៅកាន់ប្រទេសបារាំង, អ៊ីតាលី, អាល់ហ្សេរី, និងគុយបា។ នេះគឺជាខ្សែភាពយន្តដ៏រីករាយ ហើយយើងមានពេលវេលាមួយដ៏ល្អ បើទោះបីជាអាកាសធាតុត្រជាក់ខ្លាំង ដែលហាក់បីដូចជាយើងកំពុងនៅស៊ីបេរីក៏ដោយ! ខ្សែភាពយន្តនេះត្រូវបាក់បញ្ចាំងនៅកណ្ដាលវាល។ បន្ទាប់ពីនោះ មិត្តដែលមកពីមូលដ្ឋានយោធាបានរៀបចំពិធីជប់លៀងមួយ ដើម្បីទទួលស្វាគមន៍យើង។

ថ្ងៃស្អែក គឺជាថ្ងៃចុងក្រោយនៃដំណើរជាប្រវត្តិសាស្ត្រដ៏អស្ចារ្យ និងគួរឱ្យរំភើប ព្រមទាំងមិនអាចបំភ្លេចបានរបស់យើង ដែលមិនមែនមនុស្សគ្រប់រូបអាចធ្វើបាននោះទេ!

---

២៦. ជួរភ្នំជឿងសឺន ដែលត្រូវបានស្គាល់ថាជា ជួរភ្នំអាណ្ណាមលាតសន្ធឹងតាមព្រំដែនរវាងប្រទេសឡាវនិងប្រទេសវៀតណាម។ ផ្នែកខ្លះនៃជួរភ្នំនេះ មានកម្ពស់ជាង ២៥០០ ម៉ែត្រពីលើនីវ៉ូទឹកសមុទ្រ។

# ថ្ងៃទី ៣៨ ~ ថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៧៣

ព្រឹកនេះ នៅមុនពេលចេញដំណើរដែលគ្រោងធ្វើឡើងនៅម៉ោង ៦ និង ០០ នាទី យើងបានជួបសំណេះសំណាលជាមួយឧត្តមសេនីយ៍ យ៉ាប តាមប្រព័ន្ធទូរសព្ទពិសេស។ យើងពិតជាសប្បាយចិត្តខ្លាំងណាស់ហើយមានអារម្មណ៍ថាហាក់បីដូចជាបានទៅដល់ទីក្រុងហាណូយរួចបាត់ទៅហើយ!

ផ្ទៃមេឃគ្របដណ្តប់ដោយពពក ហើយយើងធ្វើដំណើរបានពាក់កណ្តាលផ្លូវ នៅលើភ្នំដែលមានអ័ព្ទស្តើងព័ទ្ធជុំវិញ។ អាកាសធាតុត្រជាក់ខ្លាំងណាស់។ ទេសភាពហាក់បីដូចជាមានភាពខុសប្លែកដោយសារអាកាសធាតុនេះ។

យើងទៅដល់មូលដ្ឋាន ៥៥៩ ដែលជាចំណុចចាកចេញរបស់យើងនៅម៉ោង ១០ និង ៣០ នាទី។ យើងទទួលបានការស្វាគមន៍យ៉ាងកក់ក្តៅពីមន្ត្រី, កម្មាភិបាល, និងយុទ្ធជននៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម។ អ្នកទាំងអស់គ្នាសប្បាយរីករាយដែលបានឃើញយើងមានសុខភាពល្អ! បន្ទាប់ពីធ្វើដំណើរទស្សនកិច្ចបែបនេះ! ថ្ងៃនេះយើងនឹងសម្រាកនៅទីនេះ ហើយថ្ងៃស្អែកយើងនឹងជិះយន្តហោះទៅកាន់ទីក្រុងហាណូយ។ នៅពេលខ្ញុំចូលទៅក្នុងបន្ទប់តូចមួយដែលរៀបចំសម្រាប់យើង ខ្ញុំមើលខ្លួនឯងនៅក្នុងកញ្ចក់ធំមួយផ្ទាំងដែលភ្ជាប់នឹងទូខោអាវ។ ខ្ញុំកត់សម្គាល់ឃើញថា ស្នាមរបួសនៅលើបបូរមាត់របស់ខ្ញុំបានជាសះស្បើយហើយ។ ដូច្នេះ ការធ្វើដំណើរដ៏មហាស្ចារ្យរបស់យើងក៏បានឈានមកដល់ទីបញ្ចប់ដូចគ្នា។ យើងនឹងតែងតែនិយាយរំឭក អំពីអារម្មណ៍នៃការធ្វើដំណើរដ៏អស្ចារ្យនេះ! នៅពេលយើងមកដល់ទីនេះ ដែលជាកន្លែងឈប់ចុងក្រោយ យើងបានភ្លេចអស់នូវភាពនឿយហត់ទាំងឡាយ។ យើងបានត្រៀមខ្លួនរួចរាល់ដើម្បីធ្វើដំណើរបែបនេះ ម្តងទៀត!

ឧត្តមសេនីយ៍ យ៉ាប បាននិយាយជាមួយយើងម្តងទៀតតាមតាមរយៈទូរសព្ទពិសេសនៅថ្ងៃនេះ។ យើងមានអារម្មណ៍រំភើបយ៉ាងខ្លាំងចំពោះទឹកចិត្តដ៏ប្រពៃរបស់លោក និងលោកស្រី ដែលខ្ញុំបានឆ្លើយឆ្លងជាមួយតាមទូរសព្ទ។ នៅទីនេះ គឺល្អខ្លាំងណាស់។ យើងមកចំពេលវេលាល្អ ពីព្រោះមិត្តវៀតណាមបានប្រាប់យើងថា កាលពីបីថ្ងៃមុនអាកាសធាតុមានសភាពក្តៅខ្លាំងណាស់។ នៅថ្ងៃខ្លះ យើងបានទទួលដំណឹងល្អអំពីជ័យជម្នះយោធា ដែលប្រជាជនរបស់យើងសម្រេចបាន។ ប៉ុន្តែ យើងក៏ទទួលបានដំណឹងដ៏ក្រៀមក្រំខ្លះទាក់ទងនឹងព្រះមហាក្សត្រិយានី និងបុត្ររបស់សម្តេច។ ជនក្បត់ជាតិបានធ្វើការសងសឹកចំពោះភាពបរាជ័យនៃប្រតិបត្តិការរបស់ខ្លួនប្រឆាំងនឹងយើងក្នុងដំណើរទស្សនកិច្ចមកកាន់ប្រទេសកម្ពុជា។ ជនក្បត់ គឺពិតជាកំសាកខ្លាំងណាស់ ប៉ុន្តែជនក្បត់ទាំងនេះ អាចប្រព្រឹត្តទង្វើអាក្រក់គ្រប់បែបយ៉ាង!

ខ្ញុំនឹងបញ្ចប់សៀវភៅកំណត់ហេតុក្នុងពេលឆាប់ៗនេះ ...

យើងមានបេសកកម្មមួយទៀតនៅពេលទៅដល់ប្រទេសចិនវិញ។ នៅក្នុងប្រទេសកម្ពុជា យើងបានធ្វើដំណើរតាមរថយន្តអស់ចម្ងាយ១២០០គីឡូម៉ែត្រពីព្រំដែនវៀតណាមទៅកាន់ ប្រាសាទអង្គរវត្ត រួចត្រឡប់មកវិញ។ នៅលើផ្លូវលំហូជីមិញ យើងបានធ្វើដំណើរអស់ចម្ងាយ១៦០០គីឡូម៉ែត្រ ដែលសរុបទៅគឺចម្ងាយ២៨០០គីឡូម៉ែត្រ នៅលើផ្លូវដ៏លំបាកលំបិននិងគ្រោះថ្នាក់បំផុតក្នុងតំបន់ឥណ្ឌូចិន! សូមអរគុណចំពោះមិត្តវៀតណាម និងថ្នាក់ដឹកនាំវៀតណាម ដែលបានជួយជ្រោមជ្រែងយ៉ាងសស្រាក់សស្រាំដល់ការធ្វើដំណើរជាប្រវត្តិសាស្ត្រនេះ។ សូមអរគុណ ផ្លូវលំហូជីមិញ! យើងពិតជាអរគុណណាស់! សូមថ្លែងអំណរគុណដល់បងប្អូនខ្មែរ និងមិត្តវៀតណាមទាំងអស់ ដែលបានយកចិត្តទុកដាក់ចំពោះយើង និងទឹកចិត្តដ៏ថ្លៃថ្លាក្នុងអំឡុងពេលធ្វើដំណើរមួយនេះ។ យើងបានជួបប្រទះគ្រោះថ្នាក់ជាច្រើន និងប្រឈមមុខនឹងភាពអស់កម្លាំង ប៉ុន្តែយើងអាចវិលត្រឡប់មកវិញដោយសុវត្ថិភាពនិងសុខភាពល្អ។ ខ្ញុំមានមោទកភាព ដែលអាចនិយាយបានថា យើងស្ថិតនៅក្នុងតំបន់រំដោះនៃប្រទេសកម្ពុជា នៅពេលដែលយន្តហោះសត្រូវវាយប្រហារមកលើប្រទេសកម្ពុជាឥតឈប់ឈរ។ យើងមានមោទកភាព ដែលអាចធ្វើដំណើរឆ្លងកាត់ផ្លូវលំហូជីមិញដ៏ល្បីល្បាញ! តាមការពិត គឺយើងមិនត្រឹមតែធ្វើដំណើរនៅលើផ្លូវតែមួយនោះទេ គឺនៅលើផ្លូវជាច្រើន!

នៅរសៀលនេះ សម្តេចទ្រង់ជួបជាមួយអង្គភាពបញ្ជូនព័ត៌មានមួយនៅម៉ោង ១៩ និង ០០ នាទី បន្ទាប់មក យើងទស្សនាខ្សែភាពយន្តអំពីផ្លូវលំហូជីមិញ។ នេះគឺជាខ្សែភាពយន្តថ្មីនិងអស្ចារ្យ។ ចំពោះយើងដែលទើបតែធ្វើដំណើរឆ្លងកាត់ផ្លូវលំហូជីមិញថ្មីៗ ខ្សែភាពយន្តនេះបាននាំមកនូវការចងចាំជាច្រើន។ បន្ទាប់ពីខ្សែភាពយន្តបញ្ចប់ទៅ យើងបានចូលរួមពិធីជប់លៀងដែលមានបរិយាកាសរួសរាយ និងរាក់ទាក់។ អ្នករាល់គ្នាមានអារម្មណ៍សប្បាយរីករាយ ប៉ុន្តែមានការសោកស្តាយបន្តិចដែរ ពីព្រោះយើងជិតឃ្លាតគ្នាហើយ បន្ទាប់ពីចំណាយអស់រយៈពេលមួយខែធ្វើដំណើររួមគ្នា។ ប៉ុន្តែអ្វីៗគ្រប់យ៉ាងគឺតែងតែមានទីបញ្ចប់។ យើងនឹងធ្វើដំណើរមកទីនេះម្តងទៀត។ មានអ្នកជានាប្រាប់យើងថា ទម្រាំពេលនោះ ផ្លូវលំហូជីមិញនឹងស្ថិតនៅក្នុងសភាពប្រសើរជាងនេះ!



សម្តេចម៉ែព្រះអង្គគង់នៅប្រាសាទបន្ទាយស្រី

# ថ្ងៃទី ៣៩ ~ ថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៧៣

ព្រឹកនេះ គឺជាថ្ងៃចុងក្រោយរបស់យើងនៅមូលដ្ឋាន ៥៥៩។ ពិធីជប់លៀងមួយត្រូវបានរៀបចំឡើង ហើយសម្តេចបានប្រទានអំណោយដល់សមាជិកក្រុមអ្នកអមដំណើរទាំងអស់ (ចំនួន១១៥នាក់) ដែលបានធ្វើដំណើរជាមួយយើងឆ្លងកាត់ផ្លូវលំហូជីមិញ។ មេបញ្ជាការនៃមូលដ្ឋាន៥៥៩ បានប្រគល់ជូនយើងនូវ គំនូរដ៏អស្ចារ្យមួយផ្ទាំងអំពីផ្លូវលំហូជីមិញ គូរដោយវិចិត្រករម្នាក់ដែលកំពុងប្រយុទ្ធតស៊ូនៅឯសមរភូមិ។ នេះគឺជាអំណោយដ៏វិសេសវិសាល ដែលយើងត្រូវតម្កល់ទុកនៅសារមន្ទីររំដោះនៅទីក្រុងភ្នំពេញ។

ខ្ញុំមិនត្រូវភ្លេចលើកឡើងថា សម្តេចបាននិពន្ធចម្រៀងមួយបទក្នុងអំឡុងពេលធ្វើដំណើរត្រឡប់មកវិញ។ ចម្រៀងនេះ មានចំណងជើងថា "អរគុណ ផ្លូវលំហូជីមិញ"។

សត្វទោចទាំងពីរក្បាលរបស់យើង បានឆ្លងកាត់ដំណើរនេះប្រកបដោយជោគជ័យ។ សត្វទាំងពីរបានផ្សាភ្ជាប់យើងទៅនឹងប្រទេសកម្ពុជា! ជាអកុសលក្នុងចំណោមសត្វសេកចំនួនប្រាំបីក្បាល ដែលយើងទទួលបាននៅ ស៊ីឡាណុន នោះ សេកចំនួនប្រាំពីរក្បាលបានងាប់ទៅក្នុងអំឡុងពេលធ្វើដំណើរ។ យើងសម្រេចចិត្តទុកសត្វសេកដែលនៅរស់មួយក្បាលចុងក្រោយ ដែលហាក់បីដូចជាមានសុខភាពមិនសូវល្អផងនៅមូលដ្ឋាន ៥៥៩។ នៅទីនោះប្រហែលជាវាអាចមានស្ថានភាពប្រសើរឡើងជាងនេះ។

យើងនឹងឡើងយន្តហោះចាកចេញពីដុងហ្ហយក្នុងពេលឆាប់ៗនេះ ដើម្បីឆ្ពោះទៅកាន់ទីក្រុង ហាណូយ។ ខ្ញុំរីករាយនៅពេលឃើញឆ្កែដ៏តូចរបស់ខ្ញុំឈ្មោះថា មីក្ូ ដែលលេខារបស់ខ្ញុំគឺ លោកស្រី ស សារ័ត្ន បាននាំមកជាមួយនៅព្រឹកនេះ។ លោកស្រីបានមកចូលរួមដំណើរជាមួយយើង និងសមាជិកដទៃទៀតនៃរណសិរ្សរួបរួមជាតិកម្ពុជានិងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ សម្តេច ប៉ែន នុត និងភរិយារបស់លោក កំពុងតែរង់ចាំយើងនៅដុងហ្ហយ។ មីក្ូគឺជាឆ្កែតូចពូជ ម៉ាល់ទីស ប៊ីឈុន ដ៏ស្រស់ស្អាតមួយ ដែលមានអាយុប្រាំបួនខែ។ មីក្ូ គឺជាព្រះអំណោយរបស់ព្រះអង្គម្ចាស់និងម្ចាស់ក្សត្រី ស៊ូផានូវង្ស នៃប្រទេសឡាវ ប្រទានមកឱ្យខ្ញុំនៅខែតុលា ឆ្នាំ១៩៧២។

# អវសានកថា

សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ គឺជាព្រះរាជតំណាងនៃភាពរឹងមាំ។ ព្រះអង្គ គឺជាវរស្ត្រីដ៏ស្រស់ស្អាតមួយអង្គ ដែលបានស៊ូទ្រាំនឹងការលំបាករាប់មិនអស់ ប្រកបជាមួយនឹងសេចក្តីថ្លៃថ្នូរ និងភាពក្លាហាន។ តាមរយៈ សម្តេចព្រះមហាក្សត្រី យើងអាចសិក្សាស្វែងយល់អំពីអាណានិគមនិយម ឯករាជ្យភាព សង្គ្រាមស៊ីវិល អំពើប្រល័យពូជសាសន៍ លទ្ធិប្រជាធិបតេយ្យ និងប្រវត្តិសាស្ត្រដ៏ស្មុគស្មាញនៃប្រទេសកម្ពុជា ដែលជាប្រទេសមួយតែងតែត្រូវបានមើលរំលង។

# អំពីមជ្ឈមណ្ឌលឯកសារកម្ពុជា

មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៥ បន្ទាប់ពីសភាសហរដ្ឋអាមេរិកអនុម័តឱ្យមានច្បាប់ស្តីពីយុត្តិធម៌សម្រាប់អំពើប្រល័យពូជសាសន៍ នៅក្នុងខែមេសា ឆ្នាំ១៩៩៤ ដែលចុះហត្ថលេខាជាធរមានដោយប្រធានាធិបតី ឃ្លីនតុន។ រាជរដ្ឋាភិបាលកម្ពុជា បានគាំទ្រមជ្ឈមណ្ឌលឯកសារកម្ពុជាជាផ្លូវការ។ មជ្ឈមណ្ឌលឯកសារកម្ពុជា ទទួលបានការកោតសរសើរ និងពានរង្វាន់ជាច្រើនចំពោះកិច្ចការរបស់ខ្លួន ក្នុងការគាំទ្រឱ្យមានការចងចាំនិងយុត្តិធម៌សម្រាប់ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា។ នៅក្នុងឆ្នាំ ២០១៧ មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានពានរង្វាន់សិទ្ធិមនុស្ស ដូឌិត លី ស្រ្តូណាច់ ពីមជ្ឈមណ្ឌលយុត្តិធម៌និងការទទួលខុសត្រូវ។ នៅក្នុងឆ្នាំដដែល ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ទ្រង់ព្រះរាជទានគ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ធិបឌិន្ទ ដល់លោក ឆាំង យុ ជាការទទួលស្គាល់ស្នាដៃដ៏ល្បីល្បាញរបស់លោកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងឆ្នាំ ២០១៨ មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏ជាម្ចាស់ពានរង្វាន់ រ៉ាម៉ុន ម៉ាកសៃ សៃ ដែលត្រូវបានចាត់ទុកថាជាពានរង្វាន់ណូបែលអាស៊ី ក្នុងការថែរក្សាការចងចាំជាប្រវត្តិសាស្ត្រដើម្បីការព្យាបាលរបួសផ្លូវចិត្ត និងយុត្តិធម៌។





...បន្ទាប់មក យើងបានចាកចេញពី សេស្វ នៅម៉ោងប្រហែល ៣ និង ០០ នាទីព្រឹក ដោយសេចក្តីសប្បាយរីករាយ ពីព្រោះយើងគិតថា ត្រឹមប៉ុន្មានម៉ោងទៀតតែប៉ុណ្ណោះ យើងនឹងមកដល់មាតុភូមិហើយ។ ខ្ញុំមិនអាចពិពណ៌នាអំពីអារម្មណ៍ដែលខ្ញុំមាននៅពេលនេះបានទេ! ខ្ញុំពិតជាសោកស្តាយណាស់ ដែលខ្ញុំមិនមែនជាអ្នកនិពន្ធកំណាព្យ ដែលអាចសរសេររៀបរាប់នៅក្នុងសៀវភៅកំណត់ហេតុនេះនូវអារម្មណ៍របស់ខ្ញុំ នៅពេលដែលអាចឃើញមាតុភូមិម្តងទៀត!...

មុនិនាថ